ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



◆ ថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ បានរំឭកប្រជាជនខ្មែរអំពីសោកនាដកម្ម ការបែកបាក់ និងការបាត់បង់សមាជិកគ្រួសារ

◆ ឯកអគ្គរដ្ឋទូតសហព័ន្ធរុស្ស៊ីប្រចាំនៅកម្ពុជា លោក អាណាតូលី បូរ៉ូវីក មកទស្សនកិច្ចបណ្ណាល័យសម្ដេចម៉ែ

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២៨០ ខែមេសា ឆ្នាំ២០២៣

# ស្វែងរកការពិត

## ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ ២៨០ ខែមេសា ឆ្នាំ២០២៣

## មាតិកា

### សំបុត្រ

◆ ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ............... ១
◆ បទចម្រៀងខ្មែរក្រហម ១៧ មេសា ........ ៤

### ផ្នែកឯកសារ

◆ អៀង ជុងខេង ៖ កងទ័ពសេរីកា មកពី...... ៦

### ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ

◆ ឯកអគ្គរដ្ឋទូតសហព័ន្ធរុស្ស៊ីប្រចាំនៅកម្ពុជា លោក អាណាតូលី បូរ៉ូវីក មកទស្សនកិច្ច... ៩
◆ ការជំរុញទឹកចិត្តចំពោះអ្នកស្ម័គ្រចិត្ត...... ១២
◆ ដាំ ឡូងឈើនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ...១៣
◆ បណ្ណាល័យ សម្ដេចម៉ែនៃមជ្ឈមណ្ឌលឯកសារ កម្ពុជា ប្រគល់អំណោយម៉ូតូកង់បីជូន ..... ១៤
◆ រឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរ ក្រហមចេញពីភូមិបាក់នឹម.................. ១៧
◆ រឿងរ៉ាវជីវិតនិងបញ្ហាសុខភាពរបស់អ្នករស់រាន មានជីវិតពីរបបខ្មែរក្រហមចំនួន ៥០០... ២៤
◆ ខ្ញុំឈឺចាប់នៅពេលដឹង កូនស្រីខ្ញុំបាត់..... ២៨
◆ វ័យជាកុមារ ធ្វើការក្នុងកងនារី ............ ៣០
◆ ខ្ញុំបេះកាត់ដេរដោយសារ ខ្ញុំមើលពី....... ៣២
◆ ក្រសែភ្នែកក្មេងស្រីម្នាក់មើលឃើញតែ... ៣៣
◆ ខ្ញុំតែងគិតថា ជីវិតខ្ញុំរស់បានមួយថ្ងៃ ....... ៣៥
◆ ប្រជាជនថ្នាក់កណ្ដាល ទទួលរងការ ...... ៣៨
◆ ការជម្លៀសរបស់ប្រជាជនត្រៀមនៅ .... ៤១
◆ ទុក្ខលំបាករបស់នារីកងចល័តនៅក្នុង..... ៤៣

### ផ្នែកវេទិកាពិភាក្សាសាធារណៈ

◆ យុវជនជំនាន់ក្រោយរំពឹកពីការចងចាំប្រវត្តិសាស្ត្ររបបខ្មែរក្រហម............................ ៤៥



ប្រជាជនកម្ពុជាវិលត្រឡប់មកភូមិកំណើតវិញ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

◆ សិស្សវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន ស្ទឹង ចូលរួមវេទិកាថ្នាក់រៀនចុងសប្ដាហ៍ស្ដីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ..................... ៥១
◆ ជំនួបជាមួយលោក ឯក ចិន្ដា ចៅសង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង ..... ៥៦

### ផ្នែកស្រាវជ្រាវរកគ្រួសារ

◆ **«ទួលពិឃាដ»** (ត) ......................... ៥៩

**រក្សាសិទ្ធិ**
មជ្ឈមណ្ឌលឯកសារកម្ពុជា
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ៣៧៥ព.មប្រក
ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨
រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា

**ស្នេរលេខនេះ ៖** សោម ប៊ុនថន, ឆាំង យុ, ដារ៉ារដ្ឋ មេត្តា, លីម អ៊ិភីង, ផាត ចាន់សុនិតា, ង៉ាន់ វីន, ជីម សុខគា, ដេង ពង្សរ៉ាស៊ី, លី ដេវីត, ទូច វណ្ណេត, ថុន ស្រីពេជ្រ, និង ឡុង វង្សសមិទ្ធ
**អ្នកនិពន្ធ និងស្រាវជ្រាវ៖** ផាត ចាន់សុនិតា **អ្នកបកប្រែ៖** លីម អ៊ិភីង និង ជ័យ ចាន់ស៊ីណែត **និពន្ធនាយកទូទៅ៖** សោម ប៊ុនថន
**ជំនួយការនិពន្ធនាយក៖** ដារ៉ារដ្ឋ មេត្តា **ក្រាហ្វិកកុំព្យូទ័រ៖** លី សេនសូនីឡា **គ្រប់គ្រងការចែកផ្សាយ៖** ឆេង វ៉េង
Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiasri.org

# ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បានរំឭកប្រជាជនខ្មែរអំពីសោកនាដកម្ម

## ការបែកបាក់ និងការបាត់បង់សមាជិកគ្រួសារ

សោម ប៊ុនថន



ប្រជាជនកម្ពុជាត្រូវបានយោធាខ្មែរក្រហមជម្លៀសចេញពីផ្ទះសម្បែងនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រៀងរាល់ឆ្នាំប្រជាជនខ្មែរដែលស្នាក់នៅប្រទេសកម្ពុជា និងធ្វើការនៅតំបន់ឆ្ងាយៗតែងតែវិលត្រឡប់មកស្រុកកំណើត ដើម្បីជួបជុំឪពុកម្ដាយ សាច់ញាតិ និងសមាជិកក្រុមគ្រួសារ ដើម្បីអបអរ និងប្រារព្ធពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ដែលមានរយៈពេលបីថ្ងៃនៅក្នុងខែមេសា នៅតាមភូមិស្រុករៀងៗខ្លួន។ ប៉ុន្តែបើយើងនឹកគិតទៅដល់៤៨ឆ្នាំមុន នៅក្នុងរដូវចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ គឺជាថ្ងៃដែលយោធាខ្មែរក្រហមវាយដណ្ដើមបានប្រទេសកម្ពុជា និងបានឡើងគ្រប់គ្រងអំណាចទាំងស្រុង។ ភ្លាមៗនោះយោធាខ្មែរក្រហមបានបណ្ដេញប្រជាជនចេញពីផ្ទះសម្បែង ហើយគ្រប់ក្រុមគ្រួសារប្រជាជនខ្មែរបានបែកបាក់សមាជិក។ ថ្ងៃនេះដែរក៏ជាថ្ងៃនៃការចាប់ផ្ដើមសោកនាដកម្ម អំពើប្រល័យពូជសាសន៍ និងការសម្លាប់ប្រជាជនខ្មែរយ៉ាងរង្គាលនៅទូទាំងប្រទេស។

បន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩ មានប្រជាជនខ្មែរស្លូតត្រង់ប្រមាណជាង ២លាននាក់បានបាត់បង់ជីវិត និងបានបន្សល់នូវជនពិការ ក្មេងកំព្រា ស្ត្រីមេម៉ាយ ព្រមទាំងប្រជាជនដែលមានជំងឺផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរ។ សព្វថ្ងៃមានអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមប្រមាណជាង៥លាននាក់ ហើយអ្នកទាំងនេះកាន់តែមានវ័យចាស់ជរា ទ្រុឌទ្រោម និងកំពុងប្រឈមបញ្ហាសុខភាពដែលគាត់គួរតែទទួលបាននូវការយកចិត្តទុកដាក់ និងសេវាថែទាំសុខភាព។ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមទាំងនេះ បានឆ្លងកាត់រឿងរ៉ាវរន្ធត់ និងបានឆ្លងកាត់ការលំបាកគ្រប់យ៉ាងក្នុងការចូលរួមកសាងជីវភាពគ្រួសារ សហគមន៍ និងស្តារប្រទេសជាតិដែលខ្ទេចខ្ទាំឡើងវិញ ដូច្នេះរឿងរ៉ាវរបស់គាត់ក៏មិនត្រូវបានបំភ្លេចចោល ហើយគួរត្រូវបានលើកមកនិយាយឲ្យបានទូលំទូលាយដើម្បីអប់រំដល់មនុស្សជំនាន់ក្រោយ និងទប់ស្កាត់កុំឲ្យរបបខ្មែរក្រហមកើតឡើងម្តងទៀត។

ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ មិនត្រឹមបានរំពុកប្រជាជនខ្មែរឡើងវិញពីសោកនាដកម្ម ការបែកបាក់និងការបាត់បង់សមាជិកគ្រួសារតែប៉ុណ្ណោះទេ ប៉ុន្តែបានជំរុញឲ្យប្រជាជនខ្មែរកាន់តែមានភាពរឹងមាំទៅថ្ងៃអនាគត។





ប្រជាជនកម្ពុជាត្រូវបានយោធាខ្មែរក្រហមជម្លៀសចេញពីផ្ទះសំបែងនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



យោធាខ្មែរក្រហមចូលក្នុងទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



យោធាខ្មែរក្រហមចូលក្នុងទីក្រុងភ្នំពេញនៅ
ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



# បទចម្រៀងខ្មែរក្រហម ១៧ មេសា ១៩៧៥

ឆាំង យុ



ការសម្តែងសិល្បៈរបស់កងសិល្បៈខ្មែរក្រហម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ពីរបីថ្ងៃបន្ទាប់ពីការឡើងកាន់កាប់អំណាចនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានបង្ខំប្រជាជនប្រហែលពីរលាននាក់ដែលកំពុងរស់នៅក្នុងទីក្រុងភ្នំពេញ និងនៅតាមទីប្រជុំជនដទៃទៀតឲ្យចាកចេញទៅកាន់ទីជនបទ ដើម្បីធ្វើការងារកសិកម្ម។ ប្រជាជនរាប់ពាន់នាក់បានស្លាប់នៅក្នុងអំឡុងពេលជម្លៀសនេះ។

ពេលជាមួយគ្នានេះ ខ្មែរក្រហមបានចាប់ផ្តើមអនុវត្តកម្មវិធីកែទម្រង់តាមលទ្ធិម៉ៅ និងលទ្ធិម៉ាក្សលេនីនដ៏ជ្រុលហួសហេតុ។ ខ្មែរក្រហមចង់ប្រែក្លាយប្រទេសកម្ពុជាឲ្យទៅជាប្រទេសដែលមិនមានវណ្ណៈសង្គម ពោលគឺពុំមានអ្នកមាន ពុំមានអ្នកក្រ និងគ្មានការកេងប្រវ័ញ្ចគ្នា។ ដើម្បីសម្រេចឲ្យបានគោលបំណងនេះ ខ្មែរក្រហមបានលុបបំបាត់រូបិយវត្ថុ ផ្សារ ការអប់រំ ទ្រព្យសម្បត្តិឯកជន ម៉ូតសម្លៀកបំពាក់ស៊ីវិល័យបរទេស ការគោរពជំនឿសាសនា និងប្រពៃណីវប្បធម៌ខ្មែរ។ សាលារៀន វត្តអារាម វិហារសាសនាអ៊ីស្លាម វិហារសាសនាគ្រិស្ត សាកលវិទ្យាល័យ ហាងលក់ទំនិញ និងអគាររដ្ឋាភិបាល ត្រូវបិទទ្វារ ឬក៏ប្រែក្លាយទៅជា (មន្ទីរសន្តិសុខ) គុក គ្រោលគោ ជំរំអប់រំកែប្រែ និងជង្រុកស្រូវ។

ខ្មែរក្រហមបានបន្តនិរន្តរភាពរបស់ខ្លួនរហូតដល់ឆ្នាំ១៩៩៩ គឺនៅពេលដែលមេដឹកនាំខ្មែរក្រហមទាំងអស់ចុះចូលជាមួយរដ្ឋាភិបាលកម្ពុជា ឬ ត្រូវចាប់ខ្លួន ឬទទួលមរណភាព។ ក៏ប៉ុន្តែ ខ្មែរក្រហមបានបន្សល់ទុកនូវភាពប្រេះស្រាំក្នុងសង្គមជាតិរហូតដល់សព្វថ្ងៃនេះ។

នៅក្នុងរបបខ្មែរក្រហម ប្រជាជនកម្ពុជាប្រមាណជាងពីរលាននាក់បានស្លាប់ដោយសារជំងឺដែលបណ្តាលមកពីការខ្វះខាតថ្នាំសង្កូវ និងសេវាសុខាភិបាល ការអត់អាហារ ការសម្លាប់ ឬការធ្វើពលកម្មហួសកម្លាំង។ ប្រជាជនដែលនៅរស់រានមានជីវិត ក្រោយរបបខ្មែរក្រហមបានទទួលរងនូវការប៉ះទង្គិចផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរ ដោយសារតែបទពិសោធន៍ដែលខ្លួនបានជួបប្រទះ។



កងសិល្បៈខ្មែរក្រហម នៅប្រាសាទបន្ទាយស្រី។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# អៀង ជុងខេង ៖ កងទ័ពសេរីកា មកពីប្រទេសសៀម

**ដារ៉ារដ្ឋ មេត្តា**



ទាហាន លន់ នល់ នៅបន្ទាយព្រះកែវមរកត ក្នុងក្រុងភ្នំពេញ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ អៀង ជុងខេង ហៅ សំឡេង ភេទប្រុស អាយុ២៧ឆ្នាំ (នៅក្នុងឆ្នាំ១៩៧៧)។ ខ្ញុំមានស្រុកកំណើតនៅភូមិដំណាក់ពពូល ឃុំកំពង់ឆ្នាំង (បច្ចុប្បន្នក្រុងកំពង់ឆ្នាំង) ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង។ នៅក្នុងឆ្នាំ១៩៧២ ខ្ញុំប្រឡងធ្លាក់ឌីប្លូម នៅវិទ្យាល័យ ១៨ មីនា។ ក្រោយមកខ្ញុំធ្វើជាភ្នាក់ងារឲ្យការសែតនគរធំតាមរយៈឈ្មោះ ពៅ។ ឈ្មោះ ទៀវយូ គឺជាអតីតគ្រូបង្រៀន និង មាស ហនបានអប់រំខ្ញុំពីអាមេរិកចិត្តល្អ រួចបញ្ចូលខ្ញុំជា សេ-អុី-អា ដោយមានអ្នកទទួលស្គាល់ឈ្មោះ ម៉ក់ ម៉េន និង មានជនជាតិអាមេរិក ម្នាក់ឈ្មោះ ស្មេនរី វ៉ាន់ស្រុន។

នៅក្នុងឆ្នាំ១៩៧៣ ខ្ញុំឈប់រៀន ហើយទៅរកស៊ីលក់អង្ករជាមួយម្ដាយនៅផ្សារតូច ខេត្តបាត់ដំបង។ នៅក្នុងខែសីហា ឆ្នាំ១៩៧៣ ដដែល ខ្ញុំប្រឡងជាប់ឌីប្លូម ហើយដាក់ពាក្យចូលធ្វើទាហានពាក់ដោយ ១ ជាន់ នៅកងពលរបស់ ឈឹម ឈួន។ នៅក្នុងខែកុម្ភៈ ឆ្នាំ១៩៧៥ ខ្ញុំពាក់អាស្ដង់ និងបានទៅលេងម្ដាយនៅខេត្តបាត់ដំបង។

នៅខែឧសភា ឆ្នាំ១៩៧៥ ចៅ សន បាត់តាំងខ្ញុំ និងឈ្មោះ ចាន់គឺជាទាហានពាក់អាស្ដង់សែប និង វ៉ន

គឺជាទាហានពាក់ដោយសែបឲ្យទៅរៀនខាងក្នាក់ផារស៊ើបអង្កេតនៅខាងជើងភ្នំដងរែក ដោយមានអ្នកបង្រៀនឈ្មោះ ឡាំ គឺជាខ្មែរកម្ពុជាក្រោម និង ធូ វ៉ាត់ គឺជាជនជាតិសៀម។ យុទ្ធវិធីស៊ើបអង្កេតគឺក្លែងបន្លំខ្លួនធ្វើជាប្រជាជនចូលទៅវាយការណ៍ និង ឲ្យរៀបចំផែនទី។ រៀនអស់រយៈពេល២ខែជាង ខ្ញុំ, ចាន់, វន បានត្រឡប់មកកងវិញ។ ចំណែក ប៊ុន សង់ និង ចៅ សន ចាត់តាំងខ្ញុំ,វឿន ឲ្យដើរអប់រំប្រជាជនដែលរត់ចេញពីប្រទេសខ្មែរហើយទើបតែចូលទៅប្រទេសសៀមឲ្យធ្វើកងទ័ពសេរីកា ដើម្បីពង្រឹងកម្លាំងកងទ័ពឲ្យបានច្រើនវាយចូលមកប្រទេសកម្ពុជាវិញ។ ក្រោយមក ចៅ សន ចាត់តាំងខ្ញុំ, អាង, នួន ឲ្យចូលមកក្នុងប្រទេសខ្មែរ ស៊ើបរកកន្លែងកងទ័ពបដិវត្តន៍នៅកន្លែងណាខ្លះ, ឲ្យខ្ញុំ, នួន ចូលមកទាក់ទងឈ្មោះ លន គឺជាអតីតទាហានរស់នៅក្នុងភូមិខ្លុងពពក ស្រុកទឹកផុស តំបន់៣១ ដើម្បីសួរពីកម្លាំងប្រឆាំងបដិវត្តន៍។ បន្ទាប់មកឲ្យ សន ចលនាប្រជាជនរត់ទៅភ្នំឱរ៉ាល់ និងយកស្បៀងឲ្យឈ្មោះ គឹម សៀង នៅភ្នំឱរ៉ាល់។

នៅខែមករា ឆ្នាំ១៩៧៦ ខ្ញុំបានវាយការណ៍ឲ្យ បងនាគ ពីដំណើរការនាំកម្លាំង១៥នាក់ទៅប្រទេសសៀមហើយ បងនាគ បានឲ្យអង្ករមកខ្ញុំចំនួន៧តៅកន្លះសម្រាប់ទុកហូបពេលធ្វើដំណើរ។ នៅខែមីនា ឆ្នាំ១៩៧៦ ខ្ញុំបានចូលរួមប្រជុំផែនការពីឈ្មោះ ប៊ុន សង នៅភ្នំដងរែកដែលអ្នកចូលរួមប្រជុំមានចៅ សន និង ឡាំ ដែលមានខ្លឹមសារដូចតទៅ ៖ ចៅ សនបានចាត់តាំងខ្ញុំឲ្យធ្វើបន្ទាយមួយនៅភ្នំធំដើម្បីដឹកស្បៀងយកពីសៀមមកទុកនៅបន្ទាយភ្នំធំ និងត្រៀមរង់ចាំយកអាវុធ និងកងទ័ពដែលខ្ញុំ និង លាង ទៅយកពីភ្នំឱរ៉ាល់ ដើម្បីបញ្ចូលឲ្យធ្វើជាកងទ័ពសេរីកា និងម៉្យាងទៀតងាយស្រួលបញ្ជូនស្បៀងទៅឲ្យឈ្មោះ គឹម សៀង នៅភ្នំឱរ៉ាល់។ នៅខែមេសា ឆ្នាំ១៩៧៦ តាមការចាត់តាំងរបស់ ប៊ុន សង ខ្ញុំនិង ចៅ សនបានទៅអប់រំប្រជាជនភូមិតាង រស់នៅតាមជើងភ្នំដងរែក ដែលទើបរត់ចេញពីប្រទេសខ្មែរនៅក្រោយថ្ងៃរំដោះ ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ឲ្យជាកងទ័ពសេរីការបស់ ប៊ុន សន។ បន្ទាប់ពីប្រមូលកម្លាំងបានច្រើន យើងបានបង្កើតជាកងពលតូចលេខ២០៥របស់ ប៊ុន សង និងត្រៀមផែនការវាយនៅខេត្តសៀមរាប ឧត្តរមានជ័យ និង ខេត្តព្រះវិហារ នៅក្នុងខែមីនា ឆ្នាំ១៩៧៧។

នៅខែកញ្ញា ឆ្នាំ១៩៧៧ ក្រុមរបស់ខ្ញុំនិងប្រជាជននៅក្នុងភូមិព្រះម្លូ ឃុំបឹងខ្នារ ស្រុកបាកាន ខេត្តពោធិ៍សាត់ បានរត់ទៅប្រទេសសៀម។ យើងធ្វើដំណើរតាមផ្លូវ អូរជ្រៅ ដោយមានកាំភ្លើងខ្លីកាន់ម្នាក់មួយដើម,ផែនទីខេត្តបាត់ដំបង និង ត្រីវិស័យមួយ។ នៅពេលទៅដល់អារញ្ញ លាង បានស្គាល់ឈ្មោះ អ៊ុំ ភឿង គឺជាសៀមកាត់ខ្មែរ រស់នៅភូមិសៃរ៉ាន់ ខេត្តអារញ្ញ។ លាងបានសុំផ្ទះរបស់ អ៊ុំ ភឿង ស្នាក់នៅរយៈពេល៥ថ្ងៃ។ ខ្ញុំ និង លាងបាននាំគ្នាទៅលេងផ្សារអារញ្ញ ហើយបានជួបទាហានខ្មែរចំនួន៣នាក់ដែលបានមកលេងផ្សារអារញ្ញដែរ មានឈ្មោះ លឹម ពាក់ដោយ១ជាន់ និង ពីរនាក់ទៀតខ្ញុំមិនបានស្គាល់ឈ្មោះ។ ខ្ញុំ និង លាងបានសួរទាហានខ្មែរទាំង៣នាក់នោះក៏បានទទួលព័ត៌មានថា មេបញ្ជាការរបស់ខ្ញុំឈ្មោះ ចៅ សន (ពាក់សក្តិ៣ នៅប្រទេសសៀម) នៅលើកំពូលភ្នំដងរែក។ ក្រោយមកខ្ញុំ និង លាងបានសុំឲ្យទាហានទាំង៣នាក់នាំពួកយើងមកកំពូលភ្នំដងរែក ទៅជួបមេបញ្ជាការរបស់ខ្ញុំ។ ក្រោយពីជួប ចៅ សនបានឲ្យខ្ញុំ និង លាង ចូលធ្វើកងទ័ពសេរីកាជាមួយ។ ក្រោយមក ចៅ សនបាននាំយើងមកជួបជាមួយឈ្មោះប៊ុនសេង(ពាក់សក្តិ៥កងទ័ពសេរីកា) ដើម្បីឲ្យគាត់ទទួលស្គាល់។ ចៅ សនបានដាក់ផែនការឲ្យខ្ញុំចូលយកការណ៍នៅក្នុងប្រទេសកម្ពុជា គឺយកការណ៍ពីកងទ័ពបដិវត្តន៍នៅស្រុកភ្នំក្រវ៉ាញ ពិនិត្យមើលជង្រុកស្រូវ និងមើលភូមិសាស្ត្រដើម្បីយកទាហានសៀមមកវាយយកស្រូវ និងជម្លៀសប្រជាជនស្រុកភ្នំក្រវ៉ាញ ហើយយកស្រុកភ្នំក្រវ៉ាញធ្វើជាទីតាំងរបស់សៀម។ ក្រោយពី ចៅ សន ដាក់ផែនការរួចហើយ ខ្ញុំ និង ធឿន បានយកផែនទីខេត្តកំពង់ឆ្នាំង និងត្រីវិស័យមួយម្នាក់ និងកាំភ្លើងខ្លីម្នាក់មួយដើមចូលមកប្រទេសខ្មែរ ដោយធ្វើដំណើរកាត់មកតាមស្រុកភ្នំក្រវ៉ាញ និងសំដៅទៅភ្នំឱរ៉ាល់។

ពេលមកដល់ភ្នំឱរ៉ាល់ ខ្ញុំបានជួប គីម សៀង ហើយខ្ញុំបានយកសំបុត្ររបស់ ប៊ុន សង ទៅឲ្យឈ្មោះ គីម សៀង ហើយខ្ញុំបានសូមកូនទាហានរបស់ គីម សៀង ៣នាក់ឲ្យជូនខ្ញុំមកកំពង់ស្ពឺ។ ពេលនោះខ្ញុំបានបែកគ្នាជាមួយឈ្មោះ ធឿន។ ពេលខ្ញុំមកដល់ពាក់កណ្ដាលផ្លូវផុតភ្នំឱរ៉ាល់ ទាហានទាំង៣នាក់ នេះក៏ត្រឡប់ទៅកន្លែងវិញ។ ខ្ញុំបានដើរតាមផ្លូវរទេះគោឡើងទៅភូមិដីថ្មី ខេត្តកំពង់ស្ពឺ អស់រយៈពេល៤ឬ៥ថ្ងៃ ខ្ញុំបានដើររកឈ្មោះ វៀង និងសំណាង មិនឃើញ ពេលដើរមកដល់រោងចក្រតម្បាញនៅអមលាំង។ ខ្ញុំត្រូវអង្គការចាប់ខ្លួននៅខែវិច្ឆិកា ឆ្នាំ១៩៧៧។

កំណត់ចំណាំ៖ អត្ថបទនេះដកស្រង់ចេញពីចម្លើយសារភាពឯកសារJ00៤៨៧។ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំ និងធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះយើងមិនអាចសន្និដ្ឋានបានថាចម្លើយសារភាពរបស់ អៀង ដុងខេង ហៅ សំឡេង ពិតប្រាកដយ៉ាងណានោះទេ?

ទាហាន លន់ នល់ នៅបន្ទាយព្រះកែវមរកត ក្នុងក្រុងភ្នំពេញ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



# ឯកអគ្គរដ្ឋទូតសហព័ន្ធរុស្ស៊ីប្រចាំនៅកម្ពុជា លោក អាណាតូលី បូរ៉ូវីក

## មកទស្សនកិច្ចបណ្ណាល័យសម្ដេចម៉ៃ

*សោម ប៊ុនថន*



នៅព្រឹកថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៣ ឯកអគ្គរដ្ឋទូតសហព័ន្ធរុស្ស៊ីប្រចាំនៅប្រទេសកម្ពុជា លោក អាណាតូលី បូរ៉ូវីក (ANATOLY BOROVIK) អមដំណើរដោយលេខាអ្នកស្រី សូហ៊ីយ៉ា អូបូស្កៃ (SOFIA OBORSKAIA) និងពិធីការផ្ទាល់របស់លោក មកទស្សនកិច្ចបណ្ណាល័យសម្ដេចម៉ៃនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដោយមានការទទួលស្វាគមន៍ពីលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅព្រឹកថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៣ ឯកអគ្គរដ្ឋទូតសហព័ន្ធរុស្ស៊ីប្រចាំនៅប្រទេសកម្ពុជា លោក អាណាតូលី បូរ៉ូវីក (ANATOLY BOROVIK) អមដំណើរដោយលេខាអ្នកស្រី សូហ៊ីយ៉ា អូបូស្កៃ (SOFIA OBORSKAIA) និងពិធីការផ្ទាល់របស់លោក មកទស្សនកិច្ចបណ្ណាល័យសម្ដេចម៉ៃនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដោយមានការទទួលស្វាគមន៍ពីលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា។

នៅក្នុងឱកាសនៃដំណើរទស្សនកិច្ចនេះ ឯកអគ្គរដ្ឋទូតសហព័ន្ធរុស្ស៊ីប្រចាំនៅប្រទេសកម្ពុជា លោក អាណាតូលី បូរ៉ូវីក បានប្រគល់រូបថតជាប្រវត្តិសាស្ត្រចំនួន៩សន្លឹកដល់លោក ឆាំង យុ ដើម្បីប្រើប្រាស់ជាឯកសារនៅបណ្ណាល័យសម្ដេចម៉ៃ។ រូបថតដែល

ជាអំណោយទាំងនេះ គឺជាព្រះឆាយាលក្ខណ៍របស់សម្តេចព្រះនរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ ជាមួយសម្តេចព្រះរាជអគ្គមហេសី នរោត្តម មុនិនាថ សីហនុ ក្នុងអំឡុងពេលព្រះអង្គយាងបំពេញព្រះរាជទស្សកិច្ចទៅកាន់ប្រទេសរុស្ស៊ីក្នុងឆ្នាំ១៩៦០ និងបានជួបសោយក្រយាពេលព្រឹក ជាមួយលោក លីអូនីត ប្រេសនេវ (LEONID BREZNHEV) ប្រធានគណៈប្រធានជាន់ខ្ពស់នៃសហភាពសូវៀត ព្រមទាំងរូបភាពក្នុងពិធីបើកការដ្ឋានសាងសង់មន្ទីរពេទ្យមិត្តភាពខ្មែរសូវៀត នៅឆ្នាំ១៩៥៨ និងរូបភាពដទៃទៀតដែលពិពណ៌នាអំពីទំនាក់ទំនងរវាងប្រទេសទាំងពីរ។

នៅក្នុងកិច្ចពិភាក្សាជាមួយលោក លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ឯកអគ្គរដ្ឋទូតសហព័ន្ធរុស្ស៊ីប្រចាំនៅប្រទេសកម្ពុជា លោក អាណាតូលី បូរ៉ូវីក បានគាំទ្រដល់កិច្ចការរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងការប្រមូលចងក្រងឯកសារ និងបង្រៀនអំពីប្រវត្តិសាស្រ្តនៃរបបកម្ពុជាប្រជាធិបតេយ្យ ដើម្បីទប់ស្កាត់កុំឲ្យរបបនេះកើតឡើងម្តងទៀត។ លោកក៏បានសម្តែងនូវការពេញចិត្តចំពោះការចុះទៅជួបសម្ភាសន៍ និងពិនិត្យសុខភាពជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅទូទាំងប្រទេសកម្ពុជា ដែលកិច្ចការនេះបានជួយដល់អ្នករស់រានទាំងនោះ។



នៅព្រឹកថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៣ ឯកអគ្គរដ្ឋទូតសហព័ន្ធរុស្ស៊ីប្រចាំនៅប្រទេសកម្ពុជា លោក អាណាតូលី បូរ៉ូវីក (ANATOLY BOROVIK) អមដំណើរដោយលេខាអ្នកស្រី សូហ្វីយ៉ា អូបូស្គៃ (SOFIA OBORSKAIA) និងពិធីការផ្ទាល់របស់លោក មកទស្សនកិច្ចបណ្ណាល័យសម្តេចម៉ែនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដោយមានការទទួលស្វាគមន៍ពីលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅឱកាសនេះដែរ ឯកអគ្គរដ្ឋទូតសហព័ន្ធរុស្ស៊ីប្រចាំនៅប្រទេសកម្ពុជា លោក អាណាតូលី បូរ៉ូវីក បានរំឭកថា នៅក្នុងឆ្នាំ២០២៣នេះ គឺជាខួបលើកទី៤០ នៃការបាត់បង់ជនជាតិរុស្ស៊ីចំនួន៧រូប ដែលត្រូវបានខ្មែរក្រហមសម្លាប់នៅ ខែសីហា ឆ្នាំ១៩៨៣ នៅក្នុងខេត្តកំពង់ចាម។ លោកក៏ចង់ឲ្យមានការរំឭកទៅដល់ជនជាតិរុស្ស៊ីដែលបានពលីនៅក្នុងប្រទេសកម្ពុជាទាំងនោះដែរ។









នៅព្រឹកថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៣ ឯកអគ្គរដ្ឋទូតសហព័ន្ធរុស្ស៊ីប្រចាំនៅប្រទេសកម្ពុជា លោក អាណាតូលី បូរ៉ូវីក (ANATOLY BOROVIK) អមដំណើរដោយលេខាអ្នកស្រី សូហ៊ីយ៉ា អូបូស្គៃ (SOFIA OBORSKAIA) និងពិធីការផ្ទាល់របស់លោក មកទស្សនកិច្ចបណ្ណាល័យសម្តេចម៉ែនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដោយមានការទទួលស្វាគមន៍ពីលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



នៅចុងបញ្ចប់ដំណើរទស្សនកិច្ច លោកឯកអគ្គរដ្ឋទូតថ្លែងថា លោកបានតាមដានកិច្ចការ បណ្ណាល័យសម្តេចម៉ែ និង មជ្ឈមណ្ឌលឯកសារកម្ពុជា កន្លងមក ហើយឃើញមានការរីកចម្រើនគួរឲ្យកត់សម្គាល់ ដែលក្នុងនោះរួមមានទាំងការពង្រីកសាខារបស់មជ្ឈមណ្ឌលឯកសារ កម្ពុជា ទៅកាន់ខេត្តទាំង៥ ដែលរួមមាន ខេត្តកំពង់ចាម, ខេត្តតាកែវ, ខេត្តត្បូងឃ្មុំ, ខេត្តព្រៃវែង និងខេត្តឧត្តរមានជ័យ។ ជាការឆ្លើយតបលោក ឆាំង យុ ស្នើឲ្យលោកឯកអគ្គរដ្ឋទូតផ្តល់ព័ត៌មានលម្អិតអំពីជនជាតិរុស្ស៊ី ដែលបានស្លាប់នៅខេត្តកំពង់ចាម ដើម្បីឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជាស្រាវជ្រាវបន្ថែម និងចែករំលែកប្រវត្តិសាស្ត្រដល់សិស្សានុសិស្ស។ រួមជាមួយនេះដែរ លោក ឆាំង យុ អញ្ជើញឯកអគ្គរដ្ឋទូតសហព័ន្ធរុស្ស៊ីទៅធ្វើទស្សនកិច្ចនៅមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម និងទីតាំងផ្ទាល់ដែលជនជាតិរុស្ស៊ីទាំង៧រូបបានស្លាប់បាត់បង់ជីវិតក្នុងឆ្នាំ១៩៨៣ទៀតផង។



# ការជំរុញទឹកចិត្តចំពោះអ្នកស្ម័គ្រចិត្តកម្ពុជា

***លីម អ៊ិកឹង***



គឹម សុវណ្ណដានី (រូបអង្គុយខាងឆ្វេង) អ្នកសម្របសម្រួលគម្រោង «ការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» ជាមួយអ្នកស្ម័គ្រចិត្តកម្ពុជានៃមជ្ឈមណ្ឌលឯកសារកម្ពុជា នៅភូមិបាក់នឹម ធ្វើការពិនិត្យសុខភាពបឋមសម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ការងារស្ម័គ្រចិត្តគឺជាទង្វើនៃការលះបង់ដើម្បីបម្រើដោយមិនគិតតែពីខ្លួនឯង ដែលតម្រូវឲ្យមានគោលការណ៍ជាក់លាក់ និងតម្លៃ។ គោលការណ៍ស្នូលមួយចំនួនដែលមានសារសំខាន់សម្រាប់អ្នកស្ម័គ្រចិត្តរួមមានការតាំងចិត្ត ការអាណិតអាសូរ ការគោរព និងការសហការ។

អ្នកស្ម័គ្រចិត្តគួរតែប្ដេជ្ញាចិត្តចំពោះបុព្វហេតុដែលខ្លួនកំពុងបម្រើ ហើយមានឆន្ទៈលះបង់ពេលវេលា និងកម្លាំង ដើម្បីធ្វើការផ្លាស់ប្ដូរឲ្យល្អប្រសើរជាងមុន។ អ្នកស្ម័គ្រចិត្តក៏គួរមានការយល់ដឹងឲ្យបានច្រើន និងមានបំណងចង់ជួយអ្នកដទៃដោយមិនរំពឹងថានឹងទទួលបានរង្វាន់ ឬការទទួលស្គាល់អ្វីឡើយ។ លើសពីនេះ អ្នកស្ម័គ្រចិត្តគួរតែគោរពមនុស្សដែលខ្លួនកំពុងធ្វើការជាមួយ និងសហគមន៍ដែលខ្លួនកំពុងបម្រើ ដោយគិតគូរពីភាពខុសគ្នាដែលខ្លួនជួបប្រទះ និងប្រព្រឹត្តចំពោះមនុស្សគ្រប់គ្នាដោយសេចក្ដីថ្លៃថ្នូរ និងសប្បុរស។

ជាចុងក្រោយ ដើម្បីធ្វើការងារឲ្យមានប្រសិទ្ធភាព អ្នកស្ម័គ្រចិត្តត្រូវយល់ពីសារសំខាន់នៃកិច្ចសហការ និងការងារជាក្រុម ហើយខិតខំធ្វើការរួមគ្នាជាមួយអ្នកដទៃ ដើម្បីសម្រេចបាននូវគោលដៅរួម។

# ដំឡូងឈើនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ដោយ អែម ឆាត

**ឆាំង យុ**



ដំឡូងឈើដែល អែម ឆាត ដាំនៅមជ្ឈមណ្ឌលឯកសារកម្ពុជា។ (ឆាំង យុ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

អែម ឆាត គឺជាអ្នកសម្អាតការិយាល័យ ចុងភៅ និងជាម្តាយរបស់បុគ្គលិកទាំងអស់គ្នានៅមជ្ឈមណ្ឌលឯកសារកម្ពុជា តាំងពីឆ្នាំ ១៩៩៥។ គាត់បានបាត់បង់សាច់ញាតិជាច្រើននាក់ក្នុងរបបខ្មែរក្រហម។ ខណៈពេលដែលយើងទាំងអស់គ្នាដាំផ្កាលម្អនៅក្នុងសួនច្បារ គាត់បានសម្រេចចិត្តដាំដំឡូងឈើដ៏ស្រស់ស្អាតជំនួសវិញ។ ដំឡូងឈើរំឭកគាត់ ហើយប្រហែលជារំឭកអ្នករស់រានមានជីវិតទាំងអស់ អំពីជីវិតនៅក្នុងរបបខ្មែរក្រហមរវាងឆ្នាំ១៩៧៥-១៩៧៩។

អែម ឆាត បានពន្យល់ប្រាប់យើងថា វាគឺជារឿងធម្មតាណាស់ដែលមនុស្សលួចដំឡូងឈើក្នុងរបបខ្មែរក្រហម។ មនុស្សស្រេកឃ្លាន ហើយការរស់ជីវិត និងមនុស្សជាទីស្រឡាញ់របស់ខ្លួនឯងបានជំនួសអ្វីៗផ្សេងទៀត រួមទាំងសីលធម៌។ មនុស្សនឹងកុហក លួច និងលាក់របស់ពីគ្នាទៅវិញទៅមក ប្រសិនបើការធ្វើបែបនោះនឹងជួយសង្គ្រោះជីវិតខ្លួនឯង។ រយៈពេល ៤៤ឆ្នាំក្រោយមក កាលៈទេសៈនេះនៅតែបន្តលងបន្លាចដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមទាំងអស់ ហើយតាមមធ្យោបាយជាច្រើន រឿងរ៉ាវទាំងអស់នេះបានបន្ទឺឡើងនៅគ្រប់កម្រិតនៃសង្គមកម្ពុជា។ ដោយសារជីវិត គឺជាការតស៊ូពីមួយថ្ងៃទៅមួយថ្ងៃដើម្បីរស់ ការសម្រេចចិត្តកុហក បោកប្រាស់ និងការលួចចេញពីអារម្មណ៍របស់មនុស្សដែលនៅរស់រានមានជីវិតពីសង្គ្រាម ទំនួលខុសត្រូវចំពោះមនុស្សជាតិ និងទស្សនៈរួមលើមនុស្សជាតិ។

សម្រាប់អ្នករស់រានមានជីវិតជាច្រើន សំណួរកើតឡើងថា៖ តើមនុស្សម្នាក់ស្វែងរកការអភ័យទោសចំពោះទង្វើក្បត់ខាងលើនេះដោយរបៀបណា? អ្នករស់រានមានជីវិតជាច្រើនត្រូវបានទទួលរងភាពញាំញីដោយសំណួរនេះ ដែលជាការរំឭកប្រចាំថ្ងៃអំពីអ្វីដែលបានកើតឡើងក្នុងរបបខ្មែរក្រហម ហើយការដាំដំឡូងឈើសព្វថ្ងៃនេះ គឺជាសកម្មភាពដ៏កម្រ និងជានិមិត្តរូបនៃការចងចាំសម្រាប់សម័យកាលនេះ។

# បណ្ណាល័យសម្តេចម៉ែនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ប្រគល់អំណោយម៉ូតូកង់បីជូនដល់ប្រជាជននៅភូមិបាក់នឹម

**ផាត ចាន់សុនិតា**



ក្រុមការងារបណ្ណាល័យសម្តេចម៉ែនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ថតរូបជុំគ្នាជាមួយប្រជាជននៅភូមិបាក់នឹម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅក្នុងប្រទេសកម្ពុជាខែមេសា គឺជាខែមួយដែលមានអាកាសធាតុក្តៅ ហួតហែង។ ជារៀងរាល់ឆ្នាំប្រជាជនខ្មែរតែងតែប្រារព្ធពិធីបុណ្យចូលឆ្នាំប្រពៃណីជាតិរបស់ខ្លួន និងជួបជុំគ្រួសារបងប្អូនប្រកបដោយសេចក្តីសប្បាយរីករាយ។ ក្រលេកទៅមើលអតីតកាលវិញ អំពើប្រល័យពូជសាសន៍នៅប្រទេសអាល្លឺម៉ង់ បូស្នី- ហឺហ្សីហ្គោវីន រវ៉ាន់ដា និង កម្ពុជាតែងតែកើតឡើងនៅក្នុងខែមេសា។ ជាក់ស្តែង ខ្មែរក្រហមឡើងកាន់អំណាចនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងបានបណ្តាលឲ្យប្រជាជនកម្ពុជាប្រមាណជាង២លាននាក់ស្លាប់បាត់បង់ជីវិត។ នៅក្នុងខែមេសានេះ អង្គការសហប្រជាជាតិ និងប្រទេសមួយចំនួនប្រារព្ធទិវារំឭកការចងចាំអំពីអំពើប្រល័យពូជសាសន៍ក្នុងគោលបំណងផ្សព្វផ្សាយ និងជំរុញឲ្យមានការចូលរួមការពារ និងទប់ស្កាត់នូវអំពើប្រល័យពូជសាសន៍។

នៅថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបចំកម្មវិធីប្រគល់ម៉ូតូកង់បីមួយគ្រឿង ដែលជាអំណោយរបស់បណ្ណាល័យសម្តេចម៉ែនៃមជ្ឈមណ្ឌលឯកសារកម្ពុជាជូនដល់ភូមិបាក់នឹមដែលមានប្រជាជនចំនួន

៨៦៨គ្រួសារ ស្ថិតនៅ ឃុំច្រេស ស្រុកជុំគិរី ខេត្តកំពត។ នៅក្នុងកម្មវិធីនេះមានការអញ្ជើញចូលរួមពីអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅក្នុងភូមិបាក់នឹម, អាជ្ញាធរមូលដ្ឋាន និង គណៈកម្មាធិការអាចារ្យវត្តបាក់នឹម សរុបចំនួន៣០នាក់។ គោលបំណងនៃការប្រគល់ជូនអំណោយម៉ូតូកង់បីទៅដល់ភូមិបាក់នឹម គឺសម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមរស់នៅភូមិបាក់នឹម ដែលស្ថិតនៅចម្ងាយជាង ២០គីឡូម៉ែត្រពីទីប្រជុំជន ប្រើប្រាស់ជាមធ្យោបាយធ្វើដំណើរដោយឥតគិតថ្លៃ ទៅកាន់មន្ទីរសម្រាកព្យាបាល ឬមណ្ឌលសុខភាព ព្រោះប្រជាជនរស់នៅភូមិបាក់នឹមភាគច្រើនជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមមានវ័យចំណាស់ មានជីវភាពខ្វះខាត និងមិនធ្លាប់បានទៅពិនិត្យសុខភាព ព្រោះតែខ្វះខាតថវិកា និងមធ្យោបាយធ្វើដំណើរ។ មួយវិញទៀត ដោយសារភូមិបាក់នឹមប៉ែកខាងជើង មានទីតាំងស្ថិតនៅឆ្ងាយដាច់ស្រយាលតាមបណ្តោយជើងភ្នំដំរីរមៀល។ ផ្លូវក្នុងភូមិមានសភាពនៅពិបាកក្នុងការធ្វើដំណើរ និងមិនទាន់មានភ្លើងអគ្គិសនី និងទឹកស្អាតគ្រប់គ្រាន់សម្រាប់ប្រើប្រាស់នៅឡើយ។

ជាកិច្ចចាប់ផ្តើមនៃកម្មវិធី ជាត ចាន់សុនិតា ប្រធានក្រុមអ្នកស្ម័គ្រចិត្តកម្ពុជាខេត្តកំពត មានមតិស្វាគមន៍ទៅកាន់អ្នកចូលរួម និង រៀបរាប់អំពីការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជានៅភូមិបាក់នឹមថា បច្ចុប្បន្នមានក្រុមអ្នកស្ម័គ្រចិត្តមជ្ឈមណ្ឌលឯកសារកម្ពុជានៅភូមិបាក់នឹមចំនួន ៦នាក់ បន្តចុះទៅជួបសួរសុខទុក្ខ និងសម្ភាសន៍អំពីរឿងរ៉ាវបទពិសោធន៍ឆ្លងកាត់របស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន ១៧០នាក់ នៅក្នុងភូមិបាក់នឹម។ ការធ្វើបទសម្ភាសន៍នេះ គឺដើម្បីយកទៅបោះពុម្ពផ្សព្វផ្សាយអប់រំពីអំពើប្រល័យពូជសាសន៍ និងការសម្លាប់រង្គាលនៅអំឡុងរបបខ្មែរក្រហម។

នៅក្នុងខែមីនា ឆ្នាំ២០២៣ កន្លងមក ក្រុមការងារគម្រោង «ការលើកកម្ពស់សិទ្ធិ និង ការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិត







ប្រជាជននៅភូមិបាក់នឹមចូលរួមពិធីទទួលអំណោយម៉ូតូកង់បី ពីក្រុមការងារបណ្ណាល័យសម្តេចម៉ែនៃមជ្ឈមណ្ឌលឯកសារកម្ពុជា សម្រាប់ប្រើប្រាស់នៅក្នុងសហគមន៍។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ពីរបបខ្មែរក្រហម» នៃមជ្ឈមណ្ឌលឯកសារកម្ពុជា បានចុះមកពិនិត្យសុខភាពបឋមដូចជា ពិនិត្យចង្វាក់បេះដូង វាស់សំពាធឈាម ពិនិត្យជាតិខ្លាញ់ ជាតិស្ករ ផ្តល់ប្រឹក្សាយោបល់ដោយវេជ្ជបណ្ឌិតជនជាតិហ្វីលីពីនដេមីរៃយ៍ និង ចែកកញ្ចប់អនុស្សាវរីយ៍ជូន

ដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមរស់នៅក្នុងភូមិបាក់នឹមចំនួនពីរលើករួចមក ដោយមានអ្នកចូលរួមចំនួន ៨៤នាក់។ ក្នុងខែឧសភា ខាងមុខនេះក្រុមការងារមានគម្រោងចុះមកពិនិត្យសុខភាពជាបន្តបន្ទាប់ ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមផ្សេងទៀតដែលនៅសេសសល់ក្នុងភូមិបាក់នឹម។

ជាកិច្ចបន្ទាប់លោក សុខ វណ្ណៈ បុគ្គលិកមជ្ឈ-មណ្ឌលឯកសារកម្ពុជាបានប្រគល់ម៉ូតូកង់បីជូនដល់លោក ពយ អ៊ួច មេភូមិបាក់នឹម និងជាតំណាងឲ្យប្រជាពលរដ្ឋចំនួន៤៣៦គ្រួសារ និងប្រជាជនសរុប១៨៩១នាក់។

លោក ពយ អ៊ួច បង្ហាញពីចំណាប់អារម្មណ៍របស់ខ្លួនថា « ខ្ញុំសប្បាយរីករាយណាស់ ដែលលោកនាយក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាយកចិត្តទុកដាក់ជួយ និងប្រគល់ម៉ូតូកង់បីជូនដល់ភូមិបាក់នឹម ដោយឃើញថាបងប្អូនអ្នករស់រានមានជីវិតពីសង្គ្រាម និងរបប ប៉ុល ពត រស់នៅតំបន់ដាច់ស្រយាលឆ្ងាយពីមន្ទីរពេទ្យ និងទីប្រជុំជននានា។ ខ្ញុំសូមមានសំណើរពីរចំណុចទៀតបន្ថែមទៅលើការប្រើប្រាស់ម៉ូតូកង់បី សម្រាប់ជាមធ្យោបាយជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមទៅកាន់មណ្ឌលសុខភាព ឬមន្ទីរសម្រាកព្យាបាល គឺ៖ សំណើរទី១) ក្នុងករណីមានបងប្អូនប្រជាជនឈឺថ្កាត់បន្ទាន់ឬស្ត្រីឆ្លងទន្លេ ត្រូវទៅមន្ទីរពេទ្យសូមឲ្យគាត់អាចប្រើប្រាស់ម៉ូតូកង់បីនេះសម្រាប់ជាមធ្យោបាយធ្វើដំណើរ ទី២) ប្រសិនបើមានអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលចង់ធ្វើបុណ្យទាននៅតាមវត្ត សូមអនុញ្ញាតឲ្យគាត់ប្រើប្រាស់ម៉ូតូកង់បីជាមធ្យោបាយធ្វើដំណើរ ព្រោះអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមមិនធ្លាប់បានធ្វើបុណ្យទានពីមុនមកទេ ទើបតែសម័យសន្តិភាពនេះមានឱកាសធ្វើបុណ្យទាន»។

នៅចុងបញ្ចប់ ក្រុមការងារចែកអាហារ កញ្ចប់អនុស្សាវរីយ៍ និងមធ្យោបាយធ្វើដំណើរជូនដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលបានមកចូលរួមក្នុងកម្មវិធី។







ប្រជាជននៅភូមិបាក់នឹមចូលរួមពិធីទទួលអំណោយម៉ូតូកង់បីពីក្រុមការងារបណ្ណាល័យសម្តេចម៉ែនៃមជ្ឈមណ្ឌលឯកសារកម្ពុជាសម្រាប់ប្រើប្រាស់នៅក្នុងសហគមន៍។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# រឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចេញពីភូមិបាក់នឹម

ផាត ចាន់សុនិតា

ភូមិបាក់នឹមមានទីតាំងស្ថិតនៅតាមបណ្តោយជួរភ្នំដំរីរមៀល ព្រំប្រទល់ខេត្តតាកែវ និងកំពត។ ដោយសារកត្តាភូមិសាស្ត្រតំបន់ជួរភ្នំដំរីរមៀល និងតំបន់តាកែនកោះស្លា សំបូរដោយព្រៃឈើក្រាស់ៗ បន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ក្រុមខ្ទាមខ្មែរក្រហមដែលនៅសេសសល់បានប្រមូលផ្តុំ និងលាក់ខ្លួននៅក្នុងព្រៃក្នុងភូមិសាស្ត្រភូមិបាក់នឹមជាប់នឹងជួរភ្នំដំរីរមៀល ដើម្បីបន្តធ្វើសង្គ្រាម ឈ្លបប្រឆាំងជាមួយរដ្ឋាភិបាលរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា។ ក្រុមខ្ទាមខ្មែរក្រហមនៅភូមិបាក់នឹម បានបង្កអសន្តិសុខតាមរយៈ ការវាយឆ្នក់ ដាក់ពង្រាយគ្រាប់មីន ប្លន់បាញ់សម្លាប់អ្នកដំណើរ វាយប្រហារទៅលើប៉ុស្តិ៍រដ្ឋបាលរបស់រដ្ឋាភិបាលរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា និងប្រជាជននៅក្នុងភូមិជាដើម។ ក្រោយពីមានកិច្ចព្រមព្រៀងទីក្រុងប៉ារីសឆ្នាំ១៩៩១ និងការបោះឆ្នោតថ្នាក់ជាតិនៅឆ្នាំ១៩៩៣ រដ្ឋាភិបាលបានបង្កើតនូវគោលនយោបាយ ឈ្នះ ឈ្នះ ដើម្បីបញ្ចប់សង្គ្រាមស៊ីវិលរ៉ាំរ៉ៃទាំងស្រុងនៅកម្ពុជា។ បន្ទាប់ពីរដ្ឋាភិបាលអនុវត្តគោលនយោបាយ ឈ្នះ ឈ្នះ ក្រុមខ្ទាមខ្មែរក្រហមនៅភូមិសាស្ត្រភូមិបាក់នឹមកាត់បន្ថយសកម្មភាពវាយប្រឆាំងជាមួយរាជរដ្ឋាភិបាលកម្ពុជា ប៉ុន្តែបានធ្វើការបែងចែកទីតាំងរដ្ឋបាលដើម្បីគ្រប់គ្រង។ ជាបន្តបន្ទាប់ក្រុមខ្ទាមខ្មែរក្រហមដែលនៅសេសសល់នៅភូមិ-សាស្ត្រ ភូមិបាក់នឹម បានយល់ព្រមចូលមកសារភាពរួមរស់ជាមួយរាជរដ្ឋាភិបាលកម្ពុជា និងបានធ្វើសមា-ហរណកម្មចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជាទាំងស្រុងនៅអំឡុងឆ្នាំ១៩៩៨។ ចាប់ពីពេលនោះហើយ ទើបប្រជាជននៅភូមិបាក់នឹមមានសុខសន្តិភាពរហូតមកដល់សព្វថ្ងៃ។

ខាងក្រោមនេះ គឺជាបទសម្ភាសន៍ទាក់ទងនឹងបទពិសោធន៍ជីវិតរបស់អតីតកងទ័ព និងប្រជាជនដែលនៅរស់រានមានជីវិតពីរបបខ្មែរក្រហមរស់នៅភូមិបាក់នឹម ៖

## ១) ពយ អ៊ូច



ពយ អ៊ូច ភេទប្រុស អាយុ៦៤ឆ្នាំ បច្ចុប្បន្នមានតួនាទីគឺជាប្រធានភូមបាក់នឹម ឃុំប្រេស ស្រុកជុំគិរី ខេត្តកំពត។ គាត់បានរៀបរាប់ថា ខ្ញុំមានស្រុកកំណើតនៅភូមិព្រៃស្បូវ ឃុំនារាយ៍ ស្រុកឈូក និងបានផ្លាស់ទីលំនៅមករស់នៅភូមិបាក់នឹមក្នុងឆ្នាំ១៩៩៧។ ពេលខ្ញុំមករស់នៅទីនេះដំបូង មានប្រជាជន ១០ទៅ ២០គ្រួសារប៉ុណ្ណោះ។ បន្ទាប់ពីឆ្នាំ១៩៧៩ កងទ័ពខ្មែរក្រហមរស់នៅរាយប៉ាយមួយក្រុមៗមានគ្នាប្អូនទៅប្រាំនាក់នៅតាមបណ្តោយជួរភ្នំដំរីរមៀល។ ប្រជាជនរស់នៅតាមភូមិអំឡុងពេលនោះមានជីវភាពខ្វះខាត

បានចូលព្រៃដើម្បីកាប់ឈើ និងប្រូតស្បូវលក់ៗ ដើម្បីអាស្រ័យផលព្រៃឈើដែលស្ថិតក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម ប្រជាជនបានលួចយកស្បៀងអាហារទៅឧបត្ថម្ភដល់ខ្មែរក្រហមរស់នៅលាក់ខ្លួនក្នុងព្រៃ។ ប្រធានកងវរសេនាធំរបស់ខ្មែរក្រហមគ្រប់គ្រងនៅភ្នំដំរីរមៀលឈ្មោះ ឡុង ឆាន់ដែលមានមូលដ្ឋាននៅតំបន់តាកែនកោះស្លា។ ថ្ងៃមួយពាក់កណ្តាលឆ្នាំ១៩៩៨ ឡុង ឆាន់បានបញ្ជូមកកងទ័ពខ្មែរក្រហមទាំងយប់ឲ្យចុះចូលជាមួយរាជរដ្ឋាភិ-បាល។ ពេលនោះទាហានខ្មែរក្រហមទាំងអស់បាននាំគ្នាចុះពីលើភ្នំទៅសារភាពសុំចុះចូលនៅស្រុកឈូក។

## ២) សំ ណុំ




សំ ណុំ ភេទប្រុស អាយុ ៦៣ឆ្នាំ មានស្រុកកំណើតនៅស្រុកទ្រាំង ខេត្តតាកែវ។ គាត់បានរំឭកអំពីរឿងរ៉ាវចងចាំមិនភ្លេចពីសម័យខ្មែរក្រហមថា ក្រោយពីខ្មែរក្រហមឡើងកាន់អំណាចនៅឆ្នាំ១៩៧៥ ខ្ញុំត្រូវអង្គការចាត់ឲ្យធ្វើការនៅកងចល័ត។ ថ្ងៃមួយខ្ញុំមានជម្លោះជាមួយអ្នកធ្វើការក្នុងក្រុម។ ប្រធានកងចល័តបានបញ្ជូឲ្យខ្ញុំជីករណ្តៅ បន្ទាប់ពីខ្ញុំជីករួចប្រធានកងនោះបានប្រាប់ខ្ញុំទម្លាក់ចូលរណ្តៅ និងកប់ខ្ញុំត្រឹមក។ មិត្តភក្តិរបស់ខ្ញុំម្នាក់បានរត់យកដំណឹងនេះទៅប្រាប់ឪពុករបស់ខ្ញុំដែលធ្វើការនៅខាងសេដ្ឋកិច្ចតំបន់១០៧។ គ្រាន់តែដឹងរឿងនេះភ្លាមឪពុករបស់ខ្ញុំបានដិះកង់មកជួយកាយដីយកខ្ញុំចេញពីរណ្តៅ និងទះកំភ្លៀងប្រធានកងនោះ ព្រមទាំងគំរាមយកប្រធានកងនោះទៅសម្លាប់ចោល។ ក្រោយមកនៅឆ្នាំ១៩៧៨ ខ្មែរក្រហមបានចាត់ខ្ញុំឲ្យទៅធ្វើកងទ័ពច្បាំងជាមួយវៀតណាម។ អំឡុងពេលច្បាំងគ្នា ខ្ញុំត្រូវអត់បាយ ព្រោះកងទ័ពវៀតណាមបានវាយផ្តាច់មិនឲ្យអ្នកជញ្ជូនស្បៀងអាហារចូលដល់សមរភូមិមុខ។ កងទ័ពណាដែលរត់ចោលជួរ ឬដកថយមកសមរភូមិក្រោយ នឹងត្រូវខ្មែរក្រហមចាប់យកទៅដាក់គុកភ្នំសន្ទុង ក្នុងស្រុកគិរីវង់ ខេត្តតាកែវ។ ពេលវៀតណាមវាយចូលមកខ្លាំង ខ្ញុំបានរត់គេចខ្លួនឡើងលើភ្នំ។ ពេលរស់នៅលើភ្នំពុំមានអាហារសម្រាប់ហូបនោះទេ ខ្ញុំត្រូវជីកមើមក្តួចត្រាំទឹករយៈពេលបួនទៅប្រាំថ្ងៃទើបអាចហូបបាន។ ក្រោយមក ខ្ញុំបានចុះពីលើភ្នំមកបន្លំខ្លួនជាមួយប្រជាជនរកស៊ីលក់ប្រហុក។ ថ្ងៃមួយកងទ័ពវៀតណាមឃើញស្បែកជើងកង់ឡានខ្ញុំពាក់ក៏ដឹងភ្លាមថា ខ្ញុំគឺជាកងទ័ពខ្មែរក្រហម ទោះបីខ្ញុំបានយកស្បែកជើងនោះទៅជ្រលក់ជាមួយភក់ដើម្បីកុំឲ្យកងទ័ពវៀតណាមចំណាំក៏ដោយ។ កងទ័ពវៀតណាមបានចាប់ខ្លួនខ្ញុំយកទៅសួរនាំ។ បន្ទាប់ពីសួរនាំរួច កងទ័ពវៀតណាមបានឲ្យបាយខ្ញុំហូបមួយចម្អែត រួចហើយជូនខ្ញុំទៅស្រុកកំណើតជួបជុំឪពុកម្តាយនៅខេត្តតាកែវវិញ។

បន្ទាប់ពីឆ្នាំ១៩៧៩ ខ្ញុំចូលរៀនអក្សរនៅសាលា ហើយក៏ឈប់រៀនវិញ ដោយសារជីវភាពខ្វះខាត។ នៅឆ្នាំ១៩៨៦ ខ្ញុំចូលធ្វើទាហានវរ៨១ នៅខេត្តតាកែវ និងបានទៅហ្វឹកហាត់នៅភ្នំពេញ។ ក្រោយពីរៀនចប់ខ្ញុំត្រូវចាត់ឲ្យទៅនៅកងពលលេខ៨។ ពេលនោះ ខ្ញុំទៅច្បាំងជាមួយខ្មែរក្រហមនៅតំបន់បរ ឡាង ខេត្តប៉ៃលិន។ ខ្ញុំនៅប៉ៃលិន និងឈរជើងជាមួយកងទ័ពវៀតណាមរយៈពេល៣ឆ្នាំច្បាំងជាមួយខ្មែរក្រហម។ នៅឆ្នាំ១៩៨៩ មានកិច្ចព្រមព្រៀងឲ្យវៀតណាមដកទ័ពចេញពីកម្ពុជា។ ពេលភាគីវៀតណាមដកកម្លាំងទ័ពចេញទៅវិញ ខាងភាគីខ្មែរក្រហមបានវាយចូលមកកៀកក្រុងបាត់ដំបង។ ពេលនោះ ខាងភាគីរដ្ឋកម្ពុជាបានប្រមូលកងទ័ពមកពីគ្រប់តំបន់រួមទាំងភ្នំពេញដើម្បីទៅទប់ទល់ជាមួយកងទ័ពខ្មែរក្រហម នៅបាត់ដំបង ប៉ៃលិន កោះកុង និងថ្មដាពោធិ៍សាត់។

ក្រោយមក នៅឆ្នាំ១៩៩៦ តាមរយៈគោលនយោបាយឈ្នះ ឈ្នះ ក្រុមឧទ្ទាមខ្មែរក្រហមនៅតំបន់ទឹករ៉ាល់ក្នុងខេត្តកំពង់ស្ពឺ ស្ថិតក្រោមការគ្រប់គ្រងរបស់ កែវ ពង់ បានធ្វើសមាហរណកម្មចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជា។ ពេលនោះ ទាហានខ្មែរក្រហមដែលស្ថិតក្រោមការគ្រប់គ្រងរបស់ សំ ប៊ិត ដែលមានមូលដ្ឋានធំនៅតំបន់គាកែនកោះស្លា បានបញ្ជូនមកមេខ្មែរក្រហមនៅភ្នំដំរីរមៀលឲ្យធ្វើសមាហរណកម្មចុះចូលជាមួយរាជរដ្ឋាភិបាល។ កម្មវិធីនៃការចុះចូលធ្វើនៅខេត្តកំពត។ ក្រោយមក ខ្ញុំក៏បានមករស់នៅភូមិបាក់នឹម ដោយតួនាទីជាវរសេនីយ៍ឯក។ ខ្ញុំទើបតែចូលនិវត្តន៍នាឆ្នាំ២០២១នេះ។ សព្វថ្ងៃខ្ញុំនៅផ្ទះប្រកបរបរធ្វើស្រែចម្ការដំណាំនៅផ្ទះ។

## ៣) ឌុច ទុង



ឌុច វុង ភេទប្រុស អាយុ៦៦ឆ្នាំ បច្ចុប្បន្នរស់នៅភូមិបាក់នឹម ឃុំប្រេស ស្រុកជុំគិរី ខេត្តកំពត។ គាត់រៀបរាប់ពីរឿងរ៉ាវអតីតកាលរបស់ខ្លួនថា ខ្ញុំចូលបដិវត្តន៍ខ្មែរក្រហមនៅស្រុកឈូក តំបន់៣៥ ភូមិភាគនិរតី ក្នុងឆ្នាំ១៩៧៤។ ខ្ញុំវាយជាមួយទាហានលន់ នល់ នៅក្រុងកំពត។ បន្ទាប់ពីខ្មែរក្រហមឡើងកាន់អំណាចនៅឆ្នាំ១៩៧៥ ខ្ញុំត្រូវអង្គការចាត់តាំងឲ្យទៅឈរជើងនៅតាមព្រំដែនវៀតណាមម្តុំទូកមាស។ នៅឆ្នាំ១៩៧៧ និង ឆ្នាំ១៩៧៨ ខ្ញុំទៅវាយជាមួយវៀតណាមនៅប្រកតន់ហាន់។ អំឡុងពេលច្បាំងគ្នាជាមួយវៀតណាមកងទ័ពខ្មែរក្រហមស្លាប់និងរបួសជាច្រើន។ ខ្ញុំវាយនៅតាមសមរភូមិបានពីរដងប៉ុណ្ណោះ ក្នុងឆ្នាំ១៩៧៧ ខ្ញុំត្រូវគ្រាប់ផ្ទុះក្តៅ និងបានវះកាត់យកគ្រាប់ចេញ៧ដង។ ខ្ញុំសម្រាកព្យាបាលនៅមន្ទីរពេទ្យកំពត និងតាកែវអស់រយៈពេល២ឆ្នាំ។ ពេលដែលកងទ័ពវៀតណាមវាយចូលមក ខ្មែរក្រហមក៏ដឹកខ្ញុំពីមន្ទីរពេទ្យទៅ ទុកនៅ ស្ទឹងកេ។ ខ្ញុំបានរត់ឡើងភ្នំ និងបន្តដំណើររហូតទៅដល់គិរីរម្យ។ រយៈពេលពីរទៅបីអាទិត្យទើបខ្ញុំត្រឡប់មកស្រុកកំណើតវិញទាំងយប់ ដោយមានស្ពាយកាំភ្លើងជាប់នឹងខ្លួនមកជាមួយ។ ខ្ញុំមកដល់ផ្ទះវិញក្នុងខែកុម្ភៈ ឆ្នាំ១៩៧៩ ពេលមកដល់ភ្លាមឪពុករបស់ខ្ញុំបាននាំខ្ញុំទៅជួបនិងរាយការណ៍ប្រាប់ឈ្លបភូមិ។ នៅខែកក្កដា ឆ្នាំ១៩៧៩ ខ្ញុំបានរៀបការជាមួយប្រពន្ធរបស់ខ្ញុំជាអតីតកងនារីកាត់ដេរក្នុងរបបខ្មែរក្រហម។

បន្ទាប់ពីរៀបការរួចខ្ញុំរស់នៅភូមិត្នារ ឃុំក្រាំងស្នាយ ស្រុកឈូក ខេត្តកំពត និងមានតួនាទីជាសេនាជនភូមិ។ នៅយប់មួយ ខ្ញុំប្រឡំបាញ់សម្លាប់ប្អូនជីដូនមួយម្នាក់ ដោយស្មានថាជាទាហានខ្មែរក្រហម ព្រោះជំនាន់នោះក្រុមឧទ្ទាមខ្មែរក្រហមនៅរាយប៉ាយក្នុងភូមិសាស្ត្រភូមិបាក់នឹម និងស្រុកជុំគិរី មិនទាន់ចុះចូលនៅឡើយ។ ខ្ញុំមានវិប្បដិសារីយ៉ាងខ្លាំងចំពោះការភ័ន្តច្រឡំ និងកំហុសឆ្គងមួយនេះរហូតដល់ខ្ញុំឈប់ធ្វើជាសេនាជនភូមិ។ ដោយសារជីវភាពខ្វះខាត ខ្ញុំនិងប្រពន្ធក៏នាំគ្នាចាកចេញពីស្រុកភូមិទៅរស់នៅជំរំណងចាន់ចម្ការគភ្នំត្រែនិងសំពៅលូននៅតាមព្រំដែនខ្មែរថៃ។ នៅទីនោះខ្ញុំទទួលបានការឧបត្ថម្ភមានដូចជាអង្ករ ត្រីខមីកំប៉ុង និងខ្លាញ់ដើម្បីហូបប្រចាំថ្ងៃ។ នៅឆ្នាំ១៩៩៣ ខ្ញុំបានត្រឡប់មករស់នៅស្រុកកំណើតវិញ ដោយមានកាកបាទក្រហមជាអ្នកផ្គត់ផ្គង់ការរស់នៅអស់រយៈពេល៣ឆ្នាំ។ ក្រោយមករាជរដ្ឋាភិបាលឲ្យប្រជាជនដែលវិលត្រឡប់មកពីជំរំទៅចាប់ដីនៅល្បើកខាងជើងស្រុកឈូក ដើម្បីដាំដំណាំនិងសាងសង់ផ្ទះ។ ពេលខ្ញុំទៅដល់ទីនោះ ក៏ត្រូវក្រុមឧទ្ទាមខ្មែរក្រហមដេញបាញ់ ហើយខ្ញុំក៏លែងទៅកាន់ទីនោះទៀត។ បន្ទាប់ពីខ្ញុំមកដល់ផ្ទះវិញរយៈពេល២ឆ្នាំ រដ្ឋាភិបាលប្រកាសឲ្យទាហានខ្មែរក្រហមដែលនៅសេសសល់ចុះចូល ដោយមានទី

កន្លែងកំណើតនៅទីណា ត្រូវទៅរស់នៅទីនោះវិញៗ អំឡុងពេលនោះ ក្រុមខ្មាំងខ្មែរក្រហមនៅតំបន់កោះស្លា និងតំបន់ផ្សេងទៀតក៏ផ្តាច់ខ្លួនចុះចូលជាមួយរាជរដ្ឋាភិបាលៗ ខ្ញុំប្រកបមុខរបរធ្វើស្រែចម្ការចិញ្ចឹមជីវិតរហូតមកដល់សព្វថ្ងៃ។

## ៤) ម៉ៅ ឡឿន



ម៉ៅ ឡឿន អាយុ៦៩ឆ្នាំ មានស្រុកកំណើតនៅអ្នកលឿង ខេត្តព្រៃវែង បានរៀបរាប់ថា កាលពីកុមារ ខ្ញុំរៀនដល់ថ្នាក់ទី៧ សង្គមចាស់ៗ បន្ទាប់ពីព្រឹត្តិការណ៍ លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ប្រជាជនក៏ផ្ទុះបាតុកម្មប្រឆាំងនឹង លន់ នល់ ហើយខ្ញុំក៏ឈប់រៀនៗ បន្ទាប់មកខ្ញុំនិងគ្រួសារបានផ្លាស់ទៅរស់នៅស្រុកព្រះស្តេច និងបានចូលធ្វើកងទ័ពតំបន់ ២៤ៗ ពេលខ្ញុំចូលកងទ័ពដំបូង នៅធ្វើជានីរសាររត់សំបុត្រពីមន្ទីរយោធាទៅសមរភូមិៗ ប្រធានតំបន់២៤ ឈ្មោះ ឈូកៗ ពេលនោះ ខាងកងទ័ពខ្មែរក្រហមនៅភាគខាងកើតទន្លេមេគង្គ ចំណែកខាងទ័ព លន់ នល់ នៅភាគខាងលិចទន្លេមេគង្គៗ នៅឆ្នាំ១៩៧៥បន្ទាប់ពីខ្មែរក្រហមចូលកាន់អំណាច ខ្ញុំត្រូវបានអង្គការបញ្ជូនឲ្យទៅនៅខាង ឡូត៍នេសាទ ស្រុកព្រះស្តេច ដើម្បីរកត្រីផ្គត់ផ្គង់សហករណ៍ធ្វើប្រហុកផ្អកៗ នៅក្នុងអង្គភាពឡូត៍នេសាទមានសមាជិកប្រមាណ ២០នាក់ៗ ប្រជាជនធ្វើការនៅឡូត៍នេសាទមានអាហារហូបគ្រប់គ្រាន់ៗ នៅដើមខែមករា ឆ្នាំ១៩៧៩ ខ្ញុំឃើញប្រជាជននាំគ្នាជ្រួលច្របល់ទើបដឹងថាវៀតណាមវាយចូលមក ហើយខ្ញុំក៏ត្រឡប់មកស្រុកវិញៗ ពេលនោះប្រធានសហករណ៍បានដឹកនាំប្រជាជនរត់ពីស្រុកព្រះស្តេចរហូតទៅដល់ស្រុកពាមជរៗ បន្ទាប់មក ខ្ញុំក៏ត្រឡប់មកផ្ទះវិញ និងបានចូលបម្រើការងារជាយោធាឃុំ និងដើរប្រមូលប្រុសៗនៅក្នុងភូមិចូលធ្វើយោធាដើម្បីឡើងទៅវាយនៅសមរភូមិៗ ក្រោយមក ដោយសារខ្ញុំមិនអាចប្រមូលប្រុសៗនៅភូមិបាន ទើបខ្ញុំសម្រេចចិត្តទៅសមរភូមិខ្លួនឯងៗ បន្ទាប់ពីខ្ញុំហ្វឹកហាត់យោធានៅខេត្តព្រៃវែងរួច ខ្ញុំត្រូវបានបញ្ជូននៅក្នុងកងពលលេខ៤ៗ ខ្ញុំត្រូវចាត់ឲ្យទៅឈរជើងនៅ ស្រអែម ខេត្តព្រះវិហាររួចមកហ្វឹកហាត់ក្បួនយុទ្ធសាស្ត្រទ័ពបន្ថែមនៅភ្នំពេញៗ បន្ទាប់ពីហាត់រៀនចប់ ខ្ញុំផ្លាស់ទៅនៅកងពលលេខ៥ ឈរជើងនៅត្រែងត្រយឹង តាមផ្លូវជាតិលេខ៤ និងថ្មបាំងវិញៗ នៅឆ្នាំ២០០១ ខ្ញុំត្រូវផ្លាស់មកកងពលលេខ១១ និងរស់នៅបាក់នឹមរហូតមកដល់សព្វថ្ងៃ។

## ៥) សុខ ដេម



សុខ ដេម ភេទប្រុស អាយុ៧០ឆ្នាំ មានស្រុកកំណើតនៅភូមិអង្គជោត ឃុំចំប៉ី ស្រុកអង្គរជ័យ ខេត្តកំពតរៀបរាប់ថា កាលពីកុមារ ខ្ញុំរៀនដល់ថ្នាក់ទី៨ចាស់ នៅវត្តអង្គជោតៗ នៅឆ្នាំ១៩៧០ មានរដ្ឋប្រហារកើតឡើង ខ្ញុំក៏ឈប់រៀនៗ នៅឆ្នាំ១៩៧៣ កងទ័ពខ្មែរក្រហមវាយកាន់កាប់ទឹកដីនៅតាមស្រុកឈូក ស្រុកអង្គរជ័យ ស្ទើរតែទាំងស្រុងនៅសល់តែទីរួមខេត្តប៉ុណ្ណោះ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ទាហាន លន់ នល់ៗ ក្នុងឆ្នាំ១៩៧៤ ខ្មែរក្រហមបង្កើតក្រុមសាមគ្គីបង្កបង្កើនផលៗ ខ្ញុំរៀបការនៅឆ្នាំ១៩៧៣

និងផ្លាស់មករស់នៅខាងប្រពន្ធប្រកបរបរធ្វើស្រែចម្ការ នៅភូមិត្រពាំងឈើទាល ឃុំច្រេស ស្រុកជុំគិរី ដែលពីមុនស្ថិតក្នុងឃុំក្រាំងស្នាយ ស្រុកឈូក។ នៅពេលនោះស្រុកឈូកមានព្រំប្រទល់រហូតដល់ត្រពាំងអណ្តើក និងស្រុកកំពត។ ចំពោះស្រុកជុំគិរី និងស្រុកដងទង់ គឺទើបតែបំបែកចេញពីស្រុកឈូកក្រោយពីរបបខ្មែរក្រហម។ នៅក្នុងរបបខ្មែរក្រហម ខ្ញុំរស់នៅភូមិត្រពាំងឈើទាលនេះដដែលរហូតដល់ឆ្នាំ១៩៧៩ ទើបខ្ញុំជាមួយប្រជាជនផ្សេងទៀតរត់ទៅនៅខេត្តពោធិ៍សាត់រយៈពេល២ខែអស់ស្បៀង ទើបត្រឡប់មកស្រុកកំណើតវិញ។ នៅឆ្នាំ១៩៩៣ មានអ៊ុនតាក់ចូលមក។ ឆ្នាំ១៩៩៥ ខ្ញុំនិងអ្នកភូមិនាំគ្នាមកកាប់គាស់រុករានព្រៃធ្វើចម្ការ និងរស់នៅភូមិបាក់នឹម ឃុំច្រេស ជាមួយប្រពន្ធកូនរហូតមកដល់សព្វថ្ងៃ។

## ប្រាក់ សុខុម



អ៊ំស្រីឈ្មោះ ប្រាក់ សុខុម មានអាយុ៦៨ឆ្នាំ និងមានមុខរបរជាកសិករ។ កាលពីអ៊ំស្រីនៅក្មេង អ៊ំស្រីមិនបានរៀនសូត្រអ្វីទេ។ បន្ទាប់ពី ប្រទេសកម្ពុជារួចផុតពីអាណានិគមបារាំង អ៊ំស្រីបានចាប់ផ្តើមរៀនបន្តិច ដើម្បីអាចអាន និងសរសេរពាក្យខ្លះបាន។ ក្នុងរបបខ្មែរក្រហម អ៊ំស្រីត្រូវចាត់តាំងជាសមាជិកកងចល័តទៅជីកប្រឡាយរហូតតាមដែលអ៊ំស្រីអាចចងចាំបាន។ អ៊ំស្រីក៏ត្រូវបានចាត់ឲ្យជីកលាមកគោ និងកាប់ដើមទន្ទ្រានខេត្រ ដើម្បីធ្វើជី។ អ៊ំស្រីមិនចាំច្រើនទេ ដូច្នេះនេះជាអ្វីដែលអ៊ំស្រីអាចនិយាយបាន។ ខ្ញុំក្រោកឡើង ហើយឱបអ៊ំស្រីដែលជាអ្នកនៅរស់រានមានជីវិតពីរបបខ្មែរក្រហម ដោយមានអារម្មណ៍ដឹងគុណ និងការគោរព។ ខ្ញុំបានសម្តែងការកោតសរសើរចំពោះភាពក្លាហាន និងភាពស្មោះត្រង់របស់អ៊ំស្រី និងការអនុញ្ញាតឲ្យខ្ញុំ និងក្រុមការងារកត់ត្រារៀនសូត្រពីរឿងរ៉ាវរបស់អ៊ំស្រី។ ខ្ញុំបានប្រាប់អ៊ំស្រីថា អ៊ំស្រីជាមនុស្សមានសំណាងដែលបានរួចផុតពីភាពភ័យរន្ធត់ដែលមិនអាចនឹកស្មានដល់ ហើយអ៊ំស្រីនៅតែមានជំនឿ និងចិត្តសប្បុរស។ អ៊ំស្រីបាននិយាយថា អ៊ំស្រីសង្ឃឹមថារឿងរបស់អ៊ំស្រីនឹងអាចអប់រំអ្នកដទៃអំពីអំពើឃោរឃៅរបស់របបខ្មែរក្រហម និងការពារកុំឲ្យឧក្រិដ្ឋកម្មបែបនេះកើតឡើងម្តងទៀត។ ខ្ញុំអរគុណអ៊ំស្រីចំពោះការទទួលយ៉ាងរួសរាយរាក់ទាក់ និងការអនុញ្ញាតឲ្យខ្ញុំនិងក្រុមការងារបានធ្វើបទសម្ភាសន៍។

ក្រុមខ្ញុំអង្គុយលើកៅអីឈើទល់មុខលោកតា។ លោកតាស្វាគមន៍ខ្ញុំនិងក្រុមការងារដោយស្នាមញញឹមតិចៗ។ លោកតាបានឆ្លងកាត់ភាពរន្ធត់នៃរបបខ្មែរក្រហម ដែលបានសម្លាប់ប្រជាជនកម្ពុជាជិតមួយភាគបួននៃប្រជាជនកម្ពុជាក្នុងទសវត្សរ៍ឆ្នាំ ១៩៧០។ ផ្ទះឈើរបស់លោកតាមានលក្ខណៈសាមញ្ញ ប៉ុន្តែលោកតាហាក់ដូចជាពេញចិត្តនឹងអ្វីដែលគាត់មាន។ លោកតាបានយល់ព្រមចែករំលែករឿងផ្ទាល់ខ្លួនជាមួយខ្ញុំ ដោយសង្ឃឹមរឿងរ៉ាវរបស់គាត់នឹងជួយការពារកុំអោយមានអំពើឃោរឃៅបែបនេះកើតឡើងម្តងទៀត។ ខ្ញុំបានបើកឧបករណ៍ថតសំឡេងរបស់ខ្ញុំ ហើយសុំឲ្យលោកតាចាប់ផ្តើមពីដំបូង។ លោកតាដកដង្ហើមវែងៗ ហើយចាប់ផ្តើមនិយាយ។ ខាងក្រោមនេះជារឿងរ៉ាវរបស់លោកតា។

## ចាន់ ថាវ



ខ្ញុំឈ្មោះ ចាន់ ថាវ អាយុ ៥៨ឆ្នាំ។ ខ្ញុំជាជន

ពិការ។ ក្នុងរបបខ្មែរក្រហម ខ្ញុំមានអាយុ ១៥ ឆ្នាំ។ នៅឆ្នាំ ១៩៧៩ ខ្ញុំនៅជាមួយម្ដាយ និងបងប្អូនខ្ញុំតែប៉ុណ្ណោះ។ ខ្ញុំចាំថាខ្ញុំបានដើរលើភ្នំស្វែងរកអាហារ។ ខ្ញុំមិនចាំច្រើនទេ ព្រោះខ្ញុំនៅក្មេង ខ្ញុំរត់គេចខ្លួនពីសង្គ្រាមតាំងពីរបប លន់ នល់។ ពេលដែលមានការទម្លាក់គ្រាប់បែក ខ្ញុំគិតថាប្រហែលក្នុងកំឡុងទសវត្សរ៍ឆ្នាំ១៩៦០ ខ្ញុំរត់ពីស្រុកអង្គរជ័យរហូតដល់ម្ដេចនេះ។ កាលពីសម័យខ្មែរក្រហមខ្ញុំរស់នៅក្នុងសហករណ៍ យើងត្រូវហូបចុក និងធ្វើការជាមួយគ្នា។ ខ្ញុំប្រហែលជាអាយុ១២ឆ្នាំ ហើយខ្ញុំមិនបានរៀនសូត្រអ្វីទេព្រោះសាលាត្រូវបានបិទ។ បន្ទាប់មក នៅពេលខ្ញុំមានអាយុ ១៣ ឆ្នាំ ខ្ញុំត្រូវអង្គការចាត់តាំងឲ្យទៅកងកុមារ នៅឆ្នាំ ១៩៧៦។ ខ្មែរក្រហមឲ្យខ្ញុំជីកប្រឡាយ។ នៅឆ្នាំ ១៩៧៩ ខ្ញុំចាប់ផ្ដើមរត់ម្ដងទៀត ហើយខ្ញុំបានទៅលាក់ខ្លួន។ ពេលដែលរបបខ្មែរក្រហមត្រូវបានដួលរលំ ខ្ញុំក៏បានត្រឡប់មកស្រុកកំណើតវិញ។

នៅពេលលោកតាបញ្ចប់រឿងរ៉ាវដែលគាត់ធ្លាប់បានឆ្លងកាត់ក្នុងរបបខ្មែរក្រហម ខ្ញុំក៏ក្រោកឡើង ហើយចាប់ដៃគាត់ដោយមានអារម្មណ៍ស្ងើចសរសើរ និងសោកសៅ។ ខ្ញុំអរគុណលោកតាសម្រាប់ការចែករំលែករឿងរ៉ាវក្នុងរបបខ្មែរក្រហមជាមួយខ្ញុំ និងក្រុមការងាររបស់ខ្ញុំ។

### ជា ការឡូន



ព្រះអាទិត្យកំពុងរះ បញ្ចេញពន្លឺដ៏កក់ក្ដៅ ពេញសួនច្បារ។ ដើមឈើត្រូវមានស្លឹកឈើពណ៌ចម្រុះគ្នា មានពណ៌ក្រហម ទឹកក្រូច និងពណ៌លឿង ហើយខ្យល់បក់មកបង្កើតជាសំឡេងដ៏ស្រទន់។ អ្នកអាចឮសត្វស្លាបស្រែកយំ ហើយក្មេងៗសើចពីចម្ងាយ។ អ្នកអាចមានអារម្មណ៍កក់ក្ដៅពីព្រះអាទិត្យនៅលើស្បែករបស់អ្នកនៅពេលអ្នកមើលទេសភាពដ៏ស្រស់ស្អាតនៅជុំវិញ។ វាជាថ្ងៃដ៏ល្អឥតខ្ចោះដើម្បីធ្វើដំណើរទៅក្នុងភូមិ និងជួបអ្នកផ្ដល់បទសម្ភាសន៍។ លោកអ៊ំ ជា ការឡូន គឺជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ជារបបដែលទទួលខុសត្រូវចំពោះការស្លាប់របស់ប្រជាពលរដ្ឋខ្មែរស្លូតត្រង់រាប់លាននាក់។ ក្នុងរបបខ្មែរក្រហម លោកអ៊ំ ជា ការឡូន ចងចាំពីគ្រាដ៏លំបាកបំផុតក្នុងជីវិតរបស់លោកអ៊ំ។ កាលពីកុមារភាព លោកអ៊ំមានភារកិច្ចមើលថែទាំហ្វូងសត្វ និងប្រមូលដើមទន្រ្ទានខេត្រមកធ្វើជី ខណៈគាត់អាចហូបបាយបានមួយក្ដាប់ពេញតាមការអនុញ្ញាត។

### វិត លុញ



លោកពូ វិត លុញ អាយុ៤៩ឆ្នាំ បច្ចុប្បន្នជាកម្មករសំណង់។ ដោយសារតែភាពតក់ស្លុតផ្លូវចិត្តដែលលោកពូបានជួបប្រទះក្នុងរបបខ្មែរក្រហម បានធ្វើឲ្យលោកពូបាត់បង់ការចងចាំនូវព្រឹត្តិការណ៍មួយចំនួនទាក់ទងនឹងរឿងរ៉ាវដែលលោកពូជួបប្រទះនៅក្នុងរបបខ្មែរក្រហម។ ទោះបីជាលោកពូ លន់មិនអាចរំឭកបទពិសោធន៍ភាគច្រើនបានក៏ដោយ លោកពូនៅតែចងចាំពីការងាររបស់លោកពូកាលពីនៅយុវវ័យដែរ។ នៅក្នុងរបបខ្មែរក្រហមលោកពូស្ថិតនៅក្នុងកងកុមារធ្វើការងារដូចជាចិញ្ចឹមសត្វ និងធ្វើស្រែ។ ជាអកុសល លោកពូលន់មិនបានរៀនសូត្រជ្រៅជ្រះទេដោយសារតែមានចលនាខ្មែរក្រហមនៅក្នុងស្រុកភូមិរបស់លោកពូ។ ទោះបីជាមានបញ្ហាប្រឈមទាំងនេះក៏ដោយ ក៏លោកពូ វិត លុញ នៅតែប្ដេជ្ញាចិត្តចំពោះតួនាទីរបស់ខ្លួនជាកូនច្បង

ក្នុងចំណោមបងប្អូន១០នាក់ ដោយ ទទួលបន្ទុកយ៉ាងសំខាន់នៅក្នុងគ្រួសារ។

## ណុច ម៉ុច



លោកយាយ ណុច ម៉ុច អាយុ៨២ឆ្នាំ បច្ចុប្បន្នមិនអាចធ្វើកិច្ចការអ្វីទេក្រៅពីនៅផ្ទះមើលថៃចៅ។ លោកយាយ បានប្រាប់ខ្ញុំនិងក្រុមការងារអំពីព្រឹត្តការណ៍ដែលលោកយាយជួបប្រទះដែលធ្វើឲ្យលោកយាយស្ទើរតែបាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ប៉ុន្តែសំណាងល្អ លោកយាយបានរួចជីវិត។ ទោះបីជាមិនបានទទួលការអប់រំជាផ្លូវការក៏ដោយ ក៏លោកយាយ ណុច ម៉ុច មានភារកិច្ចទទួលខុសត្រូវផ្សេងៗ រួមមានការធ្វើជី ដាំដំណាំ និងភារកិច្ចតិចតួចផ្សេងទៀត។ ជាអកុសល លោកយាយបានបាត់បង់បងប្អូនបង្កើតពីរនាក់ព្រោះត្រូវខ្មែរក្រហមនាំយកទៅរៀនសូត្រ។ រហូតមកដល់សព្វថ្ងៃនេះ លោកយាយនៅមិនទាន់ដឹងពីជោគវាសនារបស់បងប្អូនរបស់លោកយាយនៅឡើយទេ។ លោកយាយ ណុច ម៉ុច បានស៊ូទ្រាំនឹងការលំបាកយ៉ាងខ្លាំងក្នុងរបបខ្មែរក្រហម ដោយសារធ្វើការហួសកម្លាំង និងការតស៊ូដើម្បីរស់។



ផ្លូវលំក្នុងភូមិបាក់នឹម។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

## ទន់ អួន



អ្នកមីង ទន់ អួន អាយុ៦៧ឆ្នាំ គឺជាកសិករម្នាក់ដែលធ្លាប់មានការបាត់បង់ការចងចាំ។ ទោះជាយ៉ាងនេះក្តី អ្នកមីងនឹកឃើញឡើងវិញនៅពេលដែលខ្មែរក្រហមចាត់តាំងឲ្យធ្វើការងារពលកម្មហួសកម្លាំងដូចជា រែកដី ធ្វើជី និងលើកទំនប់ម្រេច។ ដោយសារតែការគ្រប់គ្រងរបស់ខ្មែរក្រហម អ្នកមីង ទន់ អួន រៀនបានត្រឹមថ្នាក់ទី៣តែប៉ុណ្ណោះ អ្នកមីងត្រូវបានបង្ខំឲ្យធ្វើស្រែជំនួសវិញ។ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ អ្នកមីងរត់គេចខ្លួនចេញពីទាហាន និងទីបំផុតបានមករស់នៅក្នុងភូមិបាក់នឹមដល់សព្វថ្ងៃនេះ។ ក្នុងអំឡុងពេលរត់គេចខ្លួន អ្នកមីង ទន់ អួន បានឃើញហេតុការណ៍ដ៏អាក្រក់មួយ គឺខ្មែរក្រហមចង និងបណ្តើរមនុស្សម្នាក់យកទៅសម្លាប់ចោល ដែលព្រឹត្តិការណ៍បន្សល់ទុកនូវស្លាកស្នាមជាប់អារម្មណ៍ដែលមិនអាចបំភ្លេចបាននៅក្នុងចិត្តរបស់អ្នកមីង។



ទេសភាពភូមិបាក់នឹមថតពីចង្កេះភ្នំដំរីរមៀល។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# រឿងរ៉ាវជីវិតនិងបញ្ហាសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម

## ចំនួន ៥០០នាក់ នឹងត្រូវបានផ្សព្វផ្សាយនៅលើប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន

**សោម ប៊ុនថន**



នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារកម្ពុជាមានការជួបប្រជុំជាមួយ ស្ថាប័នឯកជន, អ្នកសិក្សាស្រាវជ្រាវ អ្នកជំនាញ ចំនួន១៥រូប ដើម្បីរៀបចំការផ្សព្វផ្សាយអំពីបទពិសោធន៍ជីវិតពិត និងបញ្ហាសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ (ស៊ាង ចិន្តា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

មជ្ឈមណ្ឌលឯកសារកម្ពុជារៀបចំកម្មវិធីសម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន៥០០នាក់ ដើម្បីផ្ដល់ឱកាសឲ្យអ្នកទាំងអស់នេះ បាននិយាយរៀបរាប់អំពីរឿងរ៉ាវជីវិតពិត និងបញ្ហាសុខភាពរបស់ខ្លួន តាមរយៈប្រព័ន្ធផ្សព្វផ្សាយព័ត៌មានជាសាធារណៈ។

នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារកម្ពុជាមានការជួបប្រជុំជាមួយ ស្ថាប័នឯកជន, អ្នកសិក្សាស្រាវជ្រាវ អ្នកជំនាញ ចំនួន១៥រូប ដើម្បីរៀបចំការផ្សព្វផ្សាយអំពីបទពិសោធន៍ជីវិតពិត និងបញ្ហាសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ ការផ្សព្វផ្សាយនេះ មានការចូលរួមពីក្រុមគ្រូពេទ្យ, ស្ថាបត្យករ, សិល្បករ-សិល្បការិនី, អ្នកផលិតវីដេអូ, អ្នកស្ម័គ្រចិត្ត, បណ្ដាញទូរទស្សន៍ឯកជន, អ្នកស្រាវជ្រាវ, សារព័ត៌មាន, អង្គការមជ្ឈមណ្ឌលព័ត៌មាន, មន្ទីរសម្រាកព្យាបាលឯកជន និងសហគមន៍ចាម ដែលក្រុមនីមួយៗមានយន្តការខុសៗគ្នាក្នុងការផ្សព្វផ្សាយ ទៅកាន់សាធារណជន អំពីរឿងជីវិតពិត និងបញ្ហាសុខភាពរបស់អ្នករស់រានមានជីវិតពីសម័យខ្មែរក្រហម។





អ្នកស្រាវជ្រាវ អ្នកជំនាញ អ្នកសារព័ត៌មាន សិល្បករ សិល្បការិនី ជួបជុំជាមួយលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីរៀបចំការផ្សព្វផ្សាយអំពីបទពិសោធន៍ជីវិត និងបញ្ហាសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅក្នុងក្រុមតួរ្យតន្ត្រី យើងបានគិតពិចារណាក្នុងការកសាងឡើងវិញអំពីបទចម្រៀងដែលអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមធ្លាប់បានច្រៀងជាដំបូង ដូចជាបទ «ឱ! ភ្នំពេញអើយ»។ យើងនឹងពិចារណាថា ថាតើគួរបន្ទឺឡើងនូវសំនៀងពីសម័យខ្មែរក្រហមដែរឬទេតាមរយៈអ្នកចម្រៀងពីរបបខ្មែរក្រហម និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដើម្បីបង្ហាញអំពីការផ្សះផ្សា លែងមានការរើសអើង និងលែងមានការបែងចែកកូនឬចៅខ្មែរក្រហមតទៅទៀត។

នៅក្នុងក្រុមអ្នកសិក្សាស្រាវជ្រាវ យើងកំពុងស្រាវជ្រាវរកទីតាំងដែលអ្នកជំនាញការរុស្សុីផ្នែកកសិកម្មចំនួន៧រូប ដែលត្រូវបានខ្មែរក្រហមសម្លាប់នៅថ្ងៃទី២៣ ខែសីហា ឆ្នាំ១៩៨៣ នៅឃុំស្វាយទាប ស្រុកចំការលើ ខេត្តកំពង់ចាម ដែលជាតឹកតាងសំខាន់បង្ហាញថា របបខ្មែរក្រហមនៅបន្តរស់រានមានជីវិត ទោះបីជានៅក្រោយថ្ងៃរំដោះ៧ មករា ១៩៧៩ ក៏ដោយ ហើយក្រុមខ្មាំងនៅតែបន្តហានិភ័យ និងកាប់សម្លាប់ប្រជាជន។



ចំណែកក្រុមសិល្បករ និងអ្នកចម្រៀងរបស់យើង ពេជ្រ ចរិយា នឹងចូលរួមគ្រប់សកម្មភាពប្រជុំតាមមូលដ្ឋានផ្សព្វផ្សាយអំពីការអប់រំ និងថែរក្សាសុខភាពដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដូចជា ការពិនិត្យសុខភាពបឋមនៅតាមបណ្តាភូមិស្ថាននានា តាមរយៈការចែករំលែកបរិយាកាសសប្បាយរីករាយដល់ប្រជាជននៅតាមមូលដ្ឋានឆ្ងាយៗ និងមានការថតជាវីដេអូខ្លីៗ។ ក្នុងនោះ យើងក៏មានក្រុមយុវជនដែលកំពុងធ្វើវីដេអូខ្លី អំពីអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅតាមភូមិស្រុកដាច់ស្រយាលមួយចំនួនហើយដែរ។

ចំពោះក្រុមស្ថាបត្យកម្ម យើងរំពឹងថាគាត់នឹងជួយធ្វើយ៉ាងណាឲ្យមជ្ឈមណ្ឌលសហគមន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជានៅតាមភូមិនីមួយៗ



អ្នកស្រាវជ្រាវ អ្នកជំនាញ អ្នកសារព័ត៌មាន សិល្បករ សិល្បការិនី ទស្សនាពិព័រណ៍នៅមជ្ឈមណ្ឌលឯកសារកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

មានលក្ខណៈ ជាកន្លែងប្រជុំជនសម្រាប់មនុស្សគ្រប់រូប បង្កឲ្យមានការជួបជុំគ្នាដើម្បីនិយាយអំពីការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ជាកន្លែងដែលគាត់អាចផ្លាស់ប្តូរបទពិសោធន៍រវាងគ្នា និងគ្នាតាមរយៈការតាំងពិព័រណ៍ និងដោយប្រើប្រាស់ធនធានក្នុងស្រុក ប៉ុន្តែមានផលប្រយោជន៍ធំធេងដល់សហគមន៍។ ឧទាហរណ៍ ដូចដែលយើងបានសង់មជ្ឈមណ្ឌលសហគមន៍នៅស្រុកវាលវែង និងនៅភូមិបាក់នឹម ដើម្បីបម្រើដល់សហគមន៍ជាដើម។

ម្យ៉ាងទៀត យើងនឹងមានក្រុមស្ថាបត្យករជួយរចនានិមិត្តសញ្ញារបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលមានតាំងពីយូរមកហើយឡើងវិញ។ យើងរំពឹងថា និមិត្តសញ្ញានេះនឹងដើរតួរនាទីជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា ដើម្បីបោះបង្គោលសម្គាល់ទីតាំងដែលជាកន្លែងអំពើឧក្រិដ្ឋកម្មដែលបានកើតឡើងកាលពីសម័យខ្មែរក្រហម ព្រមទាំងបោះបង្គោលនៅតាមទីប្រជុំជនដើម្បីផ្សព្វផ្សាយអំពីរឿងសុខភាពអ្នករស់រានមានជីវិតពីសម័យខ្មែរក្រហម។

នៅក្នុងនោះដែរ យើងមានបណ្តាញសារព័ត៌មានឯកជន ដែលយើងរំពឹងថា ប្រធានក្រុមផ្សព្វផ្សាយរបស់យើងនឹងធ្វើយ៉ាងណាឲ្យប្រជាជនចំនួន៥០០នាក់បានមកកាន់បន្ទប់ថតសំឡេងរបស់ស្ថានីយ៍ទូរទស្សន៍ ស៊ី.ធី.អិន ក៏ដូចជា ស្ថានីយ៍វិទ្យុរបស់អង្គការមជ្ឈមណ្ឌលព័ត៌មានស្ត្រីកម្ពុជា, មជ្ឈមណ្ឌលព័ត៌មានមូស្លីមកម្ពុជា និងសារព័ត៌មានហ្វ្រេសញូវ ដើម្បីឲ្យគាត់មានឱកាសនិយាយរៀបរាប់អំពីបទពិសោធន៍ជីវិតពិតរបស់ខ្លួន និងជាពិសេសឆ្លើយទៅនឹងសំណួរមួយថា តើមានរឿងអ្វីនៅក្នុងសម័យខ្មែរក្រហមដែលគាត់មិនអាចបំភ្លេចបានទាល់តែសោះ ដើម្បីឲ្យក្មេងៗបានដឹង ហើយជាការរំឭកយើងទាំងអស់គ្នាកុំឲ្យភ្លេចថា រឿងនេះគឺជារឿងប្រវត្តិសាស្ត្រកម្ពុជា កុំឲ្យវាកើតឡើងជាថ្មីម្តងទៀត។ យើងចង់ឲ្យអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមមានឱកាសក្នុងការចែក

រំលែករឿងរ៉ាវជីវិតរបស់គាត់ ដោយសារភាគច្រើនប្រជាជនរបស់យើងមិនបានចូលរួមដោយផ្ទាល់ជាមួយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ ជាចុងក្រោយ យើងមានក្រុមសិល្បៈ ដែលបានសហការជាមួយបណ្ណាល័យសម្តេចម៉ែតាំងពីកកើតដំបូងមក។

ការប្រជុំនេះ គឺជាការប្រជុំលើកដំបូងក្រោយពេលដែលមានការរាតត្បាតពីជំងឺកូវីដ-១៩។ យើងរំពឹងថាការផ្សព្វផ្សាយនេះនឹងជួយឲ្យយុវជនជំនាន់ក្រោយផ្តល់ការគោរព និងការដឹងគុណ និងឈ្វេងយល់ព័ត៌មានពិត ប្រវត្តិសាស្ត្រពិត ពីអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលជាអ្នកភូមិផងរបងជាមួយនៅក្នុងភូមិស្រុកជាមួយគ្នា ហើយក៏ដូចជាឱកាសដើម្បីរំពុកឡើងវិញថា អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមទាំងអស់នេះ គឺជាអ្នកកសាងជាតិតាំងពីបាតដៃទទេតាំងពីឆ្នាំ១៩៧៩មកម្ល៉េះ។ យើងចង់ឲ្យមានការយកចិត្តទុកដាក់ដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមទាំងនោះ ព្រោះភាគច្រើនគាត់មានវ័យកាន់តែចំណាស់ ហើយបញ្ហាសុខភាពក៏កាន់តែទ្រុឌទ្រោម ស្របពេលជាមួយគ្នានេះ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមមួយចំនួននៅមានជីវភាពខ្វះខាតនៅឡើយ។ ការប្រជុំនេះមានសារសំខាន់បង្ហាញអំពីការយកចិត្តទុកដាក់របស់មជ្ឈមណ្ឌលឯកសារកម្ពុជាចំពោះអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលនៅបន្តធ្វើការជាមួយគ្នាជារៀងរហូត។







អ្នកស្រាវជ្រាវ អ្នកជំនាញ អ្នកសារព័ត៌មាន សិល្បករ សិល្បការិនី ជួបជុំជាមួយលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីរៀបចំការផ្សព្វផ្សាយអំពីបទពិសោធន៍ជីវិត និងបញ្ហាសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ខ្ញុំឈឺចាប់នៅពេលដឹង ប្អូនស្រីខ្ញុំបាត់បង់ជីវិត

**ប៉ាន់ ទីន**



*ណាំ ញី រស់នៅភូមិត្រពាំងឈូក ឃុំត្រពាំងធំខាងត្បូង ស្រុកត្រាំកក់ ខេត្តតាកែវ ខែមេសា ឆ្នាំ២០២៣។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ខ្ញុំឈ្មោះ ណាំ ញី អាយុ៨០ឆ្នាំ ហើយបច្ចុប្បន្ន រស់នៅភូមិត្រពាំងឈូក ឃុំត្រពាំងធំខាងត្បូង ស្រុកត្រាំកក់ ខេត្តតាកែវ។ ឪពុកខ្ញុំឃ្វាលគោ និងម្តាយធ្វើនំលក់ ដូច្នេះគ្រួសារខ្ញុំមិនសូវជាធូរធារទេ។ ខ្ញុំមានបងប្អូនចំនួន៨នាក់ ហើយខ្ញុំគឺជាកូនច្បងក្នុងគ្រួសារ។ នៅអាយុ៨ឆ្នាំ ខ្ញុំចូលរៀន នៅវត្តត្រពាំងធំ ស្ថិតក្នុងឃុំត្រពាំងធំខាងត្បូង ស្រុកត្រាំកក់។ ខ្ញុំតែងជួយទូលនំម៉ែលក់ មុនពេលខ្ញុំទៅរៀន។ រៀនបានត្រឹមថ្នាក់ទី៩ ខ្ញុំឈប់រៀន ដោយសារជីវភាពគ្រួសារនៅតែខ្វះខាត។ បន្ទាប់ពីខ្ញុំឈប់រៀន ខ្ញុំជួយធ្វើនំម៉ែ និងធ្វើកិច្ចការផ្ទះសម្បែង។

លុះពេលខ្ញុំអាយុ២១ឆ្នាំ ខ្ញុំរៀបការជាមួយប្តីឈ្មោះ ឌិ សឿន។ ក្រោយពីរៀបការមានគ្រួសាររួចមក ពួកខ្ញុំទាំងពីរនាក់ទៅធ្វើការនៅ ស្រុកមេមត់។ ប្តីខ្ញុំចៀរជ័រកៅស៊ូ ហើយខ្ញុំលក់ចាប់ហួយនៅទីនោះ។ រៀងរាល់រយៈពេលកន្លះខែម្តង ថៅកែចម្ការកៅស៊ូតែងបើកប្រាក់ខែឲ្យកម្មករ ដោយក្នុងម្នាក់ទទួលបានប្រាក់ចំនួន៣០០រៀល។ រយៈពេល៧ឆ្នាំក្រោយមក មានយន្តហោះទម្លាក់គ្រាប់បែកជាច្រើន ថែមទាំងធ្វើឲ្យមានមនុស្សស្លាប់ទៀត។ បន្ទាប់ពីស្បៀយការទម្លាក់គ្រាប់បែកបន្តិច ខ្ញុំនិងអ្នកផ្សេងទៀត បានធ្វើដំណើរមកស្រុកកំណើតរៀងៗខ្លួន។ ខ្ញុំចាកចេញពីស្រុកមេមត់អស់រយៈពេលជាច្រើនខែជាមួយនឹងកូនស្រីអាយុ៤ឆ្នាំ និងគ្រួសាររបស់ខ្ញុំ។ ត្រឡប់មកដល់ភូមិកំណើតវិញ យន្តហោះនៅតែបន្តទម្លាក់គ្រាប់បែកជុំវិញភូមិដដែល។ ក្រោយមកខ្ញុំឮអ្នកភូមិនិយាយតគ្នាថា «បែកទីក្រុងភ្នំពេញ យើងអស់អីហើយ»។ ខ្មែរក្រហមឲ្យខ្ញុំចិញ្ចឹមនាង និងធ្វើស្រែជាក្រុមនៅក្នុងភូមិ។ ចំណែកប្តីខ្ញុំធ្វើជាអនុប្រធានភូមិ ប៉ុន្តែខ្មែរក្រហមប្រើឲ្យឡើងត្នោតនិងធ្វើស្រែប្រាំង។ កូនស្រីខ្ញុំអង្គការនាំទៅឲ្យរៀនសូត្រ។ ខ្មែរក្រហមបែងចែកអ្នកផ្សេងដូចជា អ្នកមានកូនប្រុសឲ្យនៅក្បែរៗភូមិធ្វើកន្ទេល ដាំដំណាំ និងមើលក្មេងៗ។ ឯអ្នកមិនទាន់មានគ្រួសារ ឬមានកម្លាំង គេជម្លៀសទៅឆ្ងាយៗក្រៅពីឃុំ។ មុនបែកខ្មែរក្រហម ខ្ញុំឮថា «ទ័ពវៀតណាមឲ្យតែឃើញដឹងតែបាញ់យើងចោលហើយ»។ គ្រាន់តែឮបែបនេះ ខ្ញុំនិងអ្នកផ្សេងទៀតនាំគ្នារត់។ ខ្ញុំរត់ទៅដល់ភ្នំក្រវាញ និង

ទៅដល់ អូរសោម ខេត្តពោធិ៍សាត់បានជួបនឹងកងទ័ពវៀតណាម។ កងទ័ពវៀតណាម ចែកបាយឲ្យប្រជាជនហូប និងបញ្ជូនពួកខ្ញុំមកស្រុកកំណើតវិញ។ ប្ដីខ្ញុំរត់ទៅជាមួយពួកខ្មែរក្រហម ព្រោះតែគាត់ភ័យខ្លាចប្រជាជននឹងធ្វើបាបគាត់ដែលកាលនោះគាត់ធ្វើជាអនុប្រធានភូមិ។ ក្រោយរបបខ្មែរក្រហមដួលរលំ ខ្ញុំនិងកូនបានទៅយកប្ដីខ្ញុំមកជួបជុំគ្រួសារវិញ។ រឿងដែលខ្ញុំទុក្ខសោកបំផុតនោះគឺ ខ្ញុំបាត់បង់កូនស្រីច្បងខ្ញុំម្នាក់ដោយមិនដឹងថាស្លាប់ឬរស់នោះឡើយ។ ខ្ញុំបានសួរនាំអំពីកូនស្រីខ្ញុំពីអ្នកដែលនាំកូនស្រីខ្ញុំទៅជាមួយ គាត់តែងនិយាយថា «កុំបារម្ភអី កូនស្រីអ្នកសុខសប្បាយទេ»។ ខ្ញុំចេះតែសួរទៅអ្នកឯទៀត តែគ្មានអ្នកណាម្នាក់ប្រាប់ថាកូនស្រីខ្ញុំបាត់បង់ជីវិតនោះទេ។ ខ្ញុំស្រាវជ្រាវក៏បានដំណឹង កូនស្រីខ្ញុំបានស្លាប់បាត់បង់ជីវិត ក្នុងខណៈពេលមានគេនាំទៅកាប់ឈើធ្វើជំរំជាមួយ។ កូនស្រីខ្ញុំប្រទះនឹងផ្លែក្រឡាញ់ហើយបេះមកហូប ក៏ត្រូវជន់ជាតិថៃបាញ់សម្លាប់ចោល និងទម្លាក់ចូលទឹក។



ណាំ ញី ផ្ដល់បទសម្ភាសន៍អំពីរឿងរ៉ាវក្នុងរបបខ្មែរក្រហម ដល់ក្រុមការងាររមជ្ឈមណ្ឌលឯកសារ ខេត្តតាកែវ កាលពីខែមេសា ឆ្នាំ២០២៣។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# វ័យជាកុមារ ធ្វើការក្នុងកងនារី

ចាន់ ទីន



ថ្វាង ហៀង រស់នៅភូមិបឹងម្កាក់ ឃុំត្រាំកក់ ស្រុកត្រាំកក់ ខេត្តតាកែវ ខែមេសា ឆ្នាំ២០២៣។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ថ្វាង ហៀង អាយុ៦៨ឆ្នាំ បច្ចុប្បន្នរស់នៅភូមិបឹងម្កាក់ ឃុំត្រាំកក់ ស្រុកត្រាំកក់ ខេត្តតាកែវ។ ខ្ញុំរៀបការក្នុងឆ្នាំ១៩៨១ សព្វថ្ងៃខ្ញុំមានកូនចំនួន៦នាក់ស្រី២នាក់ និងប្រុស៤នាក់។ ប៉ុន្តែស្លាប់អស់២ នាក់គឺស្រីម្នាក់ និងប្រុសម្នាក់។ នៅរបប លន់ នល់ មានព្រឹត្តិការណ៍មួយបានកើតឡើងមានយន្តហោះទម្លាក់គ្រាប់បែក។ ខ្ញុំចាកចេញពីផ្ទះព្រោះខ្លាចយន្តហោះទម្លាក់គ្រាប់ត្រូវ។ ការហូបចុកក្នុងរបប លន់ នល់ បានគ្រប់គ្រាន់ ព្រោះនៅហូបបាយឯកជនមានផ្ទះសម្បែង ដីជារបស់ឯកជន និងរស់នៅជុំគ្រួសារ។ នៅពេលមានយន្តហោះមកខ្ញុំនិងគ្រួសារនាំគ្នារត់ចូលត្រង់សេប្កលេណដ្ឋាន។ ក្រោយមកមានការទម្លាក់គ្រាប់បែកខ្លាំងជាងមុនទៅទៀត ជាពិសេសពេលថ្ងៃ។

នៅក្នុងឆ្នាំ១៩៧៥ និង ឆ្នាំ១៩៧៦ អង្គការឲ្យខ្ញុំទៅជីកប្រឡាយរួមមានទាំងចាស់ៗនិងក្មេងអង្គការប្រើឲ្យជីកប្រឡាយ ទាំងថ្ងៃទាំងយប់។ ពេលដល់ម៉ោងធ្វើការ និងដល់ម៉ោងឈប់សម្រាក អង្គការវាយជួងសម្រាប់ផ្តល់ដំណឹង។ ខ្ញុំឃើញឈ្លបយកមនុស្សទៅធ្វើបាប អ្នកត្រូវបញ្ជូនទៅស្លៀកខោខ្លីត្រឹមជង្គង់ គ្មានអាវសម្រាប់ពាក់ ដៃចងខ្សែព័ន្ធទៅក្រោយ។ អ្នកដើរក្រោយ ទាត់អ្នកដើរមុខបន្តគ្នាមួយជើងៗ បណ្តើរចេញពីផ្ទះ តាមុត នៅចម្ការលើ ស្រុកត្រាំកក់ ខេត្តតាកែវ សំដៅចូលទៅក្នុងព្រៃមិនឃើញត្រឡប់មកវិញ។ អង្គការដាក់ខ្ញុំចូលកងកុមារបម្រុង ប៉ុន្តែកងកុមារបម្រុង និងកងនារីធ្វើការជាមួយគ្នា។ អង្គការប្រើឲ្យខ្ញុំរែកដីនៅពេលរដូវប្រាំង ហើយចូលរដូវវស្សាអង្គការប្រើឲ្យខ្ញុំទៅដកសំណាបព្រោះខ្ញុំមិនទាន់ចេះស្ទូងស្រូវ។ អង្គការដាក់ខ្ញុំទៅតាមកងគ្រប់ទីកន្លែង ដូចជានៅត្រពាំងកេស ត្រពាំងឈូក អង្គរនាប។ ការហូបចុកមិនបានឆ្អែត អង្គការឲ្យហូបតែបបរមួយពោះចានហូបជាមួយ សម្លព្រលិត សម្លត្រកួន ស្តែ ចុងភៅមិនមានបកសំបក ប្តុចិតគល់ចេញទេ ដាក់ស្លជាមួយសាច់មាន់មានសម្បុរខ្មៅព្រឹកៗ ក្រោយមកឲ្យខ្ញុំទៅកំពង់យោ លរយៈពេល៦ខែ ចាប់ពីស្ទូងរហូតដល់ស្រូវទុំ។ អង្គការឲ្យខ្ញុំទៅធ្វើស្រែប្រាំង ប្រោចស្មៅ ធ្វើការដល់ម៉ោង១២វាយជួងសម្រាកហូបបាយថ្ងៃត្រង់។ អង្គការ

ឲ្យសម្រាកបានតែមួយម៉ោងចាប់ផ្តើមធ្វើការៗ នៅកំពង់យោល ខ្ញុំជួបការលំបាកការហូបចុកយ៉ាងខ្លាំង ប្រជាជនដែលរស់នៅទីនោះមើលទៅមានសភាពស្គមស្គាំងៗ ប្រជាជនទូទៅ នារី យុវជនបានរបបអាហារស្មើៗគ្នាតែបបរមួយពោះចានក្នុងម្នាក់ៗ ក្នុងរបបខ្មែរក្រហម ខ្ញុំបាត់បង់បងប្រុសម្នាក់ឈ្មោះ មី អង្គការឲ្យទៅកំពង់អំពិល ដោយប្រាប់ថាយកយុវជនចំនួន ១០០នាក់ និងនារីចំនួន១០០នាក់យកទៅជួយបែកភូមិថ្មីឲ្យប្រជាជន ប៉ុន្តែគេយកទៅធ្វើបាប មិនឲ្យហូបបាយបានគ្រប់គ្រាន់ៗ

ឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨ អង្គការឲ្យខ្ញុំធ្វើការតាមកងមិនឲ្យត្រឡប់មកផ្ទះវិញទេៗ អង្គការមានផ្ទះដាក់តាមកន្លែងតាមកងនីមួយៗប្រមូលផ្តុំគ្នាៗ ក្រោយមកអង្គការបានឲ្យខ្ញុំមកជីកប្រឡាយនៅស្ពានស្ទឹងថ្មី ដែលស្ថិតនៅភូមិយាយឡ ឃុំត្រាំកក់ ស្រុកត្រាំកក់ ខេត្តតាកែវ កាលនោះ ខ្ញុំធ្វើការនៅក្នុងកងកុមារៗ នៅខែប្រាំង ខ្ញុំរើសអាចម៍គោ កាប់ដើមទន្ទ្រានខេត្តជីកប្រឡាយនៅស្ពានស្ទឹងថ្មីអង្គការមិនឲ្យសម្រាកទេៗ គេប្រើខ្ញុំកាប់ដី រែកដី ពីខ្ពស់មកទាប ធ្វើរហូតដល់ម៉ោង១០យប់ ទើបអាចសម្រាកបានៗ ការហូបចុកមិនគ្រាន់ទេ សម្ភារដែលយើងមានជាប់នឹងខ្លួនមានតែចានមួយ ស្លាបព្រាមួយ សម្រាប់ហូបបាយ ហើយសាក់កាដូរមួយមានខោអាវ ខ្មៅៗ ប្រជាជនមូលដ្ឋាន ឬប្រជាជនពេញសិទ្ធិ និងពួក១៧ ដាក់ឲ្យរស់នៅជាមួយគ្នាៗ ខ្ញុំឃើញអង្គការយកទៅធ្វើបាប និងធ្វើទារុណកម្មភាគច្រើនតែពួក១៧ៗ អាវក្រណាត់ពណ៌ស គេយកជ្រលក់ផ្លែមាក់ក្លឿ ហើយយកទៅដាក់ភក់ឲ្យខ្មៅរួចយកទៅហាលថ្ងៃៗ នៅពេលអាវជ្រះពណ៌ខ្មៅយកទៅធ្វើឡើងវិញម្តងទៀតដើម្បីជាប់ពណ៌ខ្មៅៗ ក្នុងរបបខ្មែរក្រហម ខ្ញុំឈឺគ្រុនគេសែងខ្ញុំមកដាក់មន្ទីរពេទ្យនៅវត្តខាងជើងផ្សារ ដាក់សេរ៉ូមកែវតូចៗ ថ្នាំអាចម៍ទន្សាយឲ្យលេបៗ បើយើងចេញពីមន្ទីរពេទ្យមកមិនអាចទៅផ្ទះទេទៅកន្លែងធ្វើការវិញៗ ប្រធានកងដែលគ្រប់គ្រងមួយស្រុកត្រាំកក់ កាន់កាប់ខាងមន្ទីរពេទ្យនៅខាងជើងផ្សារត្រាំកក់ ឈ្មោះ អ៊ុលី ហើយប្រធានកងដែលត្រូវមើលការខុសត្រូវខ្ញុំក្នុងកងកុមារ និងកងនារី ឈ្មោះ អ៊ីច្រឹបៗ ខ្ញុំធ្លាប់បានចូលរួមប្រជុំក្រុមមួយសប្តាហ៍ប្រជុំម្តង គេនិយាយឲ្យយើងខំធ្វើការប្រាប់ឲ្យបេះរិះគន់គ្នា អ្នកណាមិនខំធ្វើការ គេឲ្យទិតៀនគ្នា ថាយើងមិនខំធ្វើការមិនទាន់គេ មានពុតត្បុតធ្វើឈឺមិនទៅធ្វើការៗ «ពេលទៅប្រជុំសន្និបាតគេនិយាយថា២០ឆ្នាំ ៣០ឆ្នាំ ១០០ឆ្នាំសង្គមនៅដំណើរការដូចរាល់ថ្ងៃ» គេឲ្យប្រជាជនឡើងធ្វើការប្តេជ្ញាថា «ធ្វើស្រែមួយហិកតាឲ្យបាន ៣តោន» គេឲ្យឡើងតំណាងតាមប្រធានក្រុមមួយៗៗ សាសនាបំបិទចោល ទាំងអស់មិនឲ្យមានលោកសង្ឃទេ ដោយយកវត្តអារាមរុះរើធ្វើជាទ្រុងគោ ទ្រុងជ្រូក ខ្ញុំឃើញប្រជាជនភាគច្រើនស្លាប់ដោយសារអត់មានអាហារហូបគ្រប់គ្រាន់ធ្វើការងាររហូសម៉ោងមិនបានសម្រាកៗ

បែកឆ្នាំ១៩៧៩ ខ្ញុំបានចូលមករស់នៅស្រុកភូមិវិញការហូបចុកបានគ្រប់គ្រាន់គ្មានផ្ទះសម្បែងនៅទេ ខ្ញុំរើសឈើយកមកធ្វើផ្ទះសម្រាប់រស់នៅបណ្តោះអាសន្នៗ ភូមិមើលទៅពោរពេញទៅស្មៅដុះជុំជិតៗ ដំបូងខ្ញុំនិងប្រជាជនផ្សេងទៀតគេឲ្យធ្វើស្រែរួម បែងចែកក្រុមប្រវាស់ដៃ ធ្វើស្រែ ដាក់រួមគ្នា ចែកស្រូវក្នុងម្នាក់បាន១២ថាំងៗ ដល់ក្រោយមកចែកដីកម្មសិទ្ធិក្នុងម្នាក់១៤កុង គ្រប់សមាជិកគ្រួសាររបស់យើងមានប៉ុន្មាន ចែកឲ្យប៉ុណ្ណឹងៗ ខ្ញុំបានប្រាប់កូនរបស់ខ្ញុំអំពីជីវិតដែលខ្ញុំបានឆ្លងកាត់ៗ



អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមមកពីស្រុកត្រាំកក់ ខេត្តតាកែវ មកចូលរួមគម្រោងអប់រំអំពីសុខភាពរៀបចំដោយមជ្ឈមណ្ឌលឯកសារខេត្តតាកែវ កាលពីខែមេសា ឆ្នាំ២០២៣ៗ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ខ្ញុំចេះកាត់ដេរដោយសារ ខ្ញុំមើលពីគ្រួសារដែលខ្ញុំមើលកូនឲ្យ

**ចាន់ ទីន**



ប៉ែន សុខា ផ្តល់បទសម្ភាសន៍អំពីរឿងរ៉ាវក្នុងរបបខ្មែរក្រហម អំឡុងពេលក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា ធ្វើវេទិកាប្រវត្តិសាស្ត្រគ្រួសារ នាខែមេសា ឆ្នាំ២០២៣។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ប៉ែន សុខា អាយុ៧០ឆ្នាំ មានស្រុកកំណើតនៅថ្នល់បត់ស្ថិតនៅក្នុងឃុំពោធិអង្ក្រង ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ។ គ្រួសារខ្ញុំមានជីវភាពទីទាល់ក្រ កាលពីខ្ញុំនៅកុមារ។ ខ្ញុំមានបងប្អូនចំនួន១៤នាក់ ខ្ញុំគឺជាកូនទី៣ក្នុងគ្រួសារ ឪពុកម្តាយខ្ញុំគឺជាអ្នកស្រែចម្ការ។ ខ្ញុំមិនធ្លាប់បានចូលរៀនពីមុនមកទេ។ ចំណែកបងប្អូនខ្ញុំប៉ុន្មាននាក់ទៀត ពួកគេបានរៀនតិចតួចដែរ។ ដោយសារគ្រួសារមានជីវភាពខ្វះខាតពេក ទើបបងៗនិងខ្ញុំសម្រេចចិត្តបែកពីគ្រួសារ ដើម្បីទៅដើររកស៊ីឈ្នួលក្រៅផ្ទះ។ ពេលខ្ញុំអាយុ១០ឆ្នាំ ខ្ញុំធ្វើការស៊ីឈ្នួលជាអ្នកមើលកូនឲ្យគេ។ កាលនោះមានគ្រួសារធូរធារមួយ ត្រូវការអ្នកមើលកូនរបស់ពួកគាត់ ហើយខ្ញុំបានទៅស៊ីឈ្នួលមើលកូនក្នុងគ្រួសារនោះ។ ពួកគាត់ប្រកបរបរគឺជាអ្នកលក់ដូរនៅកន្ទួត ឃុំសៀមរាប ស្រុកកណ្តាលស្ទឹង។ ខ្ញុំគ្រាន់តែមើលជំនួសពេលឪពុកម្តាយរវល់លក់ដូរតែប៉ុណ្ណោះ។ លុះពេលកូនធំធាត់បន្តិច គ្រួសារដែលខ្ញុំមើលកូនឲ្យនោះ បានណែនាំឲ្យខ្ញុំមើលកូនគេម្នាក់ទៀតក្នុងផ្ទះគ្រួសារមួយនៅភ្នំពេញ ពួកគេប្រកបរបរ គឺជាអ្នកកាត់ដេរ។ នៅក្នុងគ្រួសារកាត់ដេររវល់ណាស់ ពួកគេមានបង្រៀនពីរបៀបកាត់ដេរ និងស៊ីឈ្នួលកាត់សម្លៀកបំពាក់ក្នុងផ្ទះរបស់គេ។ ខ្ញុំមើលកូនឲ្យគេលំបាកណាស់ ប្រាក់ខែដែលខ្ញុំទទួលបានមិនស្មើនឹងគាត់ដេរបានមួយថ្ងៃផង។ ខ្ញុំបានកម្រៃត្រឹមតែ៣០រៀលប៉ុណ្ណោះក្នុងមួយខែ។ ជារៀងរាល់ខែ ខ្ញុំតែងឲ្យប្រាក់ខែរបស់ខ្ញុំទាំងអស់ទៅពុកម៉ែរបស់ខ្ញុំទិញអង្ករទុកហូប។ ខ្ញុំមើលកូនគេរហូតបានធំល្មមដែរ ខ្ញុំក៏ឈប់ធ្វើហើយត្រឡប់មកផ្ទះវិញ។ បន្ទាប់ពីខ្ញុំមកដល់ផ្ទះវិញមិនបានប៉ុន្មានខែ ក៏មានការទម្លាក់គ្រាប់បែក។ ខ្ញុំបានឮសំឡេងគ្រាប់បែកទម្លាក់ចម្ងាយ១២គីឡូម៉ែត្រពីតាកែវមកដល់ផ្ទះរបស់ខ្ញុំ។ ខ្ញុំភ័យខ្លាំងណាស់ គ្រួសារខ្ញុំក៏បបួលគ្នារត់ទៅពួននៅក្នុងត្រង់សេឬលេណដ្ឋាន។ ចូលរបបខ្មែរក្រហម ខ្ញុំរស់នៅជុំជាមួយគ្រួសារ ព្រោះពួកខ្ញុំជាប្រជាជន១៨ មេសា។ អង្គការប្រើឲ្យឪពុកម្តាយខ្ញុំទៅធ្វើការឆ្ងាយពីផ្ទះ ហើយពេលយប់ទើបត្រឡប់មកវិញ។ ដោយសារខ្ញុំធ្លាប់មើលកូនឲ្យគ្រួសារអ្នកកាត់ដេរ ខ្ញុំក៏ចេះដេរខ្លះៗដែរ។ ជួនកាលថ្ងៃខ្លះអង្គការប្រើឲ្យកាត់ដេរបន្តិចបន្តួចដោយម៉ាស៊ីន។ អង្គការឲ្យខ្ញុំដេរខោអាវឲ្យក្មេងៗនិងប្រជាជន។ ក្មេងដែលស្របាលខ្ញុំខ្លះ អង្គការឲ្យធ្វើការ ហើយខ្លះទៀតមិនធ្វើការអ្វីសោះក៏មាន។ ក្រោយពីរបបខ្មែរក្រហមដួលរលំ ខ្ញុំរៀបការជាមួយគ្រួសារឈ្មោះ ប៉ក់ ហែ រស់នៅភូមិតុំ សង្កាត់រកាក្រៅ ក្រុងដូនកែវ ខេត្តតាកែវ។ បច្ចុប្បន្ន ខ្ញុំប្រកបរបរជាជាងកាត់ដេរនៅផ្ទះ និងធ្វើស្រែ។

# ក្រសែភ្នែកក្មេងស្រីម្នាក់មើលឃើញតែភាពឃោរឃៅក្នុងរបបខ្មែរក្រហម

***ចាន់ ទីន***



ម៉ាង ទី ផ្តល់បទសម្ភាសន៍អំពីរឿងរ៉ាវក្នុងរបបខ្មែរក្រហម អំឡុងពេលក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជាធ្វើវេទិកាប្រវត្តិសាស្ត្រគ្រួសារ នាខែមេសា ឆ្នាំ២០២៣។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ម៉ាង ទី អាយុ៦៥ឆ្នាំ មានទីកន្លែងកំណើត និងបច្ចុប្បន្នរស់នៅភូមិកន្ទួត ឃុំស្រងែ ស្រុកទ្រាំង ខេត្តតាកែវ។ ខ្ញុំគឺជាកូនអ្នកស្រែចម្ការ រស់នៅជាមួយបងប្អូនក្នុងគ្រួសារដែលមានជីវភាពខ្វះខាត។ ខ្ញុំចូលរៀននៅថ្នាក់ទី១២ពីសង្គមចាស់នៅសាលាបឋមសិក្សាស្វាយអំពារ ស្ថិតក្នុងវត្តស្វាយអំពារ។ ជារៀងរាល់ថ្ងៃ ខ្ញុំដើរទៅរៀនកាត់ភ្លឺស្រែ និងកាត់ទឹកជម្រៅត្រឹមជង្គង់។ រៀននៅទីនោះបានរយៈពេលមួយឆ្នាំ ខ្ញុំក៏ប្តូរសាលារៀនពីសាលាបឋមសិក្សាស្វាយអំពារ ទៅរៀនបន្តថ្នាក់ទី១១នៅសាលាវត្តគុំវិញ។ កាលនោះមិត្តខ្ញុំមានកង់មួយ។ ជារៀងរាល់ពេលទៅរៀន វាតែងចូលមកយកខ្ញុំទៅជាមួយ។ ខ្ញុំមិនសូវខ្វល់ខ្វាយពីរឿងរៀនសូត្រឡើយ។ ខ្ញុំទៅសាលារៀនឲ្យតែផុតពីផ្ទះ ព្រោះខ្ញុំបានជួបមិត្តភក្តិ និងបានលេងជាមួយគ្នា។ ការសិក្សារបស់ខ្ញុំមិនបានលទ្ធផលល្អដូចក្មេងសង្គមបច្ចុប្បន្ននេះទេ។ មិនយូរប៉ុន្មានខ្ញុំឈប់រៀនហើយឪពុកម្តាយក៏មិនបានស្តីបន្ទោសខ្ញុំដែរ។ ខ្ញុំនៅផ្ទះមើលថែយាយតា និងប្អូនៗរបស់ខ្ញុំនៅពេលឪពុកម្តាយទៅធ្វើស្រែ។

រយៈពេលបីបួនឆ្នាំក្រោយមក ពួកយៀកកុង ឬយួនខាងជើងចូលមកស្រុកភូមិ។ ពួកនេះចូលមកធ្វើបាបកូនក្រមុំស្អាតៗរបស់អ្នកស្រុក។ ស្ត្រីក្រមុំខ្លះបានយកធ្យូងមកប៉ាតលាបមុខរបស់ខ្លួនដើម្បីកុំឲ្យទាហានយៀកកុងឃើញមុខស្អាត។ ថ្ងៃមួយពេលខ្ញុំកំពុងស្ទូងស្រូវ ខ្ញុំឃើញមានរថក្រោះបរកាត់ភូមិ និងឃើញមានកន្ទុំរុយជាច្រើនគ្រឿងរបស់ពួកកងទ័ពវៀតណាមខាងត្បូង ហោះឆាបជុំវិញផ្ទះអ្នកស្រុក និងដេញបាញ់ពួកយៀកកុង ឬកងទ័ពវៀតណាមខាងជើងដែលកំពុងសំងំលាក់ខ្លួន។ ទាហានយៀកកុងបានរត់ចូលផ្ទះអ្នកភូមិមួយខ្នង ហើយកន្ទុំរុយដេញតាមបាញ់ទាហានយៀកកុង រហូតបណ្តាលឲ្យឆេះផ្ទះរបស់អ្នកភូមិមួយខ្នងនោះ និងស្លាប់មនុស្សនៅក្នុងផ្ទះស្ទើរតែទាំងអស់ លើកលែងតែឪពុកនៅឯចម្ការ និងក្មេងម្នាក់ដែលបានរត់ពួនក្រោមជង្រុកស្រូវប៉ុណ្ណោះ។ ក្រៅពីឆេះផ្ទះ នៅមានយន្តហោះខ្លះបានទម្លាក់គ្រាប់បែកនៅក្នុងព្រៃជុំវិញភូមិ។ ឪពុកខ្ញុំបានជីកត្រង់សេបុលេណដ្ឋាននៅក្រោយផ្ទះ ដើម្បីការពារពេលមានការទម្លាក់គ្រាប់បែក។ នៅឆ្នាំ១៩៧២ ពួកយៀកកុងបានកៀរអ្នកភូមិចេញឲ្យទៅរស់នៅក្នុងភូមិមួយទៀតគឺភូមិក្រសាំង ដោយហេតុផលថា «ខ្លាចមានគេបាញ់ផ្លោងត្រូវ»។ ទៅដល់ភូមិក្រសាំង ខ្ញុំនិងឪពុកបានស៊ីឈ្នួលច្រូតស្រូវឲ្យគេ។

នៅឆ្នាំ១៩៧៥ ខ្ញុំប្តូរមករស់នៅឃុំគោកពោធិ៍ ស្ថិតនៅឆ្ងាយពីខេត្តតាកែវ។ នៅទីនោះ ខ្ញុំនេសាទ

ត្រីធ្វើប្រហុក និងធ្វើស្រែដើម្បីទុកហូបខ្លួនឯង។ កាលនោះ ខ្ញុំមានអាយុ១៦ឆ្នាំ។ ចូលដល់ឆ្នាំ១៩៧៧ អង្គការឲ្យយើងមកភូមិកំណើតវិញ និងរស់នៅក្នុងសហករណ៍។ អង្គការចាត់តាំងឲ្យខ្ញុំធ្វើជាកងចល័តនារី។ ម្តាយខ្ញុំមើលគោ ហើយឪពុកខ្ញុំចិញ្ចឹមមាន់ក្នុងកងតាៗ។ ប្រធានកងនារីខ្ញុំឈ្មោះ ប៉ុន ហើយកាចណាស់។ ប៉ុន គ្រប់គ្រងក្នុងកងរយ និងកងហា។ ក្នុងខែវស្សា កម្មាភិបាលឲ្យខ្ញុំឡើងមកលើកភ្លឺស្រែ។ ខ្ញុំដើរពីស្រុកបូរីជលសារ ទាំងយប់ មកដកសំណាបនៅ ឃុំត្រពាំងធំ។ ខ្មែរក្រហមឲ្យដកសំណាបក្នុងម្នាក់ឲ្យបានចំនួន៥ផ្លូនក្នុងមួយថ្ងៃ។ នៅខែប្រាំង ខ្ញុំត្រូវចាត់តាំងឲ្យមកលើកទំនប់ទប់ភ្លឺស្រែនៅអូរពោធិ៍ និងស្ទូងស្រូវនៅបូរីជលសារ។ បន្ទាប់ពីស្បៀយការងារខ្លះ អង្គការឲ្យខ្ញុំមកធ្វើចម្ការ ដាំសណ្តែកដី និងដំឡូង នៅត្រពាំងធំ។ ថ្ងៃមួយ ខ្ញុំមានជំងឺគ្រុនចាញ់។ អង្គការបញ្ជូនខ្ញុំឲ្យទៅសម្រាកនៅពេទ្យឃុំ ស្ថិតក្នុងវត្តជ្រេស។ កម្មាភិបាលពេទ្យ បានឲ្យថ្នាំខ្មែរគ្រាប់ពណ៌ខ្មៅមកខ្ញុំលេប។ ក្នុងពេទ្យនោះ ខ្ញុំឃើញមានប្រដាប់វាស់សម្ពាធឈាម វាស់កម្តៅ និងថ្នាំល្អជាច្រើនមុខ។ ខ្ញុំគិតថា សម្ភារពេទ្យ និងថ្នាំទាំងអស់នោះ ប្រហែលជានាំយកមកពីប្រទេសចិន។ សម្រាកនៅមន្ទីរពេទ្យ ខ្ញុំបានដឹងថា ណាត គឺជានារីពេទ្យឃុំ បានខុសសីលធម៌ជាមួយប្រធានកងសហករណ៍ភូមិ ប៉ុន្តែខ្ញុំភ្លេចឈ្មោះគាត់។ កងឈ្លបបានសម្រាតខោអាវចេញពីខ្លួនអ្នកទាំងពីរ រួចបណ្តើរទៅកាន់ទួលដើងចាប។ នៅតាមផ្លូវកងឈ្លបឲ្យអ្នកទាំងពីរដើរកាត់កន្លែងដែលមានមនុស្សកំពុងធ្វើស្រែ និងឲ្យនិយាយឮៗថា «កុំយកគំរូតាមខ្ញុំ»។ ចាប់តាំងពីថ្ងៃនោះមក ខ្ញុំមិនដែលឃើញអ្នកទាំងពីរនោះទៀតទេ។ ប្រធានឃុំស្រងែឈ្មោះ គ្រិល គឺជាមនុស្សកាចសាហាវណាស់។ ខ្ញុំបានឮថា តាគ្រិល សម្លាប់មនុស្ស រួចវះពោះកាត់យកប្រមាត់ធ្វើថ្នាំ។ ដំបូងឡើយ ខ្ញុំមិនជឿគេនិយាយទេ។ ប៉ុន្តែនៅថ្ងៃមួយ ខ្ញុំបានឃើញអ្នកក្រោមបង្គាប់ តាគ្រិល មកចាប់មនុស្សចងស្លាបសេក រួចបណ្តើរចេញពីភូមិ យកទៅវះពោះទាំងរស់ រួចយកប្រមាត់មកធ្វើថ្នាំពិតប្រាកដមែន។ អ្នកដែលគេចាប់មានឈ្មោះ តាង៉ែត គឺជាមិត្តភក្តិឪពុករបស់ខ្ញុំ។ រឿងសម្លាប់មនុស្សវះពោះនេះ គេធ្វើមិនលាក់បាំងទេ ព្រោះគេចង់ឲ្យយើងឃើញហើយខ្លាច។

នៅឆ្នាំ១៩៧៨ ក្នុងពេលដែលខ្ញុំកំពុងបោកស្រូវនៅអង្គធ្លក និងលើកភ្លឺស្រែនៅបារាយណ៍ ខ្ញុំបានឮអ្នកភូមិនិយាយតគ្នាថា «យួនមករំដោះ! យួនឡើងមកហើយ!»។ អ្នកខ្លះភ័យរត់ទៅលើ។ ចំណែកខ្ញុំតាមរកម្តាយដើម្បីរត់នឹងគេដែរ។ ខ្ញុំរែកអង្ករ ចាន ឆ្នាំង និងខោអាវ។ ម្តាយខ្ញុំរែកកូនៗ និងក្មួយគាត់ដើរតាមក្រោយ។ ពួកយើងដើរទៅរហូតដល់ភ្នំដងរែក ក៏ត្រូវកងទ័ពវៀតណាមប្រាប់ឲ្យមកស្រុកកំណើតវិញ ហើយយើងបានត្រឡប់មកស្រុកកំណើតវិញ និងបានរស់នៅមកដល់សព្វថ្ងៃនេះ។



វាលស្រែនៅក្នុងស្រុកទ្រាំង ខេត្តតាកែវ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ខ្ញុំតែងគិតថា ជីវិតខ្ញុំរស់បានមួយថ្ងៃ នៅមួយយប់ រស់បានមួយយប់ នៅមួយថ្ងៃ

ផាន់ ទីន



មាស សុគន្ធ ផ្តល់បទសម្ភាសន៍អំពីរឿងរ៉ាវក្នុងរបបខ្មែរក្រហម អំឡុងពេលក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជាធ្វើវេទិកាប្រវត្តិសាស្ត្រគ្រួសារ នាខែមេសា ឆ្នាំ២០២៣។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ មាស សុគន្ធ អាយុ៧១ឆ្នាំ ពីដើមខ្ញុំរស់នៅភូមិត្រើយឃ្លោក ឃុំអង្គរាញ់ ស្រុកទ្រាំង ខេត្តតាកែវ បច្ចុប្បន្នខ្ញុំរស់នៅភូមិដដែល ប៉ុន្តែរដ្ឋបាលបានប្តូរមកភូមិត្រើយឃ្លោក ឃុំដូងខ្ពស់ ស្រុកបូរីជលសារ ខេត្តតាកែវ វិញ។ កាលអាយុ៧ឆ្នាំ ខ្ញុំចូលរៀននៅសាលាបឋមសិក្សា ត្រើយឃ្លោក។ ចប់ថ្នាក់ទី៧ ពីសាលាបឋមសិក្សា ត្រើយឃ្លោក ខ្ញុំប្រឡងចូលរៀនបន្តថ្នាក់ទី៦ នៅវិទ្យាល័យ ព្រៃសណ្តែក ឃុំព្រៃស្លឹក ស្រុកទ្រាំង ជាមួយអ្នកភូមិខ្ញុំម្នាក់ទៀត។ នាយកវិទ្យាល័យ ព្រៃសណ្តែក ឈ្មោះលោក សិង ហេ និងនាយករងឈ្មោះលោក ស សុវណ្ណ។ ពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ ខ្ញុំសូមស្នាក់អាស្រ័យផ្ទះរបស់លោកតា ធូ ក្នុងភូមិដើមផ្តៀក ឃុំព្រៃស្លឹក ស្រុកទ្រាំង ហើយថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ ទើបត្រឡប់មកផ្ទះវិញ។ ខ្ញុំនិងមិត្តភក្តិក្នុងភូមិ មកពីឃុំផ្សេងគ្នាចំនួន ២នាក់ បានស្នាក់នៅជាមួយគ្នា។ ក្នុងផ្ទះមានតែលោកតា ធូ, ប្រពន្ធរបស់គាត់ចាស់ជរា និងកូនចិញ្ចឹមម្នាក់ទៀត ដែលនៅចាំមើលថែគាត់ទាំងពីរនាក់។ គ្រួសារគាត់ស្លូតណាស់។ ខ្ញុំនិងមិត្តភក្តិស្នាក់នៅក្នុងផ្ទះគាត់ មិនឲ្យបង់ប្រាក់ឡើយ។ គ្រាន់តែពួកខ្ញុំជួយធ្វើការងារផ្ទះ និងដាំស្លជូនគាត់តែប៉ុណ្ណោះ។

ក្នុងឆ្នាំ១៩៧០ ខ្ញុំជិតនឹងបញ្ចប់ថ្នាក់ទី៥ទៅហើយ។ លុះពេលព្រឹកម៉ោង៧កន្លះ ខ្ញុំដើរទៅរៀនដូចសព្វមួយដង ខ្ញុំឃើញឡានដឹកទាហានចំនួន២គ្រឿង ដឹកចេញពីកំពង់ជ្រៃ ឃុំស្នោង ស្រុកទ្រាំង សំដៅមកព្រៃសណ្តែក។ ភ្លាមនោះស្រាប់តែពួសួរទម្លាក់គ្រាប់បែកនៅថ្នល់បំបែក ឃុំជីខ្មា ស្រុកទ្រាំង។ លើសពីនេះទៅទៀត នៅតាមដងផ្លូវខ្ញុំឃើញប្រជាជនជាច្រើនធ្វើបាតុកម្ម ជាមួយនឹងទាហាន លន់ នល់។ អំឡុងពេលនោះ ខ្ញុំនិងសិស្សក្នុងសាលាបាននាំគ្នាដេរទៅកាន់អ្នកដែលទម្លាក់សម្តេច ព្រះនរោត្តម សីហនុ ប៉ុន្តែត្រូវ លោក ស សុវណ្ណ គឺជានាយករងវិទ្យាល័យ ព្រៃសណ្តែក មកហាមឃាត់ថែមទាំងនិយាយមកកាន់ពួកខ្ញុំថា «ពួកឯងរាល់គ្នាគ្មានដឹងអ្វីទេ គេឲ្យទៅផ្ទះ ឆាប់នាំគ្នាត្រឡប់ទៅផ្ទះវិញទៅ កុំនៅ!»។ ខ្ញុំនិងសិស្សក្នុងសាលាទាំងអស់ក៏បំបែកគ្នាមកផ្ទះវិញ មានតែសិស្សនៅទីនោះប៉ុណ្ណោះដែលចូលរួមធ្វើបាតុកម្ម។ ខ្ញុំសំណាងណាស់ដែលបានត្រឡប់មកផ្ទះវិញ ប្រសិនជាចូលរួមធ្វើបាតុកម្មពួកខ្ញុំប្រហែលជាស្លាប់បាត់បង់

ជីវិតជាមិនខាន។ មនុស្សជាច្រើនស្លាប់យ៉ាងរង្គាល ក្នុងពេលធ្វើបាតុកម្មនោះ។

ក្នុងឆ្នាំ១៩៧១ ខែកត្ដិកធ្លាក់ខ្យល់ មានខ្មែររំដោះស្លៀកពាក់ខោអាវខ្មៅ មកបំពាក់បំប៉ននិងនិយាយថា «គេតម្រូវឱ្យអ្នកនៅលីវ តស៊ូទៅធ្វើជាកងទ័ពឡើងភ្នំ ដើម្បីរំដោះជាតិ»។ មេក្រុមកងទ័ពរំដោះម្នាក់បាននិយាយថា «មិនបានទេ ខែនេះមិនទាន់ឡើងទៅបានទេ នៅក្មេងខ្ចី ឡើងភ្នំខែរងាចឹងចាញ់ស្លាប់នៅទីនោះអស់ជាមិនខាន»។ ដោយសារឪពុកម្ដាយខ្ញុំខ្លាចគេយកខ្ញុំទៅធ្វើកងទ័ព គាត់ក៏ផ្សំផ្គុំឱ្យខ្ញុំរៀបការជាមួយអ៊ុយ សំអុល។ ក្រោយពីខ្ញុំរៀបការរួច មេភូមិក៏មកប្រាប់អ្នកមិនទាន់រៀបការ ឬអ្នកនៅលីវទៅធ្វើកងទ័ព។ ក្នុងភូមិខ្ញុំជាង១០នាក់ ត្រូវបានគេយកទៅបាត់ទាំងអស់ សព្វថ្ងៃមិនឃើញត្រឡប់មកវិញទេ។

ក្នុងឆ្នាំ១៩៧៣ ខ្មែរក្រហមចុះមកកៀរប្រជាជនឱ្យនៅត្រឹមឃុំគោកពោធិ៍ ស្រុកបូរីជលសារ។ មកដល់គោកពោធិ៍ធ្វើស្រែបានរយៈពេលពីរខែ មិនទាន់បានទាំងប្រមូលផលផង ទាហាន លន់ នល់ មកកៀរឱ្យទៅនៅទីរួមខេត្តតាកែវ។ ប្រជាជនច្រើនណាស់បានរស់នៅកកកុញក្នុងខេត្ត មានទាំងលក់ដូរ ធាក់ស៊ីក្លូ និងរបរផ្សេងៗទៀត។ ខ្ញុំបានសង់តូបតូចមួយ ដើម្បីលក់នំក្នុងដីមួយកន្លែងមុខម៉ាស៊ីនអូតាវ ស្ថិតក្នុងសង្កាត់រកាក្នុង ក្រុងដូនកែវ។ រាល់ថ្ងៃមនុស្សទាំងនោះតែងគេចគ្រាប់ផ្លោងពីទ័ពខ្មែរក្រហមដែលនៅព័ទ្ធជុំវិញទីរួមខេត្ត។ ខ្ញុំនិងប្រជាជនផ្សេងទៀតនាំគ្នារត់ចូលទៅពួនក្នុងត្រង់សេប្រុលេណដ្ឋាន អ្នកខ្លះលូនក្រាបនៅលើដី។ មនុស្សច្រើនណាស់ ស្លាប់កំឡុងពេលខ្មែរក្រហមផ្លោងគ្រាប់មក ព្រោះពួកគេរត់មិនទាន់។ ដើមឡើយបងថ្លៃខ្ញុំជាអ្នកកសិកម្ម ក្រោយមកចូលបម្រើជាទាហាន លន់ នល់ បានក្លាយជាអនុប្រធានកងទ័ព គ្រប់គ្រងទាហានចំនួន ៥០០នាក់។ ក្រោយពីខ្មែរក្រហមវាយបែកទីក្រុងភ្នំពេញភ្លាម បងថ្លៃខ្ញុំបានដំណឹងពីតេអូ (វិទ្យុទាក់ទង) រួចមកប្រាប់ឪពុកក្មេកខ្ញុំថា «បងប្អូនទាំងអស់យើងចាញ់គេហើយ ពេលណាខ្មែរក្រហមចូលមកដល់ គេឱ្យទៅណាទៅតាមគេ កុំទទឹងមុខសឹក។ មានតែផ្លូវមួយទេគឺ ផ្លូវអង្គតាសោម បើរត់ក្រៅពីផ្លូវនេះ គេនឹងយកទៅវាយសម្លាប់ចោល»។ ព្រឹកព្រលឹមស្រាងៗ ទ័ពខ្មែរក្រហមចូលមកដល់ទីរួមខេត្តតាកែវ។ ប្រជាជនជាង១០០នាក់រត់សំដៅទៅខាងកើតតាកែវ ឆ្លងកាត់ភូមិអង្គរាញ់ ត្រូវខ្មែរក្រហមចាប់បានសម្លាប់ចោលទាំងអស់។ ប្រជាជនចំនួន៧០នាក់រត់ទៅទិសខាងត្បូងតាកែវ មកដល់ទីវាលភូមិខ្ញុំ ត្រូវខ្មែរក្រហមសម្លាប់ចោល។ សព្វថ្ងៃអ្នកភូមិហៅទីកន្លែងនោះថា ត្រពាំងចិតសិប។ ពួកខ្ញុំរត់តាមផ្លូវអង្គតាសោម រួចខ្មែរក្រហមប្រមូលផ្តុំដាក់នៅវត្តចំប៉ាលើ។ បន្ទាប់ពីផ្តុំគ្នានៅវត្ត ខ្មែរក្រហមចាត់ឱ្យស្រង់ឈ្មោះអ្នកធ្វើការទាំងអស់ដែលចេញពីខេត្តតាកែវ យកទៅសម្លាប់ចោល។ មួយខែក្រោយមក ខ្មែរក្រហមឱ្យយើងមកភូមិស្រុកវិញ។ លុះបានមួយសប្តាហ៍ ឪពុកក្មេកខ្ញុំជាមេឃុំអង្គរាញ់ និងគ្រួសារគាត់ព្រមទាំងកូនក្មួយ៤នាក់ ខ្មែរក្រហមយកទៅសម្លាប់ចោលទាំងអស់។ មួយសប្តាហ៍ក្រោយមក ខ្ញុំសម្រាលបានកូនស្រីម្នាក់ដោយដាក់ឈ្មោះ ចន្ថា។ ប្រធានកងឱ្យខ្ញុំធ្វើម៉ែដោះ ព្រមទាំងមើលកូនតូចចំនួន៧នាក់។ រយៈពេលបីខែ អង្គការផ្ទេរឱ្យលោកយាយ យ៉ាន មើលក្មេងៗជំនួសខ្ញុំវិញ។ ខ្មែរក្រហមជម្លៀសឱ្យធ្វើការតាមភូមិ និងចាត់ខ្ញុំជាប្រជាជន១៧មេសា។ ពួកអ្នកពេញសិទ្ធិដៀល និងបោះពាក្យសម្តីមកលើពួកខ្ញុំថា «ពួកឈ្លើយសឹក ពួក១៧ ពួកទមិឡផ្តតសាសនា» ខ្ញុំមិនតបតនឹងប្រជាជនពេញសិទ្ធិវិញឡើយ។ នៅបានមួយឆ្នាំ អង្គការបានបំបែកខ្ញុំនៅជាមួយអ្នកមូលដ្ឋានឯភូមិខាងលិច ដោយមួយភូមិមានចំនួន១០គ្រួសារ។ អង្គការឱ្យខ្ញុំរែកដីដំបូក ធ្វើជី និងទប់ភ្លឺស្រែ២នាក់ទំហំ៥០ម៉ែត្រក្នុងមួយថ្ងៃ។ ខ្ញុំរែកដីដាក់តែតិចៗប៉ុណ្ណោះ ព្រោះខ្ញុំខ្លាចទាស់។ ខែវស្សាដកស្រូវក្នុងម្នាក់ចំនួន២ផ្លូន ស្ទូងមួយកុងគ្នា ២នាក់ និងប្រូតមួយកុងគ្នា ២នាក់។ ក្នុងឆ្នាំ១៩៧៧ ខ្មែរក្រហមប្រមូលយាយៗ និងមីងៗទៅប្រជុំនៅវត្តក្រាំងដៃ ស្រុកទ្រាំង។ ខ្ញុំគិតក្នុងចិត្តថាម្តងនេះខ្ញុំដឹងតែស្លាប់ហើយ តែបន្ទាប់ពីឮថាអង្គការយកតែម៉ែ ដោយកូនទុកនៅយាយៗមើល ខ្ញុំក៏បានធូរ

ចិត្តវិញ។ ពេលប្រជុំអង្គការនិយាយថា«ពេលនេះគេចម្រាញ់អស់ហើយ នៅតែអ្នកធ្វើបដិវត្តន៍ប៉ុណ្ណោះ អស់ទាំងទមិ ឡអស់ទាំងខ្មាំង»។ ក្នុងអំ ឡុងពេលហៅមីងៗទៅប្រជុំ អង្គការក៏ប្រមូលពូៗទៅប្រជុំក្នុងពេលតែមួយដូចគ្នា។ ប្ដីខ្ញុំត្រូវអង្គការយកទៅសម្លាប់ក្នុងពេលហៅប្រជុំនោះ ដោយឪពុកគាត់គឺជាមេឃុំ។ មុនបែកខ្មែរក្រហម ប្រធានកងជប់លៀងធ្វើនំបញ្ចុកហូបខ្ញុំហូបបាន២ថ្ងៃ។ បែកខ្មែរក្រហមខ្ញុំរត់ទៅដល់ភ្នំដំរីរមៀល ជួបនឹងទ័ពវៀតណាមស្កាត់នៅពីមុខ ពួកកងទ័ពវៀតណាមឲ្យគ្រ ឡប់មកផ្ទះវិញ។ បន្ទាប់មកខ្ញុំនៅមិនបានមួយខែ ខ្មែរក្រហមកៀរឲ្យយើងរត់ទៅម្ដងទៀត។ ខ្ញុំរត់ទៅដល់អង្គតាសោម កងទ័ពវៀតណាមស្ទាក់ឲ្យត្រ ឡប់មកស្រុកកំណើតដោយប្រកបរបរធ្វើស្រែចម្ការវិញ។



ផ្ទះរបស់ប្រជាជននៅក្នុងស្រុកទ្រាំង ខេត្តតាកែវ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ប្រជាជនថ្នាក់កណ្ដាលទទួលរងការកៀបសង្កត់ដូច អ្នក១៧ និង អ្នកថ្មី

*ឌីម សុខគា*



សេក អ៊ីម ផ្ដល់បទសម្ភាសន៍អំពីរឿងរ៉ាវក្នុងរបបខ្មែរក្រហម អំឡុងពេលក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា ធ្វើវេទិកាប្រវត្តិសាស្ត្រគ្រួសារ នាខែមេសា ឆ្នាំ២០២៣។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ សេក អ៊ីម បច្ចុប្បន្នរស់នៅភូមិត្រើយឃ្លោក ឃុំដូនខ្ពស់ ស្រុកបូរីជលសារ ខេត្តតាកែវ។ សព្វថ្ងៃមានអាយុ៧៤ឆ្នាំ ហើយខ្ញុំគឺជាប្រធានភូមិត្រើយឃ្លោក។ តាំងពីកុមារ ខ្ញុំចូលរៀនត្រឹមថ្នាក់ទី៧ នៅសាលាវត្តត្រើយឃ្លោក។ កាលពីដើមសាលារៀនមានត្រឹមតែថ្នាក់ទី៧ មានគ្រូបង្រៀនត្រឹមត្រូវ សាលាប្រក់ក្បឿង ជញ្ជាំងស្លឹកត្នោត គ្រូបង្រៀនកាលពីសម័យមុនគាត់កាច ប៉ុន្តែគាត់មានការពន្យល់ច្រើន កូនសិស្សណាមិនគោរពគ្រូនឹងដាក់ទណ្ឌកម្ម។ កាលខ្ញុំនៅរៀនជុំគ្រួសារជាមួយឪពុកម្ដាយ ខ្ញុំមានបងប្អូនចំនួន៤នាក់ ប៉ុន្តែពួកគាត់ស្លាប់តាំងពីនៅកុមារតូចៗអស់ហើយ ឡូវនៅតែខ្ញុំតែម្នាក់ឯងប៉ុណ្ណោះ។ ខ្ញុំមានផ្ទះសម្បែងរស់នៅ ហើយការហូបចុកគ្រប់គ្រាន់។ កាលពីដើមមុខរបរសម្រាប់គ្រួសារខ្ញុំ និងប្រជាជនទាំងអស់ដែលរស់នៅក្នុងភូមិត្រើយឃ្លោកគឺធ្វើស្រែ។

បន្ទាប់មកចូលឆ្នាំ១៩៦៦ ខ្ញុំបួសជាព្រះសង្ឃបានចំនួនពីរព្រះវស្សានៅវត្តត្រើយឃ្លោក។ ខ្ញុំរៀបការក្នុងឆ្នាំ១៩៦៨ ។ សព្វថ្ងៃខ្ញុំមានកូនចំនួន៩នាក់ ស្រីម្នាក់ប្រុសចំនួន៨នាក់ហើយប្រពន្ធខ្ញុំស្លាប់ក្នុងឆ្នាំ២០១៦ ដោយសារជំងឺ។

ឆ្នាំ១៩៧០ មានសង្គ្រាមក្នុងរបប លន់ នល់ យន្តហោះដឹកគ្រាប់ចូល ភូមិត្រើយឃ្លោកនេះគឺជាកន្លែងទ័ពប្រយុទ្ធគ្នា មានទ័ពយៀកកុង ប៉ុ យួនខាងជើង ក៏បានប្រយុទ្ធគ្នានៅកន្លែងនេះដែរ។ របប លន់ នល់ ខ្ញុំធ្វើជាកសិករ ការហូបចុកមិនសូវមានការខ្វះខាតទេខ្ញុំអាចធ្វើស្រែបាន។

ឆ្នាំ១៩៧១ដល់ឆ្នាំ១៩៧២ ខ្មែររំដោះបានជម្លៀសខ្ញុំ និងប្រជាជនទាំងអស់ដែលរស់នៅក្នុងភូមិត្រើយឃ្លោក និងប្រជាជនរស់នៅភូមិផ្សេងៗទៀតចេញពីភូមិទាំងអស់។ ការជម្លៀសមុនដំបូងគេឲ្យទៅនៅព្រៃផ្គាំរួចបន្តទៅតាម៉ូងរយៈពេលមួយឆ្នាំ។ ក្រោយ

មកខ្ញុំទៅនៅទួលក្រសាំងដែលស្ថិតនៅស្រុកអង្គរបូរី ទៅរយៈពេលពីរឆ្នាំទើបត្រឡប់មកវិញ។ ខ្មែររំដោះមិនសូវឲ្យខ្ញុំមកស្រុកភូមិវិញទេ បើមកបានមានតែប្រុសៗ ២០ ទៅ ៣០នាក់ មកបានតែពេលយប់នាំគ្នាសម្រាន្តដឹកជង្ហុកចាំគេចតែគ្រាប់នៅជិតៗនោះ ភូមិត្រើយឃ្លោកនេះពោរពេញទៅដោយព្រៃគ្មាននរណាហ៊ានចូលក្នុងភូមិនេះវិញទេ។ ការទៅរស់នៅស្រុកអង្គរបូរី ហូបចុកមិនដែលជួបផលវិបាកអ្វីទេ ខ្ញុំបានប្រវាស់ដីអ្នកភូមិធ្វើស្រែ។ ក្រោយមកខ្ញុំរត់គេចទៅនៅតានីដែលស្ថិតនៅក្នុងខេត្តកំពតរយៈពេលកន្លះខែ បានធ្វើដំណើរតាមរទេះគោ ហើយអ្នកដែលគ្មានរទេះគឺរែកអីវ៉ាន់ដើរមិនមានកង់ម៉ូតូអ្វីទេ។

ឆ្នាំ១៩៧៥ នៅពេលថ្ងៃអង្គការប្រើឲ្យខ្ញុំរកត្រីឲ្យសហករណ៍ធ្វើម្ហូប ពេលយប់គេឲ្យរែកដីធ្វើប្រឡាយនៅទំនប់ប្រវត្តិសាស្ត្រដែលស្ថិតក្នុងស្រុកបូរីជលសារ ហើយការហូបចុកមិនបានគ្រប់គ្រាន់ទេ។ ការជីកប្រឡាយមានមនុស្សមកពីខេត្តតាកែវ កំពត កំពង់ស្ពឺ និងខេត្តកណ្ដាល។ គេធ្លាប់ធ្វើបាបខ្ញុំដែរ ព្រោះខ្ញុំមានជីវភាពថ្នាក់កណ្ដាល គេកៀបសង្កត់ស្មើនឹងអ្នកផ្ញើ និងដូចអ្នក១៧ដែរ។ តាមពិតទៅខ្ញុំជាអ្នកមូលដ្ឋាន ទេព្រោះខ្ញុំជាប់ពាក់ព័ន្ធជាមួយបងប្អូន ដែលគាត់ធ្លាប់ធ្វើជាទាហានដូច្នេះហើយ គេតាមដានខ្ញុំរហូតក្រែងមានបញ្ហាក្បត់។ ខ្ញុំធ្លាប់ត្រូវគេចាប់យកទៅមន្ទីរកសាងពីរដងនៅមន្ទីរនីរសារ នៅក្រាំងល្វៀង។ អង្គការបាននិយាយថា«យើងប្រជាជនវណ្ណៈកណ្ដាល ការលះបង់មិនជ្រះស្រឡះទេ» ការប្រជុំផ្សេងៗខ្ញុំមិនដែលចូលរួមទេ ខ្ញុំនៅតែព្រៃ នៅតែវាលបឹងរកត្រី។ បើសម្លៀកបំពាក់អង្គការចែកឲ្យក្នុងមួយឆ្នាំម្នាក់បានពីរ សម្រាប់មានខោអាវខ្មៅៗ។ នៅភូមិត្រពាំងសំរោង គេដាក់សុទ្ធតែពួក១៧ សុទ្ធតែទាហាន ខ្ញុំឮថាបាត់ខ្លួនមួយៗដែរ បើគេយកប្ដី ឬប្រពន្ធទៅគឺបាត់ខ្លួនរហូត។ ក្រោយមកបានបញ្ជូនក្រុមគ្រួសាររបស់បងជីដូនមួយខ្ញុំនៅក្បែរកោះអណ្ដែតធ្វើការនៅការដ្ឋាន គេប្រាប់ថា «ឲ្យមកលេងស្រុកឲ្យមករស់នៅស្រុកភូមិវិញ» ក្រោយមកខ្ញុំបានដំណឹងថាបងប្អូនរបស់ខ្ញុំត្រូវគេយកទៅសម្លាប់មួយគ្រួសារនៅក្រាំងតូចនៅខាងកើតវត្តព្រៃឈើទាល។ ក្រៅពីនេះក៏មានបងប្អូនជីដូនមួយឈ្មោះគុណ គេយកទៅសម្លាប់ដោយសារគាត់ធ្វើជាទាហាន។

ឆ្នាំ១៩៧៦-១៩៧៨ នៅភូមិត្រើយឃ្លោកនេះដាក់ជារួម ពេលហូបបាយទៅហូបនៅត្រយឹង នៅក្បែរគ្នាជាមួយភូមិត្រើយឃ្លោកដែរ។ ចាប់ពីខែកក្កដាដល់ខែសីហា គេឲ្យហូបតែបបរ បើបានបាយហូបបានតែក្នុង ខែតុលា វិច្ឆិកា និងខែធ្នូ គឺជាខែប្រមូលផលស្រូវ អង្គការឲ្យហូបបានគ្រប់គ្រាន់ជាមួយសម្លព្រលិតស្ល ទាំងសំបកហាន់ទាំងកង់ៗ និងត្រកួនដែលបេះមកពីបឹង។ កូនៗបើធំៗទៅធ្វើការតាមកងកុមារ យាយតាគាត់នៅផ្ទះមើលថៅចៅៗ។ ខ្ញុំធ្វើការនៅក្នុងកងនេសាទ មានតែសំណាញ់មួយ គេបានកំណត់រយៈពេលដប់ថ្ងៃ ទើបបានមកលេងផ្ទះម្ដង គេឲ្យមកតែពេលយប់ទេ ពេលព្រឹកត្រូវដល់កន្លែងធ្វើការវិញ។ ខ្ញុំដើររកត្រី ដើរបង់សំណាញ់ អួសអួន និងដាក់មង។ ប៉ុន្តែខ្ញុំនៅក្រុមតូចមួយ ក្រុមមានមនុស្ស១២នាក់ធ្វើរោងតូចមួយសម្រាប់រស់នៅជុំគ្នា អង្ករគេចែកកំណត់ឲ្យក្នុងមួយពេលបានអង្ករបីកំប៉ុង ប៉ុន្តែក្រុមខ្ញុំបានម្ហូបយ៉ាង គេឲ្យហូបបបរដែលគោកៗវាមិនរាវពេកទេ ហើយខ្ញុំរកត្រីរហូតដល់បែកតែម្ដង។ ពីដើមមានមន្ទីរពេទ្យចំនួនពីរកន្លែង នៅវត្តខ្សារកកោះមួយកន្លែង និងវត្តសរសៃមានបុណ្យមួយកន្លែង។ វត្តត្រើយឃ្លោក គេដាក់ធ្វើជាមន្ទីរស្រុក១០៧ អង្គការដាក់ធ្វើជាកន្លែងស្លូឱសថ យកទឹកដូងធ្វើជាសេរ៉ូម សម្រាប់ដាក់ឲ្យអ្នកជំងឺ និងដាក់ជាកន្លែងផលិតស្រា។ ប្រជាជនដែលស្លាប់ គេយកទៅបញ្ចុះនៅព្រៃខ្មោចដែលនៅក្បែរវត្តត្រើយឃ្លោក ហើយពេលមានសាកសពកងទ័ពស្លាប់ គេយកទៅទុកនៅឃុំដូងខ្ពស់មួយកន្លែង។

ឆ្នាំ១៩៧៩ ពេលជិតបែកខ្ញុំបានរត់ទៅដល់វត្តអង្គរលាយ ខ្មែរក្រហមបានកៀរឡើងទៅភ្នំទៅរយៈពេលដប់ថ្ងៃ។ ពេលទ័ពវៀតណាមវាយចូលមកដល់វត្តអង្គរលាយ ហើយកងទ័ពវៀតណាមបាននិយាយថា «ពុកម៉ែអើយអញ្ជើញទៅផ្ទះវិញ»។

ការហូបចុកខ្ញុំត្រៀមអង្ករទុករហូតយកប្រហុកពីឡទឹកត្រីប្រហែល១០គីឡូយកទៅហូបបណ្ដោះអាសន្ន។ ក្រោយបែកឆ្នាំ១៩៧៩ ខ្ញុំបានមករស់នៅក្នុងស្រុកភូមិវិញឪពុករបស់ខ្ញុំគាត់កាលពីរបបខ្មែរក្រហមធ្វើជាងផ្ទះ គាត់បានសង់ផ្ទះឡើងវិញរស់នៅជួបជុំគ្រួសារ។ ផ្ទះរបស់ប្រជាជនមួយចំនួនក៏ខូចខាតដោយសារការទម្លាក់គ្រាប់បែក។ ក្នុងភូមិត្រើយឃ្លោកនេះ ផ្ទះរបស់ប្រជាជនចំនួន ២០ផ្ទះ ត្រូវគេរុះរើយកទៅធ្វើសហករណ៍ នៅសល់តិចតួចណាស់។ ក្រោយមកគេធ្វើស្រែក្រុមសាមគ្គី ឬក្រុមប្រវាស់ដៃ ប្រមូលស្រូវបានមកវាល់ចែកស្មើៗគ្នាគ្រប់សមាជិកក្នុងគ្រួសារ។ គេបែងចែកទៅតាមកម្លាំងមួយ និងកម្លាំងពីរ កុមារគេដាក់ចូលក្នុងកម្លាំងទីពីរ។ ក្រោយបែកបានរយៈពេលពីរឆ្នាំគេបានចែកដី។ កាលនោះសមាជិកគ្រួសាររបស់ខ្ញុំទាំងអស់មានប្រាំបួននាក់។



ផ្លូវលំនៅក្នុងស្រុកបូរីជលសារ ខេត្តតាកែវ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំបានប្រាប់កូនចៅជំនាន់ក្រោយពេលបែកថ្មីៗ នៅមានភស្តុតាងបញ្ជាក់ មានជង្ហុកអាបេ ជង្ហុកគ្រាប់ និងជង្ហុក ត្រង់សេនៅសល់ពេញដី។ ពេលបច្ចុប្បន្នលែងមានទៀតប្រជាជនលុបធ្វើជាស្រែអស់។ ក្រោយមកខ្ញុំដាស់តឿនកូនចៅជំនាន់ក្រោយកុំឲ្យសេពគ្រឿងញៀន ឲ្យខិតខំប្រឹងប្រែងរៀនសូត្រ។ ការហូបចុកមិនមានការខ្វះខាតទៀតទេ ឃើញថាប្រជាជនក្នុងភូមិមានជីវភាពគួរសម ហើយមិនសូវមានភាពខ្វះខាតដូចមុនមានផ្ទះសម្បែងរស់នៅ។ ប្រជាជនក្នុងភូមិចេះជួយយកអាសាគ្នាទៅវិញទៅមក មកដល់បច្ចុប្បន្ន មិនដែលមានបញ្ហាអ្វីគឺមានភាពសុខសប្បាយ។



ដៃទន្លេនៅក្នុងស្រុកបូរីជលសារ ខេត្តតាកែវ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ការជម្លៀសរបស់ប្រជាជនត្រៀមនៅក្នុងរបបខ្មែរក្រហម

**ឌីម សុខគា**



សោម ទឹម ផ្តល់បទសម្ភាន៍អំពីរឿងរ៉ាវក្នុងរបបខ្មែរក្រហម អំឡុងពេលក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា ធ្វើវេទិកាប្រវត្តិសាស្ត្រគ្រួសារ នាខែមេសា ឆ្នាំ២០២៣។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ សោម ទឹម អាយុ៧២ឆ្នាំ សព្វថ្ងៃរស់នៅភូមិបឹងម្កាក់ ឃុំត្រាំកក់ ស្រុកត្រាំកក់ ខេត្តតាកែវ។ ខ្ញុំរស់នៅជុំជាមួយឪពុកម្តាយ និងយាយ។ ខ្ញុំមើលថែយាយរបស់ខ្ញុំរហូតគាត់បានចែកឋាន។ ជីវភាពក្នុងគ្រួសារខ្ញុំហូបចុកគ្រប់គ្រាន់មិនមានភាពខ្វះខាតឡើយ ក្នុងអំឡុងពេលនោះ។ ខ្ញុំរៀបការជាមួយគ្រួសារខ្ញុំឈ្មោះ ទូន សេម ក្នុងឆ្នាំ១៩៨០។ ខ្ញុំមានកូនចំនួន៧ នាក់ស្រី៣នាក់ និង ប្រុស៤នាក់។

ប្អូនប្រុសរបស់ខ្ញុំឈ្មោះ សោម ទៀប ធ្វើទាហានលន់ នល់ គាត់បានស្លាប់ក្នុងពេលប្រយុទ្ធគ្នានៅ ស្ទឹងស។ ក្រោយបែកភ្នំពេញឆ្នាំ១៩៧៥ ខ្មែរក្រហមបានជម្លៀសខ្ញុំ និងប្រជាជនផ្សេងទៀតឲ្យទៅរស់នៅផ្តុំគ្នាក្នុងផ្សារត្រាំកក់ ព្រមទាំងឲ្យយកសម្ភារមួយចំនួនទុកម្តុំក្នុងផ្ទះ តាណែម ភូមិត្រពាំងរំពាក់ និងសម្ភារមួយចំនួនទៀតបោះបោលក្នុងត្រពាំង។ ខ្មែរក្រហមចាត់ខ្ញុំជាប្រជាជនត្រៀម។ ប្រធានឃុំត្រាំកក់ឈ្មោះ ច្រឹប គាត់គឺជាប្រជាជនពេញសិទ្ធិ។ បងប្អូនប្រុសខ្ញុំទាំងពីរត្រូវខ្មែរក្រហមសម្លាប់ បងប្រុសខ្ញុំឈ្មោះ សោម អ៊ុន គាត់គឺជាប្រធានភូមិ និងប្អូនប្រុសឈ្មោះ សោម គន ធ្វើជាឈ្លបឃុំគេចាប់ពួកគាត់ទាំងពីរ «និយាយថាគេយកទៅកសាង» ដោយសារពួកគាត់ប្រឆាំងនឹងអង្គការ។ ខ្ញុំបែកពីឪពុកម្តាយ ព្រោះគេបញ្ជូនខ្ញុំក្នុងកងនារី ខេត្តកំពង់ស្ពឺ។ ខ្ញុំដើរកាប់ឈើ រែកដី ទាំងថ្ងៃ ទាំងយប់គ្មានពេលសម្រាក។ ទីនោះខ្ញុំហូបចុកមិនបានឆ្អែតទេ បើយើងហ៊ាននិយាយ ហូបមិនឆ្អែតមានតែចង់បានត្បូងចប។ រយៈពេល៣ខែអង្គការឲ្យខ្ញុំមកជីកទំនប់រហូតដល់ខេត្តកំពត។ ប្រហែលជារយៈពេលបីខែ អង្គការផ្លាស់ខ្ញុំទៅឆ្ងាយ ខ្ញុំដើរពីត្រពាំងអណ្តើក និងអូរសារាយ ទើបដល់ទំនប់ទួលគ្រួស ដើម្បីទប់ស្ទឹងស្លាគូ។ រយៈពេល ២ទៅ៣ខែ អង្គការតែងផ្លាស់ខ្ញុំទៅកន្លែងមួយទៀត ហើយនៅតាមកងនីមួយៗ មានមនុស្សច្រើនណាស់។ រយៈពេល៣ខែទៀត ខ្ញុំចូលធ្វើការក្នុងកងចល័តនៅ ខ្លាជល់ អង្គការឲ្យខ្ញុំជីកប្រឡាយបានរយៈពេលពីរខែ គេបញ្ជូនខ្ញុំមកក្បាលពោធិ៍។ ខ្ញុំ

ជិះទូករយៈពេល៦ម៉ោងពីខ្លាជល់ មកដល់ក្បាលពោធិ៍ ធ្វើស្រែប្រាំង អង្គការឲ្យស្ទូង និងច្រូត។ ចេញពីធ្វើស្រែប្រាំងបានរយៈពេល៣ខែ ខ្ញុំត្រូវអង្គការបញ្ជូនទៅបូព៌ាធ្វើកងទ័ពចល័ត រៀនពីរបៀបច្បាំង ជញ្ជូនបាយ ជញ្ជូនគ្រាប់ឲ្យកងទ័ព សែងអ្នកជំងឺនិងអ្នកត្រូវរបួស។ ខ្ញុំសែងអ្នករបួសទៅព្យាបាល ហើយមន្ទីរព្យាបាលនោះមាននៅផ្សារត្រាំកក់មួយកន្លែង និងនៅអង្គរនាបមួយកន្លែង។ ក្មួយខ្ញុំម្នាក់ពុលអាហារ សែងទៅពេទ្យរយៈពេលមួយយប់ក៏ស្លាប់។ ប្រធានកងរបស់ខ្ញុំឈ្មោះ អ៊ីតឿ គាត់គឺជាកូនរបស់ តាប៉ោក។

ឆ្នាំ១៩៧៨ ខ្ញុំមករស់នៅស្រុកភូមិ អង្គការឲ្យខ្ញុំកាន់ខាងសេដ្ឋកិច្ច ដាំដំណាំ ដាំបន្លែ។ ខ្ញុំដាំបន្លែទៅតាមប្រជាជនគ្រប់ភូមិដែលស្នើឲ្យខ្ញុំដាំ។ គេឲ្យដាំដំណាំនៅព្រៃរំដួលក្បែរជើងភ្នំដំរីរមៀល និងអូរអាចម៍ទន្សាយ។ ដំណាំដែលដាំបាន អង្គការណែនាំមិនឲ្យលួចបេះហូបប៉ុន្តែទុកជារបស់រួម បើលួចហើយអង្គការដឹងនឹងយកទៅកសាង។ ក្រៅពីដាំដំណាំ អង្គការឲ្យខ្ញុំចិញ្ចឹមគោ៤ទៅ៥នឹមទៀត និងមានរទេះមួយ ទុកដឹករបស់របរផ្សេងៗ។ កាលនោះខ្ញុំមានតួនាទីគឺជាប្រធានមើលថែពួក១៧ ចំនួន៣០នាក់ ពួកគាត់ទាំងអស់ជាពួក ១៧ និងពួកត្រៀមសុទ្ធតែប្រជាជនមកពីភ្នំពេញ និងមានជីវភាពធូរធារ។ គេធ្វើបាបពួក១៧ ខ្លាំងណាស់ ឲ្យហូបមិនគ្រប់គ្រាន់។ ប៉ុន្តែពេលធ្វើការងារលែងកើតរបបអាហារឲ្យហូបបបរ និយាយថា «ពួកខ្ជិល»។ ពេលឃុំហៅខ្ញុំទៅប្រជុំម្តងៗ គេសួរខ្ញុំថាពួកខ្ជិលៗដេកនៅរោងវែងសុទ្ធតែពួកខ្ជិលពួក១៧។ ខ្ញុំឆ្លើយថា គ្មានខ្ជិលទេ វាខ្សាហ៍ណាស់។ ខ្ញុំនិយាយប្រាប់ពួក១៧ នាំគ្នាហូបអីបានបេះ តែហូបទៅកុំឲ្យតែ ឈ្លបឃើញបានហើយ។ អង្គការតាមដានថាពួក១៧រស់នៅដូចជ្រូក គេឲ្យទៅប្តូរផ្សាក៏មិនទៅ ការប្រជុំគេឲ្យទៅក្នុងមួយសប្តាហ៍ម្តង។

ឆ្នាំ១៩៧៩ ខ្ញុំឮសូរកាំភ្លើង ប៉ុន្តែខ្ញុំមិនរត់ទៅណាទេ ខ្ញុំចេះតែគេចនៅក្បែរៗភូមិ។ នៅពេលយប់ប្រជាជនត្រៀម និងអ្នកផ្ញើ សម្រាន្តពេញរោងខ្ញុំត្រូវនៅយាមពួកគាត់។ អ្នក១៧ និងអ្នកផ្ញើដើរចាប់កូនកង្កែប ត្រី ក្តាម យកមកអាំងហូប។ ខ្ញុំឃើញគេធ្វើបាបពួក១៧ និងឃើញមួយយប់ៗ យកទៅសម្លាប់ច្រើនៗ បើខ្ញុំគេយកទៅវាយចោល ១ដងទៅហើយ ខ្ញុំមិនដែលធ្វើអ្វីខុសទេ គេឲ្យខ្ញុំទៅប្តូរផ្សា ព្រោះខ្ញុំបានប្រឆាំងនឹងគេ ខ្ញុំបាននិយាយថា «បើយើងអត់ពេញចិត្តឆ្លើយថាអត់ពេញចិត្ត យើងកុំខ្លាចគេវាយចោល ទោះបីគេយកយើងទៅណាក៏ដោយ» អ្នករស់នៅក្នុងផ្ទះជាមួយខ្ញុំយំពេញផ្ទះថាគេយកខ្ញុំទៅវាយចោលបាត់ហើយ។ គេតែងបទចម្រៀង«កម្មសិទ្ធិសមរម្យមានតែស្បោងមួយតូច» ខ្ញុំមានសាក់កាដូតូចមួយ មានស្បែកជើងកង់ឡានមួយគូ ដើរឡើងពងជើងអស់ហើយ។ ស្ត្រីៗស្លៀកសំពត់ ឯបុរសៗស្លៀកខោ។ គេចែកក្នុងម្នាក់ពីរសម្រាប់ខោអាវខ្មៅ សំពត់ខ្មៅកន្សែងមួយ។

ក្រោយបែកឆ្នាំ១៩៧៩ ខ្ញុំមករស់នៅស្រុកភូមិវិញ ប៉ុន្តែចូលមកគ្មានផ្ទះសម្បែងទេ មុនដំបូងខ្ញុំធ្វើខ្ទមតូចមួយសម្រាប់រស់នៅ។ គេបែកចែកដីឲ្យខ្ញុំ និងប្រជាជនផ្សេងទៀត ជាកម្មសិទ្ធិក្នុងម្នាក់ទទួលបាន១២កុង។ មកដល់សម័យបច្ចុប្បន្ន ខ្ញុំណែនាំកូនចៅឲ្យខិតខំប្រឹងប្រែងរៀនសូត្រដើម្បីទទួលបានចំណេះវិជ្ជា។ ការហូបចុកទទួលបានគ្រប់គ្រាន់ យើងចង់រៀនអាចរៀនបាន ចង់ធ្វើការងារអ្វីបានតាមការសម្រេចចិត្តរបស់យើង មានផ្ទះសម្បែងរស់នៅសមរម្យ មានសិទ្ធិមានសេរីភាពគ្រប់បែបយ៉ាងទាំងអស់។



សិស្សទស្សនកិច្ចសិក្សានៅអតីតមន្ទីរសន្តិសុខក្រាំងតាចាន់ ស្ថិតនៅក្នុងស្រុកទ្រាំង ខេត្តតាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ទុក្ខលំបាករបស់នារីកងចល័តនៅក្នុងរបបខ្មែរក្រហម

***ឌីម សុខគា***



ស្វាយ មុំ ផ្តល់បទសម្ភាសន៍អំឡុងពេលក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា ធ្វើវេទិកាប្រវត្តិសាស្ត្រគ្រួសារនាខែមេសា ឆ្នាំ២០២៣។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ស្វាយ មុំ អាយុ៦៣ឆ្នាំ សព្វថ្ងៃរស់នៅភូមិបឹងម្កាក់ ឃុំត្រាំកក់ ស្រុកត្រាំកក់ ខេត្តតាកែវ។ តាំងពីខ្ញុំពេញវ័យមកខ្ញុំរស់នៅជុំគ្រួសារពុកម៉ែ បងប្អូនទាំងអស់។ ខ្ញុំមានឪពុកឈ្មោះ ស្វាយ ណៃ និងម្តាយឈ្មោះ ភាំ និត។ ខ្ញុំមានបងប្អូនបង្កើតសរុបទាំងអស់ចំនួន៦នាក់ ស្រីចំនួន៤នាក់ ។ ផ្ទះខ្ញុំធ្វើអំពីឈើនិងមានការហូបចុកគ្រប់គ្រាន់។ ខ្ញុំរៀបការនៅឆ្នាំ១៩៨៧ គ្រួសារខ្ញុំមានឈ្មោះ អ៊ុំ ណុប គាត់ធ្វើជាទាហាន និងស្លាប់នៅចុងឆ្នាំ២០១១។

កាលពីតូចខ្ញុំចូលរៀននៅសាលាក្នុងវត្តឯកឧត្តម រៀននៅថ្នាក់ទី១១។ ខ្ញុំរៀនជាមួយលោកគ្រូ ពុធ លោកគ្រូ ធន ការបង្រៀនគាត់កាចណាស់ ប៉ុន្តែបង្រៀនឆាប់ចេះ។ នៅក្នុងរបប លន់ នល់ មានការទម្លាក់គ្រាប់ អាបេ ទាំងខ្សែៗ ប្រជាជនទាំងអស់មានការភ័យខ្លាចនាំគ្នារត់ចូលត្រង់សេបុលេណដ្ឋាន។ ប៉ុន្តែមិនទម្លាក់ត្រូវមនុស្សទេ គ្រាន់តែត្រូវខ្ទេចផ្ទះប្រជាជនមួយចំនួនតូចដែលនៅជិតថ្នល់។

នៅឆ្នាំ១៩៧៥ ក្នុងរបបខ្មែរក្រហម អង្គការជម្លៀសខ្ញុំដាក់ទៅតាមកងចល័តនារីមុនដំបូងអង្គការប្រើឲ្យទៅលើកទំនប់លោកក្នុងខេត្តកំពង់ស្ពឺរយៈពេលមួយខែកន្លះ។ ខ្ញុំដើរថ្មើរជើងពីភូមិបឹងម្កាក់ទៅដល់ទំនប់ពកត្របែក ទើបសម្រាកហូបបាយថ្ងៃត្រង់ ហើយបន្តដំណើរទៅ ទំនប់លោកនៅខេត្តកំពង់ស្ពឺ មានតែសាក់ការដូរម្នាក់មួយ សម្លៀកបំពាក់ ហើយរែកបានឆ្នាំង។ ពេលលើកទំនប់រួច អង្គការឲ្យនៅដាំស្មៅរហូតដល់ម៉ោង១១ សម្រាកហូបបាយ អង្គការឲ្យធ្វើការវិញនៅម៉ោង១រសៀល ឈប់សម្រាកនៅម៉ោង៥ល្ងាច។ នៅតាមកង អង្គការមានចុងភៅ ដាំបាយឲ្យហូបមានសម្លបន្លែផ្លែចេក ល្ហុង លាយសាច់មាន់ខ្លះៗ ដែលដឹកពីក្នុងភូមិ។ គេឲ្យហូបបាយតែពីរពេលគឺ ថ្ងៃត្រង់ និងពេលល្ងាច។ អង្គការដាក់ទៅចំនួនបួនភូមិមានភូមិបឹងម្កាក់ ត្រពាំងចក ត្រពាំងខ្ទត ត្រពាំងកេស។

ឆ្នាំ១៩៧៦-១៩៧៧ អង្គការដាក់ខ្ញុំជាប្រជាជន

ត្រៀម ព្រោះមានឪពុកធ្លាប់ធ្វើជាប៉ូលិសតាំងពីមុនរបប លន់ នល់។ ប្រជាជន១៧មេសា អង្គការដាក់ឈ្មោះថាអ្នកផ្ញើ។ គេហៅខ្ញុំចូលប្រជុំតាមកងរយៈពេលមួយថ្ងៃ ក្នុងមួយខែប្រជុំម្តង «គេនិយាយថាសមមិត្តខំធ្វើការងារឲ្យបានល្អ» កុំឈឺសតិអារម្មណ៍។ ក្នុងរបបខ្មែរក្រហមខ្ញុំកើតពិសនៅម្រាមដៃ គេឲ្យថ្នាំលេប ថ្នាំមានពណ៌ខ្មៅស គេដឹងថាខ្ញុំឈឺគេឲ្យឈប់សម្រាកធ្វើការងាររយៈពេលមួយសប្តាហ៍។ ពេលលើកទំនប់លោក ក្នុងខេត្តកំពង់ស្ពឺ ហើយបានដាំស្ពៅរួចរាល់ហើយអង្គការឲ្យមកវិញ។ បាយឲ្យហូបរាល់បើមិនឆ្អែត ក៏ឆ្លើយថាឆ្អែតដែរ មិនហ៊ានឆ្លើយថាមិនឆ្អែតទេ។ វត្តអារាមត្រូវទុកចោល បំផ្លាញព្រះពុទ្ធបដិមាយកទៅទម្លាក់ចោលក្នុងទឹកស្រះ។ ដំណាំដែលម្តាយខ្ញុំដាំបានយកទៅដាក់រួម មានននោង ដែលដាំបាននៅក្បែរផ្ទះ ចុងភៅដើរបេះអស់ ក្រៅពីនេះមាន់ដែលចិញ្ចឹមនៅតាមផ្ទះខ្លួនឯងគេចាប់យកទៅដាក់រួម។ ទ្រព្យសម្បត្តិគោ គេប្រមូលយកទៅដាក់មួយក្រោលរួមគ្នា។ ប្រជាជនដែលរៀបការហើយមានកូនគេដាក់ទៅតាមភូមិផ្សេងៗគ្នា អង្គការមិនឲ្យនៅជុំគ្នាទេ។ សម្លៀកបំពាក់ អង្គការចែកឲ្យកំណត់ក្នុងមួយឆ្នាំបានពីរសម្រាប់មានសំពត់ពណ៌ខ្មៅ អាវពណ៌ខ្មៅ។ ឪពុករបស់ខ្ញុំក្នុងរបបខ្មែរក្រហម អង្គការប្រើគាត់ឲ្យឡើងត្នោតនៅទំនប់បឹងម្កាក់ជិតភ្នំសែនហាន អង្គការរៀបយកគាត់ទៅសម្លាប់ពីរដងរួចមកហើយ ព្រោះគាត់មានប្រវត្តិរូបមិនល្អ។ ក្រោយមកអង្គការបញ្ជូនខ្ញុំទៅតាមកងចល័តនៅស្តុកខេត្តកំពត។ ខ្ញុំបានទៅរស់នៅជុំគ្រួសារដែលស្ថិតនៅភូមិត្រពាំងថ្កាន់ ឃុំបាភ្នំ ស្រុក១០៦ ខេត្តកំពត។ នៅអន្លង់ទៀន អង្គការឲ្យខ្ញុំធ្វើស្រូវប្រាំងស្ទូង គេឲ្យបាចទឹកដោយប្រើស្នាច និងបោចស្មៅ។ នៅទីនោះការហូបចុកបានគ្រប់គ្រាន់។ ប្រធានកងរបស់ខ្ញុំកាច ប៉ុន្តែខ្ញុំភ្លេចឈ្មោះរបស់គាត់ គាត់បានស្រែកដាក់ឲ្យប្រជាជន។

ក្រោយបែកឆ្នាំ១៩៧៩ ពេលអង្គការឲ្យខ្ញុំនិងប្រជាជនផ្សេងទៀតចូលមករស់នៅស្រុកភូមិមើលទៅសុទ្ធតែព្រៃ ខ្ញុំបានសុំផ្ទះខ្ញុំមកវិញ ហើយរកគេសែងយកមកពីភូមិតាកែនព្រោះក្នុងរបបខ្មែរក្រហមកាលនោះគេយកផ្ទះរបស់ខ្ញុំធ្វើជាកងកុមារនៅក្នុងភូមិបឹងម្កាក់។ ពេលច្រូតរាល់ស្រូវចែកគ្នាតាមគ្រួសារ មួយគ្រួសារមានសមាជិកប៉ុន្មានគេឲ្យតាមនោះ ក្នុងម្នាក់គេចែកឲ្យប្រាំថាំង។ ក្រោយមកគេវាស់ដីចែកជាកម្មសិទ្ធិក្នុងម្នាក់បានដប់ពីរកុង បើគ្រួសារណាមានគោធំសម្រាប់ទឹមគេចែកឲ្យសម្រាប់គោ។ ខ្ញុំចង់ឲ្យក្មេងៗជំនាន់ក្រោយប្រឹងប្រែងរៀនសូត្រដើម្បីទប់ស្កាត់កុំឲ្យរបបនោះវិលត្រឡប់មកវិញ។ ខ្ញុំធ្លាប់ឆ្លងកាត់ភាពលំបាកគ្រប់បែបយ៉ាងហើយ ក្នុងចិត្តខ្ញុំមិនចង់ឲ្យជួបមិនចង់ឃើញទៀតទេ។



សិស្សទស្សនកិច្ចសិក្សានៅអតីតមន្ទីរសន្តិសុខក្រាំងតាចាន់ ស្ថិតនៅក្នុងស្រុកត្រាំកក់ ខេត្តតាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# យុវជនជំនាន់ក្រោយរំឭកពីការចងចាំប្រវត្តិសាស្ត្រខ្មែរក្រហម និងបទពិសោធន៍របស់ជីដូនជីតា

## របស់ខ្លួនដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហម

*ផេង ពង្សរ៉ាស៊ី*





នៅថ្ងៃទី៦ ខែមេសា ឆ្នាំ២០២៣ សិស្សមកពីវិទ្យាល័យចម្រើនវិជ្ជា ចំនួន៣០នាក់ ចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍ អំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥-១៩៧៩) រៀបចំដោយមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខែមេសា កាលពីសតវត្សរ៍ទី២០ ជាពេលវេលានៃការកើតអំពើប្រល័យពូជសាសន៍នៅក្នុងសាកលលោក។ នៅដើមសតវត្សរ៍ទី២១នេះ អំពើប្រល័យពូជសាសន៍នៅតែបន្តកើតមានជាហូរហែរ ហើយយន្តការនៃការទប់ស្កាត់អំពើនេះ ក៏ត្រូវបានធ្វើឡើងផងដែរតាមវិធីសាស្ត្រផ្សេងៗដូចជាការអប់រំ ការកាត់សេចក្តីចំពោះបទឧក្រិដ្ឋ និងការផ្តួចផ្តើមគំនិតដើម្បីបន្ថយសន្ទុះនៃការរីករាលដាលនៃអំពើប្រល័យពូជសាសន៍។ ជារៀងរាល់ឆ្នាំ យើងសង្កេតឃើញថា ប្រទេសមួយចំនួនក្នុងសាកលលោក បានកំណត់យកខែមេសាជាខែនៃការស្វែងយល់ពីអំពើប្រល័យពូជសាសន៍ដែលបានកើតឡើងនាពេលអតីតកាល ដើម្បីរំឭកដល់ពិភពលោកឲ្យនឹកឃើញឡើងវិញនូវរឿងរ៉ាវអាក្រក់ៗដែលបានកើតមានឡើង ក៏ដូចជាដាស់តឿនដល់មនុស្សជំនាន់ក្រោយឲ្យចងចាំពីរឿងរ៉ាវទាំងនោះក្នុងន័យចូលរួមបង្ការការកកើតឡើងវិញប្រំដែលៗនៃទង្វើរអមនុស្សធម៌ ឃោរឃៅ និងសម្លាប់រង្គាល។ សិស្ស និស្សិត និងបុគ្គលិកអង្គការមកពីវិទ្យាល័យ មហាវិទ្យាល័យ និងអង្គការក្រៅរដ្ឋាភិបាលមួយចំនួន បានបង្កើតកម្មវិធី ឬគម្រោងផ្សេងៗ ដើម្បីរំឭកពីព្រឹត្តិការណ៍កើតមានអំពើប្រល័យពូជសាសន៍កាលពីអតីតកាល ដូចជាកម្មវិធីប្រឡង

ប្រដេញតែងកំណាព្យ និពន្ធបទចម្រៀង និពន្ធបទភ្លេង ប្រគុំតន្ត្រី សម្តែងសិល្បៈ តាំងពិព័រណ៍រូបថត និងបញ្ចាំងវីដេអូឯកសារនានា ទាក់ទងនឹងព្រឹត្តិការណ៍នានា ស្តីអំពីការប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ដែលបានកើតមានឡើងនៅលើបណ្តាប្រទេសមួយចំនួនដូចជា ប្រទេសរ៉្វាន់ដា ការសម្លាប់រង្គាលហូឡូខស ប្រទេសបូស្នៀ ហឺហ្ស៊េហ្គូវីន ប្រទេសកម្ពុជា និងការសម្លាប់រង្គាលនៅតំបន់ដាហ្វួរប្រទេសស៊ូដង់ជាដើម ដែលសុទ្ធសឹងជាប្រទេសដែលធ្លាប់បានទទួលរងនូវការប្រព្រឹត្តអំពើប្រល័យពូជសាសន៍ដែលចាប់ផ្តើមនៅក្នុងខែមេសាដូចគ្នា។

នៅថ្ងៃទី៦ ខែមេសា ឆ្នាំ២០២៣នេះ មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង បានប្រារព្ធធ្វើកម្មវិធី វេទិកាថ្នាក់រៀនចុងសប្តាហ៍របស់ខ្លួនដូចសព្វមួយដង ហើយអ្នកចូលរួមទាំង៣០នាក់គឺជាសិស្សថ្នាក់វិទ្យាល័យនៃវិទ្យាល័យ ចម្រើនវិជ្ជា មានទីតាំងស្ថិតនៅក្នុងសង្កាត់បារាយណ៍ ក្រុងព្រៃវែង ខេត្តព្រៃវែង។ ដើម្បីចូលរួមចំណែកក្នុងការរំឭក និងការយល់ដឹងពីអំពើប្រល័យពូជសាសន៍ដែលបានកើតឡើងនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥នៅកម្ពុជា អ្នកចូលរួមទាំងអស់ ត្រូវបានណែនាំពីគម្រោងសរសេរអត្ថបទខ្លីៗ ទាក់ទងនឹង «ការសិក្សារួចមកហើយ និងការចងចាំពីរឿងរ៉ាវ បទពិសោធន៍ ឬព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រដែលបានកើតឡើងនៅក្នុងក្រុមគ្រួសាររបស់ខ្លួនកាលពីរបបខ្មែរក្រហម» ដោយឆ្លើយនឹងសំណួរមួយដូចៗគ្នាគឺ៖ «ចូរប្អូនសរសេរអត្ថបទខ្លីមួយ ស្តីអំពីរឿងរ៉ាវដែលបានកើតឡើងក្នុងរបបខ្មែរក្រហម ឬសរសេរពីរឿងរ៉ាវរបស់ក្រុមគ្រួសារប្អូនដែលធ្លាប់ឆ្លងកាត់ក្នុងរបបខ្មែរក្រហម?»។ ការអនុវត្តគម្រោងសំណេរនេះ គឺកើតឡើងមុនពេលដែលអ្នកទាំងនោះចូលរួមនៅក្នុងវេទិការយៈពេល២ម៉ោង ពិភាក្សាលើប្រធានបទ «ការចូលកាន់កាប់ទីក្រុងភ្នំពេញនៅថ្ងៃ១៧ មេសា ១៩៧៥ និងការជម្លៀសប្រជាជនទៅកាន់ទីជនបទ» ជាជំពូកមួយនៃសៀវភៅ ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ មុននឹងចាប់ផ្តើមសរសេរ សិស្សានុសិស្សទាំងអស់មិនត្រូវបានណែនាំ ឬពន្យល់អ្វីឡើយ ទាក់ទងនឹងរបបខ្មែរក្រហម ព្រោះថាគម្រោងនេះគឺជាការរំឭកឡើងវិញពីអ្វីដែលខ្លួនបានរៀនរួចមកហើយ ឬដឹងរួចមកហើយពីអំពើប្រល័យពូជសាសន៍ខ្មែរក្រហម។ សិស្សានុសិស្សបានចំណាយពេលវេលាកន្លះម៉ោង សម្រាប់គម្រោងមួយនេះ។ អ្នកទាំងនោះ អង្គុយដោយស្ងៀមស្ងាត់នៅលើកៅអីផ្តៅរៀងៗខ្លួនហើយចាប់ផ្តើមកាន់ប៊ិក និងក្រដាស សរសេរពីចំណេះដឹងផ្ទាល់ខ្លួនពីប្រធានបទ ដោយមិនងាកឆ្វេងស្តាំ ឬសួរគ្នីគ្នាឡើយ។ (សំណេររបស់សិស្សនឹងដាក់នៅក្នុងផ្នែកខាងក្រោមនៃអត្ថបទនេះ)។

បន្ទាប់ពីរយៈពេលកន្លះម៉ោងនៃការរំឭកឡើងវិញពីការចងចាំ និងបន្ទាប់ពីបានប្រមូលដោយក្រុមការងាររួចមក សិស្សានុសិស្សទាំងអស់បានចំណាយពេលវេលាបន្ថែមជាងពីរម៉ោងទៀត ដើម្បីបំពេញបន្ថែមនូវចំណេះដឹងពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិប-តេយ្យ និងវិធីសាស្ត្រដ៏មានសារសំខាន់នានា ទាក់ទងនឹងការរារាំង និងទប់ស្កាត់ការវិលត្រឡប់នៃអំពើប្រល័យពូជសាសន៍។

នៅពេលរសៀលថ្ងៃដដែល ក្រុមសិស្សានុសិស្សទាំងអស់ធ្វើដំណើរទៅកាន់ទីតាំងមួយ ឈ្មោះថា «ទួលធាតុ» ជាកន្លែងកប់សាកសពមនុស្សរបស់អ្នកភូមិនានាក្នុងឃុំចាម ស្រុកកំពង់ត្របែក ខេត្តព្រៃវែង មានចម្ងាយប្រមាណ៨០គីឡូម៉ែត្រពីទីរួមខេត្តព្រៃវែង។ នៅលើទីតាំង«ទួលធាតុ» មានសំណង់ចេតិយរឹងមាំមួយនៅចំកណ្តាលទីទួល និងមានផ្ទាំងពាក្យស្លោករំឭកពីការចងចាំពីអំពើប្រល័យពូជសាសន៍ចំនួនពីរផ្ទាំង ទល់ខ្នងគ្នានៅលើទម្រធ្វើពីស៊ីម៉ងត៍កម្ពស់កន្លះម៉ែត្រ និងស្ថិតនៅចម្ងាយប្រមាណ១០ម៉ែត្រពីសំណង់ចេតិយ។ ផ្ទាំងទី១នៃពាក្យស្លោកសរសេរថា «និយាយពីការរស់នៅក្នុងរបបខ្មែរក្រហម គឺនិយាយពីការជម្រុះជម្រា អប់រំកូនចៅឲ្យអត់ឱន អធ្យាស្រ័យគ្នា» និងផ្ទាំងទី២សរសេរថា «រៀនពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ គឺរៀនពីការទប់ស្កាត់អំពើប្រល័យពូជសាសន៍»។ នៅឆ្នាំ២០២០ មជ្ឈមណ្ឌលឯកសារកម្ពុជា បានកសាងសំណង់ចេតិយ និងផ្ទាំងពាក្យស្លោកនេះឡើង ដើម្បី



នៅថ្ងៃទី៦ ខែមេសា ឆ្នាំ២០២៣ សិស្សមកពីវិទ្យាល័យចម្រើនវិជ្ជា ចំនួន៣០នាក់ ចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍អំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥-១៩៧៩) រៀបចំដោយមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



ផ្តល់ជាទីកន្លែងសម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមប្រើប្រាស់ជាទីកន្លែងតម្កល់អដ្ឋិធាតុសាច់ញាតិបងប្អូនខ្លួន ដែលបានស្លាប់ក្នុងរបបខ្មែរក្រហម និងដើម្បីប្រើប្រាស់ទីតាំងនេះជាកន្លែងប្រារព្ធធ្វើកម្មវិធីសាសនា ឬកម្មវិធីអប់រំនានាដូចជា វេទិកាអប់រំសាធារណៈ ស្តីពីបទពិសោធន៍ឆ្លងកាត់របបខ្មែរក្រហម និងវេទិកាអប់រំដទៃទៀតដែលធានាដល់ការពិភាក្សាអន្តរជំនាន់ពីប្រវត្តិសាស្ត្រខ្មែរក្រហម។ សិស្សានុសិស្សត្រូវបានណែនាំពីសំណង់ទាំងពីរ និងផ្តល់ឱកាសឲ្យមានការពិភាក្សា និងសួរឆ្លើយពីទីតាំងនេះ។ យើងបានចំណាយពេលវេលាជាងពីរម៉ោងនៅលើទួលធាតុ ហើយសិស្សានុសិស្សទាំងអស់ ក៏មានឱកាសឈ្វេងយល់បានច្រើនដែរពីទីតាំងទួលធាតុ ការសម្លាប់មនុស្ស ការកសាងមន្ទីរសន្តិសុខ និងកន្លែងសម្លាប់របស់ខ្មែរក្រហម ព្រមទាំងយល់ដឹងបានច្រើនពីវិធីសាស្ត្រនៃការទប់ស្កាត់អំពើប្រល័យពូជសាសន៍។ ខាងក្រោមនេះជាសំណេររបស់សិស្សានុសិស្សទាំង៣០នាក់ ដែលបានសរសេររៀបរាប់ពីការចងចាំរបស់ខ្លួនទាក់ទងនឹងអំពើប្រល័យពូជសាសន៍នៅកម្ពុជា៖



**ហ៊ាន លីហួ**
**ភេទស្រី អាយុ១៧ឆ្នាំ**

នៅពេលមានរបបកម្ពុជាប្រជាធិបតេយ្យកើតឡើងដំបូង ប្រជាជនទាំងអស់សប្បាយរីករាយជាខ្លាំង ប៉ុន្តែមិនយូរប៉ុន្មានក៏មានការប្រែប្រួល ព្រោះខ្មែរ

ក្រហមបានជម្លៀសប្រជាជនចេញពីទីក្រុង និងទីប្រជុំជននានា ដើម្បីឲ្យទៅធ្វើស្រែចម្ការនៅឯជនបទៗ។ នៅក្នុងតំបន់ភូមិភាគខ្លះ ប្រជាជនក៏មានការហូបចុកគ្រប់គ្រាន់ៗ ប៉ុន្តែនៅកន្លែងផ្សេងទៀត ក៏មានការខ្វះខាតស្បៀងអាហារ ព្រោះតែការអនុវត្តដី១ហិកតា ឲ្យប្រជាជនធ្វើស្រូវឲ្យបាន៣តោនៗ។ ឪពុករបស់ខ្ញុំគាត់ធ្លាប់ប្រាប់ខ្ញុំថា កាលនោះ គាត់ជាក្មេងប្រុសដែលមានអាយុ៧ឆ្នាំ។ គាត់បាននិយាយប្រាប់ខ្ញុំថា នៅសម័យនោះ សម្បូរត្រីណាស់ គាត់បានស្ទូចត្រីដើម្បីដូរជាមួយនឹងអំបិលពីកងនៅផ្ទះបាយ។ គាត់បានប្រាប់ទៀតថា ក្មេងនៅសម័យនោះ អ្នកដែលមានអាយុចាប់ពី៦ឆ្នាំដល់១០ឆ្នាំ គេឲ្យទៅឃ្វាលគោក្របីជាក្រុមៗ ទៅតាមកងនីមួយៗ។ នៅចន្លោះឆ្នាំ១៩៧៧-១៩៧៨ លោកតារបស់ខ្ញុំត្រូវបានទាហានខ្មែរក្រហមចាប់យកទៅធ្វើទាហាន។ នៅមុនពេលក្រុមទាហានរណសិរ្ស និងកងទ័ពវៀតណាមចូលមកដល់តំបន់ដែលឪពុកខ្ញុំកំពុងរស់នៅ មានការដាំបបរផ្ដែកន្ទួត ធ្វើឲ្យប្រជាជនជាច្រើនបានស្លាប់ និងខ្លះទៀតមិនមានកម្លាំងកំហែងក្នុងខ្លួន ព្រោះតែជំងឺពករួស ក្រោយពេលហូបបបរកន្ទួតរួច នឹងខ្លះទៀតបានសន្លប់ ក៏ត្រូវបានអង្គការយកទៅកប់ទាំងរស់ៗ។ នៅពេលរត់ភៀសខ្លួន គាត់បាននិយាយទៀតថា មានប្រជាជន និងក្រុមទាហានជាច្រើនបានស្លាប់ពាសពេញផ្ទៃទឹកនៅក្នុងទន្លេ និងកន្លែងខ្លះ ទឹកទន្លេមានពណ៌ក្រហមដូចទន្លេឈាម។ មិនតែប៉ុណ្ណោះ ការធ្វើការហួសកម្លាំងនៅក្នុងសម័យខ្មែរក្រហមបានធ្វើឲ្យមនុស្សជាច្រើនកើតមានជំងឺរ៉ាំរ៉ៃ ក្រោយពេលរបបខ្មែរក្រហមដួលរលំទៅ។



**ឡឿន រក្សា**
**ភេទស្រី អាយុ១៦ឆ្នាំ**

របបខ្មែរក្រហម ជារបបមួយដ៏សាហាវយង់ឃ្នងបានសម្លាប់ប្រជាជនអស់ជាច្រើននាក់ ក្នុងនោះក៏មានសមាជិកដែលជាលោកតារបស់ខ្ញុំម្នាក់ដែរ។ ម្តាយរបស់ខ្ញុំបានរៀបរាប់ពីទុក្ខលំបាករបស់គាត់នាសម័យនោះ រួមទាំងទុក្ខដ៏ក្រៀមក្រំដែលបាត់បង់ឪពុកជាទីស្រឡាញ់គឺលោកតារបស់ខ្ញុំ។ ម្តាយរបស់ខ្ញុំបានប្រាប់ថា លោកតារបស់ខ្ញុំជាគ្រូបង្រៀនម្នាក់ និងជាជនគំរូនៅក្នុងស្រុកភូមិ ដោយសារគាត់ជាអ្នកចេះដឹង។ គេបានមកចាប់គាត់ និងសួរនាំ ប៉ុន្តែគាត់មិនព្រមប្រាប់គេថាគាត់ជាគ្រូបង្រៀនឡើយ។ គាត់ព្យាយាមធ្វើឡឺកឺ ធ្វើជាមនុស្សមិនគ្រប់ដើម្បីឲ្យគេជឿ។ លោកតាខ្ញុំត្រូវបានគេចាប់ឃុំអស់ជាច្រើនថ្ងៃ និងហូបអាហារសាបៗគ្មានរសជាតិ។ ក្រោយពីរួចខ្លួន តារបស់ខ្ញុំបានស្ម័គ្រចិត្តចូលបម្រើកងទ័ព។ កាលនោះម្តាយរបស់ខ្ញុំទើបតែមានអាយុ៦ទៅ៧ឆ្នាំប៉ុណ្ណោះ មិនសូវបានឃើញមុខឪពុកទេ ព្រោះលោកតាខ្ញុំមួយទៅពីរខែម្តង ទើបគាត់បានត្រឡប់មកលេងផ្ទះ។ អស់កាលដ៏យូរ ម្តាយខ្ញុំរួមទាំងអ៊ំៗរបស់ខ្ញុំ បានចាំបាត់ៗមិនឃើញលោកតាត្រឡប់មកផ្ទះ។ យើងមានការព្រួយបារម្ភខ្លាំងណាស់។ លុះក្រោយមកក៏ទទួលដំណឹងថា លោកតារបស់ខ្ញុំបានស្លាប់ដោយសារគ្រាប់កាំភ្លើងយ៉ាងទារុណ។ លោកយាយខ្ញុំមានសេចក្តីទុក្ខសោកសង្រេងយ៉ាងខ្លាំង ព្រោះរៀបការនិងរស់នៅជាមួយគ្នាមិនបានយូរ មិនបានជួបជុំគ្រួសារ ក៏ត្រូវបានបាត់បង់បុរសដែលជាមេជ្រោងគ្រួសារ ហើយលោកយាយខ្ញុំក៏ក្លាយជាស្ត្រីមេម៉ាយចិញ្ចឹមកូន៥នាក់តែឯងគ្មានទីពឹង។ ឯម្តាយ និងអ៊ំខ្ញុំក៏ក្លាយជាកូនកំព្រាឪពុក។



**ម៉ៅ កញ្ញា**
**ភេទស្រី អាយុ២០ឆ្នាំ**

របបខ្មែរក្រហមជាប្រវត្តិសាស្ត្រមួយដែលសាហាវបំផុតរបស់ប្រទេសកម្ពុជា។ ប្រជាជននៅក្នុងសម័យនោះត្រូវរស់នៅដោយការបំបិទសិទ្ធិសេរីភាព ការហូបចុកមិនគ្រប់គ្រាន់ ក៏ដូចជាត្រូវបង្ខិតបង្ខំឲ្យធ្វើការមួយថ្ងៃ១២ម៉ោងពេញ១សប្តាហ៍។ ក្មេងតូចៗត្រូវបាន

គេបញ្ជូនឲ្យទៅធ្វើការកើបលាមកគោ ហើយមនុស្សពេញវ័យត្រូវធ្វើការកាប់ដី ឬធ្វើស្រែចម្ការដែលអង្គការបានបញ្ជា។ ចំណែកឯមនុស្សចាស់ជរាត្រូវនៅមើលថែក្មេងៗតូចៗឬទារក។ ចំពោះការអប់រំវិញគឺបានបង្រៀនឲ្យស្មោះស្ម័គ្រនឹងអង្គការ ពោលគឺអង្គការជាឪពុកម្ដាយ។ ដោយឡែកក្នុងសម័យនោះពុំមានសាលារៀនអ្វីទេដោយសារសាលារៀនត្រូវបានកម្ទេចចោល ហើយលោកគ្រូអ្នកគ្រូត្រូវរត់ភៀសខ្លួនដោយសារសង្គ្រាម។ ម្យ៉ាងវិញទៀតនរណាក៏ដោយឲ្យតែប្រឆាំងនឹងអង្គការត្រូវតែសម្លាប់ចោល ទាំងអស់ «ស៊ីសម្លាប់ច្រឡំ ប្រសើរជាងដោះលែងច្រឡំ» «ទុកក៏មិនចំណេញ ដកចេញក៏មិនខាត»។ នៅក្នុងរបបនោះប្រជាជនប្រមាណ២លាននាក់ត្រូវបានសម្លាប់ដោយខ្មែរក្រហម។ ក្រោយរបបខ្មែរក្រហម បន្សល់ទុកនូវក្មេងកំព្រា ស្ត្រីមេម៉ាយ ជនពិការក៏ដូចជាអ្នកមានរបួសជាច្រើននាក់ផងដែរ។ របបនេះ ធ្វើឲ្យប្រជាជនខ្មែររងទុក្ខវេទនា និងធ្វើឲ្យមានការស្អប់ខ្ពើមចំពោះរបបប្រល័យពូជសាសន៍ដ៏សាហាវយង់ឃ្នងមួយនេះ។



**ច័ន សាវី**
**ភេទប្រុស អាយុ១៦ឆ្នាំ**

តាមរយៈការយល់ដឹងខ្លះៗ ឬការចងចាំរបស់ខ្ញុំពីប្រវត្តិសាស្ត្រខ្មែរក្រហម គឺលំបាកសម្រាប់ប្រជាជនខ្មែរយើងដោយសាររបបនេះមានការរើសអើងវណ្ណៈ ការគាបសង្កត់ទៅលើការហូបអាហារ ការស្លៀកពាក់ ហើយពេលខ្លះក៏មានផលវិបាកមួយចំនួនដូចជាការសម្លាប់យោរយៅ ពេលដែលយើងធ្វើខុសពីបទបញ្ជាដែលអង្គការបានដាក់ឲ្យធ្វើ។ មិនត្រូវមានទំនាស់ទេ ដោយសារសម័យនោះក្នុងគ្រួសារនីមួយៗមិនថាអ្នកមានឬអ្នកក្រ សុទ្ធតែទទួលនូវបទពិសោធន៍ដូចគ្នា។ បើកូនស្រីត្រូវកាត់សក់ឲ្យខ្លីដើម្បីជួយខ្មែរក្រហម ហើយកូនប្រុសត្រូវជួយខ្មែរក្រហមឲ្យមានភាពធូរធារដូចជាការដាំដំឡូង ធ្វើស្រែចម្ការជាដើម។ ម្យ៉ាងវិញទៀតការបញ្ជារបស់ខ្មែរក្រហម«អង្គការ» មានចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ ពេលខ្លះមានការពិបាកដោយសារហូបតែបបរប៉ុណ្ណោះ ប៉ុន្តែបើយើងជំទាស់អង្គការ យើងនឹងត្រូវស្លាប់មិនខានមិនថាចាស់ឬក្មេងទេ។ ពួកគេមិនអាណិតអាសូរយើង នៅពេលយើងឈឺឡើយ ពោលគឺប្រើគ្មានត្រាប្រណី។ ដូច្នេះយើងមិនត្រូវយកគំរូតាមពួកខ្មែរក្រហមឡើយ។



**កុល ស្រីណាថ**
**ភេទស្រី អាយុ១៦ឆ្នាំ**

ដំបូងនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ អង្គការខ្មែរក្រហម ឬ ប៉ុល ពត បានកៀរប្រជាជនខ្មែរចេញពីទីក្រុងភ្នំពេញដោយកុហកថា ទីក្រុងភ្នំពេញទម្លាក់គ្រាប់បែក ហើយនិយាយថាឲ្យប្រជាជនចេញតែពីរបីថ្ងៃប៉ុណ្ណោះ នឹងត្រឡប់មកវិញ។ អង្គការបានប្រាប់ទៀតថាមិនបាច់យកអ្វីច្រើនទៅទេ។ នេះជាចលនាដំបូងរបស់របបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដែលមាន ប៉ុល ពត ជាអ្នកដឹកនាំ។ មិនត្រឹមតែបានកៀរខ្លួនប្រជាជនខ្មែរប៉ុណ្ណោះទេ ថែមទាំងសម្លាប់អ្នកចេះដឹង តារាល្បីៗ មេដឹកនាំសាសនាផ្សេងៗ ព្រោះចោទថាក្បត់នឹងអង្គការ។ ម្យ៉ាងទៀតឲ្យប្រជាជនស្លៀកពាក់ខ្មៅ ចាប់ព្រះសង្ឃផ្សឹក ដើម្បីឲ្យទៅធ្វើស្រែចម្ការ លើកដី និងធ្វើទំនប់ផ្សេងៗ និងចាស់ៗឲ្យនៅមើលក្មេងតូចៗ ហើយក្មេងអាយុ៥ ទៅ៧ឆ្នាំឲ្យដើរកើបអាចម៍គោក្របី។ ពេលដល់ម៉ោងហូប ឲ្យហូបតែបបរមិនឲ្យហូបបាយទេ។ រីឯដំណាំឬផ្លែឈើរបស់ហូបដែលខ្លួនបានដាំនៅផ្ទះគឺមិនឲ្យបេះហូបបានទេ ព្រោះជារបស់អង្គការ។ បើល្មើសច្បាប់នេះត្រូវយកទៅកសាង។ ពាក្យថា កសាងនៅសម័យនោះ មានន័យថាយកទៅសម្លាប់ចោល។



**ព្រាប ស្រីអឿយ**
**ភេទស្រី អាយុ១៦ឆ្នាំ**

តាមដែលខ្ញុំឮពីលោកគ្រូអ្នកគ្រូ និងលោកយាយរបស់ខ្ញុំ គាត់បាននិយាយថា របបខ្មែរក្រហមជារបបដែលអាក្រក់បំផុត ព្រោះរបបនេះបានពង្រាត់បងប្អូនឲ្យបែកបាក់គ្នា រស់នៅក្រោមគំនាបអង្គការ បរិភោគមិនបានគ្រប់គ្រាន់ បំបិទសិទ្ធិសេរីភាពគ្រប់បែបយ៉ាងដូចជាការជ្រើសរើសគូស្រករ ត្រូវអង្គការចាប់គូឲ្យ ជាពិសេសចំពោះដំណាំបរិភោគដែលយើងដាំដោយខ្លួនឯងក៏គ្មានសិទ្ធិបេះយកមកហូបបានដែរ។ ប្រសិនបើហ៊ានបេះ ហើយអង្គការដឹងនឹងយកទៅសម្លាប់ចោល។ ប្រទេសជាតិស្ថិតនៅក្នុងភ្លើងសង្គ្រាម មានការបាញ់សម្លាប់គ្នា និងសុទ្ធសឹងតែជាប្រជាពលរដ្ឋខ្មែរដូចគ្នា ដែលធ្វើឲ្យប្រជាជនខ្មែរបាត់បង់ជីវិតអស់រាប់ពាន់នាក់ ដែលកាលពីមុនមិនមានការស្លាប់ច្រើនបែបនេះទេ។ រយៈពេល៣ឆ្នាំ ៨ខែ ២០ថ្ងៃ ដែលប្រជាពលរដ្ឋខ្មែរបានជួបនូវទុក្ខវេទនាគ្រប់បែបយ៉ាងធ្វើឲ្យប្រជាជនខ្មែរមិនអាចបំភ្លេចបាន។



**ចិន ច័ន្ទស្រីនួ**
**ភេទស្រី អាយុ១៦ឆ្នាំ**

មានមូលហេតុ៣យ៉ាងដែលធ្វើឲ្យខ្មែរក្រហមដួលរលំ។ ទី១) ការស្អប់ខ្ពើមរបស់ខ្មែរក្រហមចំពោះប្រជាជន៖ ការអនុវត្តផលិតស្រូវ៣តោនក្នុង១ហិកតាពុំទទួលបានជោគជ័យឡើយ។ ប៉ុន្តែពួកកម្មាភិបាលបានធ្វើរបាយការណ៍ក្លែងក្លាយ និងបញ្ជូនស្រូវទៅតាមផែនការទៅឲ្យមជ្ឈិម។ មេដឹកនាំមជ្ឈិមបក្ស ជឿជាក់លើរបាយការណ៍នេះ។ ឯអ្នកថ្នាក់ក្រោមមិនហ៊ានរាយការណ៍ពីព័ត៌មានពិតឡើយ។ ប្រជាជនរស់ដោយភាពអត់ឃ្លាន ខ្វះអាហារ ធ្វើការច្រើនម៉ោង រងនូវការសម្លាប់ និងស្លាប់ដោយសារកង្វះអាហារ។

ទី២) ធ្វើសង្គ្រាមជាមួយវៀតណាម៖ នៅឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមត្រូវបានបញ្ជូនទៅព្រំដែន និងធ្វើសង្គ្រាមរប៉េះរប៉ោះជាមួយវៀតណាម។ ក្រោយមកមានការបង្កើតបង្កើតរណសិរ្សសាមគ្គីសង្គ្រោះជាតិ ដោយលោក ហេង សំរិនជាប្រធាន ហើយរណសិរ្សនេះបានរួបរួមជាមួយកងទ័ពវៀតណាមដើម្បីវាយយកទីក្រុងភ្នំពេញពីពួកខ្មែរក្រហម។

ទី៣) ការបម្រាញ់យកមនុស្សបរិសុទ្ធ(វិសុទ្ធកម្ម)៖ ត្រូវបានជ្រើសរើសមេដឹកនាំនៅក្នុងជួរបក្សនយោបាយជាច្រើនរូប ដែលនាំឲ្យមានចលនានៅក្នុងជួរបក្សនយោបាយ។ ការធ្វើបែបនេះ នាំឲ្យនយោបាយលែងទុកចិត្តគ្នា តាំងពីថ្នាក់មជ្ឈិម ភូមិភាគ ភូមិ និងឃុំ។ ដូច្នេះឲ្យតែពួកគេសង្ស័យលើនរណាម្នាក់ ឬក្រុមណាម្នាក់គឺត្រូវសម្លាប់ចោល តាមពាក្យស្លោក «សម្លាប់ច្រឡំ ប្រសើរជាងលែងច្រឡំ» «ទុកមិនចំណេញ ដកចេញមិនខាត»។



**រម្យ ស្រីពេជ្រ**
**ភេទស្រី អាយុ១៦ឆ្នាំ**

ពួកខ្មែរក្រហម បានបង្ខំប្រជាជនឲ្យធ្វើការហួសកម្លាំង១២ម៉ោងក្នុង១ថ្ងៃ៧ថ្ងៃក្នុង១សប្តាហ៍ដោយមិនមានការហូបចុកគ្រប់គ្រាន់។ ផ្តាច់មនោសញ្ចេតនាប្តីប្រពន្ធនិងកូន។ ជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងទីប្រជុំជននានា។ ធ្វើវិសុទ្ធកម្ម បំផ្លិចបំផ្លាញប្រពៃណី ទំនៀមទម្លាប់ ជំនឿសាសនា វត្តអារាមបំផ្លាញធនធានមនុស្ស បង្កើតមន្ទីរសន្តិសុខគ្រប់កន្លែង (គុក)។ អំពើខាងលើនេះខុសពីសន្ធិសញ្ញាអន្តរជាតិគឺបានប្រព្រឹត្តិឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម។ បញ្ហានេះហើយ ទើបបានជារាជរដ្ឋាភិបាលបានស្នើសុំទៅអង្គការសហប្រជាជាតិឲ្យបង្កើតតុលាការកូនកាត់មួយដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហម។ តុលាការកូនកាត់នោះគឺសាលាក្តីខ្មែរក្រហម។

# សិស្សវិទ្យាល័យ ប៊ុន រ៉ានី ហ៊ុន សែន ស្ពឺ

## ចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍ស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ក្រោមប្រធានបទ «ប្រអប់សង្គ្រោះជីវិតក្នុងពេលជម្លៀសដោយបង្ខំ»

***លី ដេវីត និង ទូច វណ្ណេត***





*សិស្សវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន ស្ពឺ ចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍ស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ក្រោមប្រធានបទ «ប្រអប់សង្គ្រោះជីវិតក្នុងពេលជម្លៀសដោយបង្ខំ» រៀបចំដោយមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម នៅថ្ងៃទី២ ខែមេសា ឆ្នាំ២០២៣។ (លី ដេវីត/ មជ្ឈមណ្ឌលឯកសារកម្ពុជា)*

នៅថ្ងៃទី២ ខែមេសា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ដែលជាសាខាមជ្ឈមណ្ឌលឯកសារកម្ពុជា បានរៀបវេទិកាថ្នាក់រៀនចុងសប្តាហ៍ស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដែលផ្តោតទៅលើប្រធានបទ «ប្រអប់សង្គ្រោះជីវិតក្នុងពេលជម្លៀសដោយបង្ខំ»។ វេទិកាថ្នាក់រៀនចុងសប្តាហ៍នៅក្នុងខែមេសា ឆ្នាំ២០២៣ នេះត្រូវបានរៀបចំឡើងក្នុងគោលបំណងផ្តល់ចំណេះដឹងដល់សិស្សអំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងស្តាប់អំពីបទពិសោធន៍របស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។

មុនការផ្តើមទបង្ហាញស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) លោក ស៊ាង ចិន្តា នាយកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បានរំឭកអំពីព្រឹត្តិការណ៍ការសម្លាប់រង្គាល និងអំពើប្រល័យពូជសាសន៍ជាច្រើនដែលបានកើតមានឡើងនៅក្នុងសតវត្សរ៍ទី២០ និងជាញឹកញាប់កើតនៅខែមេសា។ លោក ស៊ាង ចិន្តា បន្តពន្យល់ទៅកាន់សិស្សដែលចូលរួមថា «ខែមេសា គឺជាខែនៃការក្រើនរំឭកអំពីអំពើប្រល័យពូជសាសន៍ដែលបានចាប់ផ្តើមកើតមានឡើងនៅក្នុងប្រវត្តិសាស្ត្រសកលលោក។ អំពើប្រល័យពូជសាសន៍ដែលបានចាប់ផ្តើម

កើតមានឡើងនៅក្នុងខែមេសានេះ គឺរួមមាន អំពើប្រល័យពូជសាសន៍អាមេនី (១៩១៥-១៩១៧), អំពើប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិជ្វីបនៅអឺរ៉ុប ឬហៅថា ហូឡូខូសត៍ (១៩៣៣-១៩៤៥), អំពើប្រល័យពូជសាសន៍កម្ពុជា (១៩៧៥-១៩៧៩), អំពើប្រល័យពូជសាសន៍បូស្នី(១៩៩២) និងអំពើប្រល័យពូជសាសន៍រ៉្វាន់ដា (១៩៩៤)។

ជាកិច្ចបន្ត លោក ស៊ាង ចិន្តា បានធ្វើបទបង្ហាញដោយផ្តោតសំខាន់ទៅលើព្រឹត្តិការណ៍ប្រវត្តិសាស្ត្ររួមមាន៖ រដ្ឋប្រហារលន់នល់ នៅឆ្នាំ១៩៧០, ការផ្ទុះឡើងនូវសង្គ្រាមរវាងទាហានលន់នល់ និងកងទ័ពរំដោះខ្មែរក្រហមដែលបានអូសបន្លាយរយៈពេលជិត៥ឆ្នាំ, ការឡើងកាន់អំណាចរបស់ខ្មែរក្រហម, ការជម្លៀសប្រជាជនចេញពីទីក្រុង និងទីប្រជុំជនទៅកាន់






សិស្សវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន ស្ទឺ ចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍ស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ក្រោមប្រធានបទ «ប្រអប់សង្គ្រោះជីវិតក្នុងពេលជម្លៀសដោយបង្ខំ» រៀបចំដោយមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម នៅថ្ងៃទី២ ខែមេសា ឆ្នាំ២០២៣។ (លី ដេវីត/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ជនបទ និង ការកាប់សម្លាប់ទៅលើប្រជាជន។ បន្ថែមលើនេះទៀត លោក ស៊ាង ចិន្តា បានចាក់បញ្ចាំងវីដេអូអំពីការជម្លៀសប្រជាជនដោយបង្ខំ និងការធ្វើការងារហួសកម្លាំងនៅតាមការដ្ឋានទំនប់។ ផ្នែកចុងក្រោយនៃបទបង្ហាញរបស់លោក ស៊ាង ចិន្តា គឺផ្តោតទៅលើនិយមន័យ និងវិធីសាស្ត្រទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ និងប្រល័យពូជសាសន៍។

បន្ទាប់ពីបទបង្ហាញបានបញ្ចប់ លោក ស៊ាង ចិន្តា បន្តដឹកនាំកិច្ចពិភាក្សាទៅលើប្រធានបទ៖ «ប្រអប់សង្គ្រោះជីវិត និងទិសដៅជម្លៀសដោយបង្ខំ» និងបែងចែកយុវសិស្សចូលរួមទាំងអស់ទៅជា៥ក្រុម។ សកម្មភាពនៃប្រអប់សង្គ្រោះជីវិត និងទិសដៅជម្លៀសដោយបង្ខំ» បានធ្វើឡើងដើម្បីឲ្យយុវសិស្សដែលជាក្មេងជំនាន់ក្រោយមានការត្រិះរិះពិចារណារបស់ខ្លួន ក្នុងការបង្កើតប្រអប់សង្គ្រោះរបស់ខ្លួនក្នុងគ្រាលំបាក និងយល់អំពីទុកលំបាករបស់ប្រជាជនជម្លៀសក្នុងអាកាសធាតុក្តៅក្នុងខែមេសា។

ក្រុមពិភាក្សាទាំង៥ ទទួលបានប្រធានបទទិសដៅជម្លៀសដោយបង្ខំផ្សេងៗគ្នា និងមានរយៈពេល ១៥នាទីដើម្បីពិភាក្សាជាក្រុមក្នុងការជ្រើសរើសយកសម្ភារចាំបាច់ ក្នុងការធ្វើដំណើរថ្មើរជើងក្រោមកម្តៅថ្ងៃនៃខែមេសា។ បន្ទាប់ពីការពិភាក្សាបានបញ្ចប់ ក្រុមនីមួយៗបានជ្រើសរើសតំណាងដើម្បីប្រាប់ពីទីតាំងត្រូវបានជម្លៀសទៅ និងសម្ភារដែលក្រុមរបស់ខ្លួនបានជ្រើសរើស ដូចខាងក្រោម ៖

- ក្រុមទី១ ដែលមានសមាជិកក្រុមរួមមានយ៉ុនសេងហួយ, ហាក់កញ្ញា, លឹមពៅ, ឆាយ លីណេ, ឌីន ថុនា, រេតមុនីរត្ន, ខឿនស្រីនាង, នាថហេង៉ា, ឈួន ឈុនហ៊ាង និង ហនស្រីណេង ទទួលបានទិសដៅជម្លៀសពីទីក្រុងភ្នំពេញមកកាន់ស្រុកចំការលើ ខេត្តកំពង់ចាម និងបានជ្រើសរើសសម្ភារ និងរបស់របរដាក់ក្នុងប្រអប់សង្គ្រោះជីវិតរបស់ខ្លួនរួមមាន៖ ឆ្នាំង, ក្រមា, ទឹក, អង្ករ, ថ្នាំប៉ារ៉ា, ចង្កៀង, ក្អម, កាំបិត, ចាន, ស្លាបព្រា និងសម្លៀកបំពាក់។ ក្រុមទី១បានបន្ថែមថា «ការជ្រើសរើសយកសម្ភារខាងលើនេះគឺសំខាន់ណាស់ក្នុងការចាកចេញពីផ្ទះដើម្បីធ្វើ



នៅថ្ងៃទី៦ ខែមេសា ឆ្នាំ២០២៣ សិស្សមកពីវិទ្យាល័យប៊ុនរានី ហ៊ុនសែន ស្ទឹង ចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍អំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥-១៩៧៩) រៀបចំដោយមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ដំណើរវែងឆ្ងាយ និងក្រោមកម្ដៅថ្ងៃក្ដៅខ្លាំង»។

- ក្រុមទី២ ដែលមានសមាជិកក្រុមរួមមាន លន់ ប៊ុនណូ, ឡេង វិចិត្ត, ស៊ី ស៊ឺ, ភោគ ថាវី, សំ មុននី, ជឿន បុផ្ផាលីហ្សា, សល់ សុធារ៉ា, ដៃ គន្ធា, ខេង សូលីដា, និងថាំ ធារ៉ា ទទួលបានទិសដៅជម្រៀសពីទីក្រុងភ្នំពេញមកកាន់ស្រុកកំពង់សៀម ខេត្តកំពង់ចាម និងបានជ្រើសរើសសម្ភារ និងរបស់របរដាក់ក្នុងប្រអប់សង្គ្រោះជីវិតរបស់ខ្លួនរួមមាន ៖ ទឹក, អង្ករ, សម្លៀកបំពាក់, ចាន, ឆ្នាំង, កាំបិត, ដែកកេះ, អំបិល ប្រហុក, ថ្នាំសង្កូវ និងអាហារក្រៀម។ ក្រុមទី២បានបន្តថា «ទឹកមានសារសំខាន់ជាងគេ ពីព្រោះខែមេសា មានអាកាសធាតុក្ដៅខ្លាំង ហើយយើងត្រូវផឹកទឹកជាចាំបាច់»។
- ក្រុមទី៣ ដែលមានសមាជិកក្រុម រួមមាន ណាល់ ស្រីមុំ, សែម នីហ្សា, ស៊ុល សៃណាល់, សុខ សុខិតា, ប៉ុម គឹមស័ង, គិត លីហ្សា, ជួន សុភត្រ្គា, ចាន់ ដា, ឆេន ឈុននី, ឌីន ធីតា, និង ណាស៊ាត់រ៉ូហ្សានី ទទួលបានទិសដៅជម្រៀសពីទីក្រុងភ្នំពេញមកកាន់ស្រុកកោះសូទិន ខេត្តកំពង់ចាម និងបានជ្រើសរើសសម្ភារ និងរបស់របរដាក់ក្នុងប្រអប់សង្គ្រោះជីវិតរបស់ខ្លួនរួមមាន ទឹក, ថ្នាំ, អាហារ, ឆ្នាំងដាំបាយ, មាសប្រាក់, ក្រមា, ខ្ទឹមស, កាំបិត, ស្បែកជើង, អង្ករ និងអំបិល។ ក្រុមទី៣បានគូសបញ្ជាក់ថា «អាហារ និង បាយ អាចជួយឲ្យយើងមានកម្លាំងបន្តដំណើរទៅមុខបាន»។
- ក្រុមទី៤ ដែលមានសមាជិកក្រុម រួមមាន ណុល លីណា, គង់ សុខគា, កេម វិនី, ហ៊ាង ធារី, ស្រេង រតនា, សារី រំលី, ថាត សុភ័ក្រ, យ៉េ នីតា, ផនខត្តម, លឹម រតនា, រៀម ចាន់រដ្ឋា និង រដ្ឋា រតនា ទទួលបានទិសដៅជម្រៀសពីទីក្រុងភ្នំពេញមកកាន់ស្រុកស្ទឹងត្រង់ និងបានជ្រើសរើសសម្ភារ និងរបស់របរដាក់ក្នុងប្រអប់សង្គ្រោះជីវិតរបស់ខ្លួនរួមមាន ទឹកចាំបាច់បំផុត, អង្ករសម្រាប់យកមកដាំបាយ, ថ្នាំសង្កូវសម្រាប់ព្យាបាលពេលឈឺ, សម្លៀកបំពាក់ប្រើសម្រាប់បិទបាំងរាងកាយ, ចង្កៀងប្រេងប្រើសម្រាប់ពន្លឺពេលយប់, មាស ពេជ្រ, ក្រមាសម្រាប់ទទូរពេលដើរហាលថ្ងៃ, ភួយសម្រាប់ដណ្តប់ការពារភាពត្រជាក់, ស្បែកជើង, មុង ការពារកុំឲ្យមូសខាំ, ម្ហូបសម្រាប់ហូប និងកាំបិតសម្រាប់ប្រើប្រាស់។



នៅថ្ងៃទី៦ ខែមេសា ឆ្នាំ២០២៣ សិស្សមកពីវិទ្យាល័យ ប៊ុន រ៉ានី ហ៊ុន សែន ស្គី ចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍ អំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥-១៩៧៩) រៀបចំដោយមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ក្រុមទី៤ បានលើកឡើងអំពីសម្ភារមួយដែលខុសប្លែកពីក្រុមផ្សេងទៀតនោះគឺ ចង្កៀងថា «ការធ្វើដំណើរដោយថ្មើរជើងក្រោមកម្ដៅថ្ងៃក្ដៅ ខ្លាំងក្នុងខែមេសានេះ គឺមិនបានឆ្ងាយនោះទេ និងពិតជាហត់នឿយខ្លាំងណាស់។ ដូច្នេះហើយ យើងបានយកចង្កៀងបំភ្លឺផ្លូវ ដើម្បីធ្វើដំណើរនៅពេលយប់ ដែលមិនសូវក្ដៅ»។

- ក្រុមទី៥ ទទួលបានទិសដៅជម្លៀសពីទីក្រុងភ្នំពេញមកកាន់ស្រុកកងមាស ខេត្តកំពង់ចាម។ សមាជិកក្នុងក្រុមបានជ្រើសរើសសម្ភារ និងរបស់របរដាក់ក្នុងប្រអប់សង្គ្រោះជីវិតរបស់ខ្លួនរួមមាន៖ ទី១) រៀម រតនា យកអង្ករទុកដាំបាយតាមផ្លូវ។ ទី២) រ៉េត រដ្ឋា យកឆ្នាំងដើម្បីហូបជាមួយបាយ។ ទី៣) រំលី ទីយ៉ា យកស្ករដែនពីព្រោះស្ករដែនអាចផ្ដល់កម្លាំងដល់យើងពេលធ្វើដំណើរ និងមិនមានអាហារហូប។ ទី៤) វ៉ែង រួចលី យកទឹកដើម្បីផឹក។ ទី៥) មឿន សុម៉ារ័ត្ន យកថ្នាំសង្គ្រោះបឋមដើម្បីប្រើប្រាស់នៅពេលធ្លាក់ខ្លួនឈឺ។ ទី៦) ផុន យូរីណា យកកាំបិតដើម្បីប្រើប្រាស់។ ទី៧) វ៉ុន ដាម៉ាន់ យកប្រហុកដើម្បីហូប ពីព្រោះប្រហុកអាចរក្សាទុកបានយូរ។ ទី៨-៩) សេង រិន និង ហេង សុគន្ធ យកដែកកេះដើម្បីបង្កាត់ភ្លើង និង ទី១០) ជីវី សហ្សារី យកឆ្នាំងដើម្បីដាំបាយ និងស្ល។

ក្រុមនីមួយៗបានឡើងចែករំលែកអំពីសម្ភារ និងរបស់របរក្នុងប្រអប់សង្គ្រោះជីវិត និងទិសដៅជម្លៀសរបស់ខ្លួន និងការយល់ឃើញរបស់ខ្លួនអំពីទុក្ខលំបាករបស់ប្រជាជនដែលត្រូវបានបង្ខំឲ្យចាកចេញពីផ្ទះរបស់ខ្លួន និងធ្វើដំណើរក្រោមកម្ដៅព្រះអាទិត្យនៃខែមេសា។

កម្មវិធីបន្ទាប់ គឺការចុះទៅកាន់ចេតិយរំឭកសម្រាប់សហគមន៍ដែលស្ថិតនៅកណ្ដាលវាលស្រែក្នុងភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម។ នៅពេលទៅដល់ទីតាំងចេតិយរំឭកសម្រាប់សហគមន៍នេះ សិស្សទាំងអស់ត្រូវបានផ្ដល់ឱកាសឲ្យជួបសន្ទនាផ្ទាល់ជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ អ៊ំប្រុស តុង សុភា អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងជាតំណាងសមាគមអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមក្នុងមូលដ្ឋានភូមិចំការសាមសិប បាននិយាយប្រាប់សិស្សអំពីទីតាំងសម្លាប់ប្រជាជននៅក្នុងឃុំគគរក្នុងរបបខ្មែរក្រហម, បទពិសោធន៍ និងការបាត់បង់ឪពុក និងគោលបំណងនៃការសាងសង់ចេតិយរំឭកនេះឡើង។ បន្ទាប់មក សិស្សចូលរួមទាំងអស់បន្តទៅទស្សនកិច្ចនៅវត្តរកាគយ ដែលជាអតីតបន្ទាយទាហាន លន់ នល់ និងទីតាំងសមរភូមិក្ដៅរវាងទាហាន លន់ នល់ និងកងទ័ពរំដោះខ្មែរក្រហម។

សិស្ស វ៉ែង រួចលី រៀនថ្នាក់ទី១២ មុខវិជ្ជាវិទ្យាសាស្ត្រពិតនៃវិទ្យាល័យ ប៊ុន រ៉ានី ហ៊ុន សែន ស្គី បង្ហាញទស្សនយល់ឃើញបន្ទាប់ពីបានចូលរួមវេទិកាថ្នាក់រៀនថា «ខ្ញុំទទួលបានចំណេះដឹងថ្មីៗអំពីប្រវត្តិសាស្ត្រខ្មែរក្រហម និង វិនាសកម្ម ព្រមទាំងការបាត់បង់ដែលបន្សល់ទុកដោយរបបនេះ។ ខ្ញុំពិតជាមានចិត្តអាណិតអាសូរដល់ប្រជាជនជំនាន់មុនខ្លាំងណាស់។ បន្ថែមលើនេះទៀត ខ្ញុំដឹងអំពីព្រឹត្តិការណ៍សម្លាប់រង្គាល និងអំពើប្រល័យពូជសាសន៍ដែលបានចាប់ផ្ដើមនៅទីកន្លែងផ្សេងទៀតក្នុងប្រវត្តិសាស្ត្រសកលលោកនៅខែមេសានេះដែរ»។

សិស្ស ហ៊ាង ធារី ថ្នាក់ទី១២ មុខវិជ្ជាវិទ្យាសាស្ត្រពិតនៃវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន ស្ពឺ និយាយថា «ខ្ញុំមិនដែលដឹងទេថា ខែមេសា គឺជាខែដាស់តឿន និងរំឭកអំពីអំពើប្រល័យពូជសាសន៍ដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា និងបណ្តាប្រទេសផ្សេងទៀត។ ការចងចាំអំពីជនរងគ្រោះដែលបានស្លាប់ក្នុងរបបខ្មែរក្រហម និងការស្តាប់រឿងរ៉ាវជីវិតរបស់អ្នករស់រានមានជីវិតដែលបានឆ្លងកាត់របបនេះ គឺពិតជាមានអត្ថន័យណាស់សម្រាប់ខ្ញុំដែលជាក្មេងជំនាន់ក្រោយ។ ខ្ញុំនឹងខិតខំរៀនសូត្របន្ថែមទៀតដើម្បីចូលរួមការពារកុំឲ្យរបបនេះកើតឡើងជាថ្មីម្តងទៀត»។

សិស្ស សាលី រំលី ថ្នាក់ទី១២ មុខវិជ្ជាវិទ្យាសាស្ត្រពិតនៃវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន ស្ពឺ ទទួលបានចំណេះដឹងថ្មីៗដែលខ្លួនមិនដែលដឹងពីមុនមក និងបានលើកឡើងថា «ខ្ញុំយល់ដឹងអំពីប្រជាជនខ្មែរជំនាន់មុនដែលបានរស់នៅឆ្លងកាត់សង្គ្រាមរ៉ាំរ៉ៃ និងរបបប្រល័យពូជសាសន៍ខ្មែរក្រហម។ ខ្ញុំដឹងអំពីទុក្ខលំបាកប្រជាជនជម្លៀសក្នុងអាកាសធាតុក្តៅ និងការមិនមានសម្ភារគ្រប់គ្រាន់នៅពេលនោះ។ ខ្ញុំមានការអាណិតអាសូរដល់អ្នកទាំងនោះ»។







នៅថ្ងៃទី៦ ខែមេសា ឆ្នាំ២០២៣ សិស្សមកពីវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន ស្ពឺ ចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍ អំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥-១៩៧៩) រៀបចំដោយមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



# ជំនួបជាមួយលោក ឯក ចិន្តា ចៅសង្កាត់ កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង ថ្ងៃទី១១ ខែមេសា ឆ្នាំ២០២៣

ថុន ស្រីពេជ្រ





នៅថ្ងៃទី១១ ខែមេសា ឆ្នាំ២០២៣ បុគ្គលិកមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង ជួបជាមួយ លោក ឯក ចិន្តា ចៅសង្កាត់កំពង់លាវ ដើម្បីជម្រាបអំពីគោលបំណងនៃការអនុវត្តកម្មវិធីចំនួន៤ ដែលមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែងបានធ្វើឡើងជារៀងរាល់ខែនៅក្នុងការិយាល័យរបស់ខ្លួន ស្ថិតនៅក្នុង ភូមិ២ សង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នារសៀល ថ្ងៃទី១១ ខែមេសា ឆ្នាំ២០២៣ បុគ្គលិកមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង បានធ្វើការទាក់ទង និងបានទៅជួបជាមួយ លោក ឯក ចិន្តា ចៅសង្កាត់កំពង់លាវដើម្បីជម្រាបអំពីគោលបំណងនៃការអនុវត្តកម្មវិធីចំនួន៤ ដែលមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែងបានធ្វើឡើងជារៀងរាល់ខែនៅក្នុងការិយាល័យរបស់ខ្លួន ស្ថិតនៅក្នុង ភូមិ២ សង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង។

បន្ទាប់ពីស្តាប់របាយការណ៍រួច លោកចៅសង្កាត់បានទទួលស្វាគមន៍ក្រុមការងារ ដោយទឹកមុខសប្បាយរីករាយ។ ជាកិច្ចចាប់ផ្តើម ភារស្នើបុគ្គលិកមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង បានជម្រាបបន្ថែមអំពីដំណើរការនៃសកម្មភាពការងាររបស់មជ្ឈមណ្ឌលឯកសារ ខេត្តព្រៃវែងចំនួន៤ ដែលត្រូវបានធ្វើឡើងជារៀងរាល់ខែ គឺ ទី១) វេទិកាថ្នាក់រៀនជាមួយសិស្សានុសិស្ស ទី២) វេទិកាអប់រំសហគមន៍ជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងសិស្សានុសិស្ស ទី៣) វេទិកាអប់រំសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ទី៤) វេទិកាប្រវត្តិសាស្ត្រគ្រួសារ។

ជាមួយគ្នានេះដែរ ចំពោះគម្រោងវេទិកាប្រវត្តិ-

សាស្ត្រគ្រួសារ ភា រស្មី បានបន្ថែមថា ខាងមជ្ឈមណ្ឌលសុំការអនុញ្ញាតពីលោកចៅសង្កាត់ដើម្បីចុះសម្ភាសន៍ជាមួយអ្នករស់រានមានជីវិតនៅតាមផ្ទះនីមួយៗ ដែលរស់នៅក្នុងសង្កាត់កំពង់លាវ ទាំងមូល ដើម្បីប្រមូលសាច់រឿងរបស់ អ្នករស់នៅក្រោមរបបខ្មែរក្រហម មកចងក្រងធ្វើជាឯកសារតម្កល់ទុកសម្រាប់ក្មេងជំនាន់ក្រោយបានសិក្សារៀនសូត្រ។

បន្ថែមពីលើនេះ ភា រស្មី បានជម្រាបអំពីដំណើរការនៃការជ្រើសរើស អ្នកស្ម័គ្រចិត្តក៏ដូចជាបុគ្គលិកកិច្ចសន្យាក្នុងរយៈពេលមួយឆ្នាំពេញដល់លោកចៅសង្កាត់។ ឱកាសនោះ លោកចៅសង្កាត់ បានលើកឡើងថា ជាការល្អដែលមជ្ឈមណ្ឌលឯកសារបានជម្រាបជូនគាត់អំពីដំណើរការនៃការចុះអនុវត្តការងារនីមួយៗ ការពារមានអ្នកសួរនាំច្រើន និងដើម្បីសុវត្ថិភាពនៅតាមភូមិឃុំ ក៏ដូចជា ដំណើរការនៃការចុះអនុវត្តគម្រោងបានប្រព្រឹត្តទៅយ៉ាងរលូន។

ជាចុងក្រោយ ភា រស្មី តំណាងឲ្យមជ្ឈមណ្ឌលឯកសារ ខេត្តព្រៃវែង បានថ្លែងអំណរគុណលោកចៅសង្កាត់ ចំពោះការសហការ និងការអនុញ្ញាតឲ្យមជ្ឈមណ្ឌលឯកសារ ខេត្តព្រៃវែងអនុវត្តគម្រោងរបស់ខ្លួនដោយរលូន។



នៅថ្ងៃទី១១ ខែមេសា ឆ្នាំ២០២៣ បុគ្គលិកមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង ជួបជាមួយ លោក ឯក ចិន្តា ចៅសង្កាត់កំពង់លាវ ដើម្បីជម្រាបអំពីគោលបំណងនៃការអនុវត្តកម្មវិធីចំនួន៤ ដែលមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែងបានធ្វើឡើងជារៀងរាល់ខែនៅក្នុងការិយាល័យរបស់ខ្លួន ស្ថិតនៅក្នុង ភូមិ២ សង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)


















# បណ្ណាល័យមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង

បណ្ណាល័យមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងនៃមជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូន សិស្ស និស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ អង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍អំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។

បណ្ណាល័យមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង គឺជាកន្លែងប្រមូលផ្តុំ និងតម្កល់ឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅបណ្ណាល័យមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង មានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយ គឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរ គឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបី គឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួន គឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។

តាមរយៈបណ្ណាល័យមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង សាធារណជនអាចនឹងស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមាន៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាពកំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ថនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។



## បណ្ណាល័យកងពលតូចថ្មើរជើងលេខ ៨១

***បណ្ណាល័យប្រវត្តិសាស្ត្រយោធា ស្ថិតនៅក្នុងកងពលតូចថ្មើរជើងលេខ ៨១ ក្នុងស្រុកអន្លង់វែង ខេត្តបន្ទាយមានជ័យ។***

បណ្ណាល័យមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង មានទីតាំងនៅភូមិអូរចិញ្ចៀន ឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ ការិយាល័យរបស់យើងបើកជូនសាធារណជនចាប់ពី ថ្ងៃចន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង ៨៖០០ ដល់ម៉ោង ១២៖០០ និងពេលរសៀលពីម៉ោង២៖០០ដល់ម៉ោង៥៖០០។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទង បណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង តាមរយៈ ទូរសព្ទលេខ៖ ០១២ ៥៧០ ៤៦៥ ឬ អ៊ីម៉ែល ៖

truthlysokkheang@dccam.org

សូមអរគុណ!











## «ទួលពិឃាដ» (ត)

# ១២. លាភូមិកំណើតលុះអវសានជាតិ (ត)

### សរម្រែកបណ្តាំចុកឈាម (ត)

...អ៊ីយកដៃមកអង្អែលក្បាលក្មួយទាំងពីរពោលទាំងខ្សឹកខ្សួលអារម្មណ៍ថា "អ៊ីអាណិតក្មួយណាស់ មិនគួរគេសម្លាប់ឪពុកម្តាយចោល ទុកឲ្យកំព្រាទាំងក្មេងខ្ចីដូច្នេះ។

ហ៊ឺ ប្អូនឆេង ប្អូនឡុង ដែលជាឪពុកម្តាយក្មួយពេលគេសម្លាប់ ពិតជាបិទភ្នែកមិនជិតទេព្រោះអាល័យកូនៗមិនដឹងរស់នៅរបៀបណា? វិញ្ញាណប្រាកដជាវិលវល់ក្នុងវដ្តសង្សារគ្មានកោះត្រើយ"។ ឮពាក្យនេះខ្ញុំ ស្រមៃថយក្រោយ ទឹកភ្នែកហូរកាន់តែខ្លាំងកាត់ដែនថ្ពាល់ដែលមិនអាចទប់បាន ហើយអ៊ីលើកដៃសំពះទៅលើ ជូតទឹកភ្នែកផងពោលផង ទាំងសំឡេងយំជាចំៗថា "សូមវិញ្ញាណក្ខន្ធប្អូនឆេង លោកប្អូន ឡុង និងកូនក្មួយ ទាំងអស់បានសោយក្នុងសុគតិភពចុះ"។

រួចពីនោះ គាត់ងាកមកក្មួយទាំងពីរដោយហុចត្រឡោកដូងមានទឹក ហើយនិយាយថា "នេះក្មួយផឹកទឹកសិនទៅ ចាំបន្តិចតាឯងទៅកាប់ធាងត្នោតមកធ្វើដងវែក"។ មួយសន្ទុះខ្ញុំឃើញតាកាន់ធាងត្នោត ដែលគាត់ធ្វើជារាងដងវែករួចជាស្រេច ហើយព្យួរនំកូរបាយដំណើប និងស្ករត្នោតនៅកណ្តាលដងវែក។

ប្អូនដើរខាងមុខចំណែកខ្ញុំដើរខាងក្រោយ ខ្ញុំនិយាយជម្រាបលាតានិងអ៊ី។ រៀបចេញដំណើរ អ៊ីស្រែកថា "ឈប់សិនក្មួយ! នេះថ្មដែកកេះមានពីរគ្រាប់យកទៅផ្ញើយាយឯងផង។" ពេលនោះខ្ញុំតបថា"មានដែកកេះឯណាប្រើទៀត"។ អ៊ីសួរបន្ត ចុះដែកកេះអ៊ីទើបនឹងផ្ញើឲ្យថ្ងៃមុននោះ? ខ្ញុំឆ្លើយ "ដែកកេះនោះ ត្រូវទាហានវៀតណាមយកទៅបាត់ហើយ នៅព្រឹកថ្ងៃចូលឆ្នាំដំបូង ក្រោយតាចេញពីភូមិមកទីនេះ។ ពួកគេចូលមកប្រហែលម្ភៃសាមសិបនាក់ប្រដាប់ដោយកាំភ្លើងអាកា និងបេសែសិប គ្រាប់ដៃ។ សូម្បីនំអន្សមនំគម ដែលយាយដាក់ថ្វាយទេវតាក៏ពួកគេប្រមូលទៅអស់ដែរ" ។ តានិយាយកាត់ "អូ! ដល់ថ្នាក់នឹងផង?"។ ហើយគាត់បានប្រាប់ទៅអ៊ីថា"នែកូនយកដែកកេះដែលកូនប្រើសព្វថ្ងៃឲ្យទៅក្មួយទៅ។" រួចអ៊ីក៏ដើរសំដៅទៅចង្ក្រានបាយ ហើយហុចឲ្យខ្ញុំ។

ខ្ញុំយកវាមករុំនឹងក្រមាហើយក្រវាត់ចងនឹងចង្កេះ ទឹកភ្នែកហូរលាតា និងអ៊ី។ "ខ្ញុំលាសិនហើយ" គាត់តបព្រមៗគ្នាអ៊ីៗ "ចៅ ក្មួយទៅឲ្យបានសុខណា ហើយកុំភ្លេចបណ្តាំតាឯងប្រាប់យាយ និងក្មួយចិន្តា ណាត និងក្មួយខស្សរាហ៍មកលេងតាផង ព្រោះគាត់កាន់តែចាស់ហើយ"។

ប្អូនលីធាងត្នោតដើរខាងមុខ ខ្ញុំដើរខាងក្រោយក្នុងចិត្តសែនទោម្នេញយំមិនចេញ។ ខ្ញុំងាកមើលក្រោយឃើញតា និងអ៊ី នៅតែឈរសម្លឹងមើលចៅ និងក្មួយក្នុងចិត្តសង្វេគ ដែលរកអ្វីមកប្រៀបផ្ទឹមពុំបាន។ ខ្ញុំនឹកឃើញពាក្យសម្តីតាគាត់និយាយអម្បាញ់មិញដែលពោរពេញដោយកំហឹង ហើយចង្អុលទៅភូមិកំណើត។

គាត់ពិតជាមានការស្តាយយ៉ាងខ្លាំង ដែលគាត់ខំធ្វើអំពើល្អកន្លងមកជាមួយអ្នកភូមិគាត់ ក្រោយមកបែរជាទទួលនូវលទ្ធផលដ៏អាក្រក់ចំពោះគ្រួសារគាត់ពីពួកមេកងកម្មាភិបាលបដិវត្តន៍មួយចំនួនដែលមានការប្រណែនឈ្នានីស ស្អប់ខ្ពើមគុំគួន និងលាបពណ៌គ្រប់រូបភាពដើម្បីបំបែកបំបាក់កូនចៅឪពុកម្តាយ ដោយមិននឹកស្មានថារសជាតិជីវិតរបស់គាត់ធ្លាក់មកក្នុងអន្លង់កម្មប្រចាំកាយយ៉ាងនេះសោះ។ ជីវិតចុងក្រោយរបស់គាត់ ដែលគិតថារស់នៅសុខដុមរមនាជាមួយកូនចៅតរៀងទៅដល់ចាស់ព្រឹទ្ធចាស់ព្រេងរៀងៗខ្លួន។

ខ្ញុំដើរមកដល់ដើមខ្វិត នឹកឃើញអ៊ីគាត់បេះឲ្យខ្ញុំហូបៗ រៀបបត់ចូលផ្លូវធំ ខ្ញុំងាកមើលទៅតា និងអ៊ីនៅតែឈរសម្លឹងមក ឃើញគាត់ទាំងពីរយក

ក្រមាជូតមុខៗ មិនខុសទេ គឺគាត់កំពុងតែយកក្រមាជូតទឹកភ្នែកដែលហូរនឹកស្រណោះអាឡោះអាល័យក្មួយ និងចៅកំព្រាទាំងពីរដែលឃ្លាតឆ្ងាយបន្តិចម្តងៗ ពីកម្រងមនោសញ្ចេតនាដែលយើងប្រាថ្នាបានតែក្នុងក្តីស្រមៃប៉ុណ្ណោះ។

ខ្ញុំឈានជើងមួយជំហានក៏បាត់ស្រមោលគាត់ទាំងពីរ គាត់ពិតជាមានអារម្មណ៍ក្តុកក្តួលមិនខុសពីរូបខ្ញុំដែរ។ ជីវិតក្មេងទាំងពីរបានលីរបស់របរដែលអ៊ុំឲ្យ ធ្វើដំណើរតាមផ្លូវមកកាន់ភូមិក្រាំងវិញ។

គ្រប់រូបភាពបានដក់ជាប់ក្នុងដួងចិត្ត ហើយនៅសញ្ជប់សញ្ជឹងតាមផ្លូវ ហាក់ដូចជារឿងរ៉ាវត្រលប់ថយក្រោយដែលបានបោកប្រាណរុញច្រានវាសនាជីវិតឲ្យធ្លាក់ក្នុងរណ្តៅទុក្ខ។

ខ្ញុំមជីវិតអភ័ព្វបានស្រោចស្រពពេញវិញ្ញាណឲ្យវង្វេងស្មារតី មានជីវិតស្រាលជាងសម្លីដែលហើរគ្មានកោះត្រើយ ទៅតាមខ្យល់បក់។ ភ្នក់ភ្លើងជីវិតពិតជាក្តៅខ្លាំងណាស់ ដែលខ្ញុំពិបាកទ្រាំនឹងការរុកកួនផ្លូវចិត្តឲ្យគិតអ្វីពុំយល់ គឺយល់តែទុក្ខសោកលើផែនដីក្នុងវាលស្រែល្ហល្ហេវគ្មានដែនដូចជាជីវិតងងឹតឥតរស្មីនៅពេលនេះដែរ។ ដើរបណ្តើរទឹកភ្នែកស្រក់បណ្តើរ។ អារម្មណ៍សោកសៅបានបើុងមកប៉ះ ដាស់ឲ្យខ្ញុំនឹកឃើញរឿងអតីតដ៏ជូរចត់កន្លងមក។

ខ្ញុំពីរនាក់ប្អូនដើរបានពាក់កណ្តាលផ្លូវ ព្រះអាទិត្យថ្ងៃត្រង់បញ្ចេញកម្តៅ ខ្ញុំយកដៃជូតញើសដែលកំពុងហូរដូចឈាមក្រោមកម្តៅថ្ងៃ ហើយក៏ប្រាប់ប្អូនថា "តស់ប្អូនយើងសំដៅទៅជ្រកក្រោមម្លប់ដើមត្នោតមួយដើមនោះសិនទៅ"។

យើងដាក់អំរែកចុះពីលើស្មា ហើយយកនំកូរម្នាក់មួយមកទំពាបំបាត់ការស្រេកឃ្លាន ហើយមើលមុខគ្នាបន្តប់ដោយភាពស្រងូតស្រងាត់។ នំកូធ្វើឲ្យខ្ញុំបាត់ឃ្លានមែន តែក្តីនឹករលឹកចំពោះឪពុកម្តាយ ប្អូនភ្លោះ បងប្រុសនៅតែស្រេកឃ្លានយ៉ាងខ្លាំងដែលមិនអាចយកអ្វីមកបាំងឲ្យបំភ្លេចបានឡើយ។

ខ្ញុំពីរនាក់ប្អូនសម្រាកក្រោមដើមត្នោតមួយសន្ទុះ រួចក៏និយាយទៅប្រាប់ប្អូនថា "តស់យើងចេញដំណើរទៅទៀត"។ ពីរនាក់ប្អូនដើរក្រោមកម្តៅថ្ងៃឡើងក្រហាយខ្នងភាយៗ។ ខ្ញុំមានអារម្មណ៍ថាជំងឺខ្ញុំដូចជាចង់រើមកវិញព្រឺរងាៗ ខ្ញុំខាំមាត់សង្កត់ចិត្ត តាំងស្មារតីបេះតែតស៊ូទ្រាំមិនឲ្យប្អូនដឹង។ ឃើញដានជើងក្របីមួយមានដក់ទឹក យើងបានឱនដឹកទឹកម្នាក់ពីរបីក្អឹករួចបន្តដំណើរ។

ធ្វើដំណើរយូរគួរសម យើងបានចូលក្នុងភូមិ និងបានមកដល់ផ្ទះ។ ឃើញយាយបងស្រីបងណាតស្ទុះមកទទួលខ្ញុំហើយពោលថា ប្អូនទាំងពីរបានអ្វីមកខ្លះ? ខ្ញុំឆ្លើយថាអ៊ុំបានផ្ញើនំកូបាយដំណើប និងស្ករត្នោតមកជាមួយ។ យាយបន្តថា "តើតានិងអ៊ុំទូចសុខសប្បាយទេ?" ខ្ញុំតបថា "គាត់ទាំងអស់គ្នាសុខសប្បាយធម្មតាទេ។ តែតាបានផ្តាំមកប្រាប់យាយ និងបងទាំងពីរថា គាត់មិនត្រលប់មករស់នៅក្នុងភូមិនេះវិញឡើយ ទាំងទឹកភ្នែកហូររហាមៗ មិនតែប៉ុណ្ណោះគាត់ផ្តាំអ៊ីទៀតថា បើសិនថ្ងៃក្រោយគាត់ស្លាប់ទៅមិនត្រូវយកសពគាត់មកបូជាឬបញ្ចុះនៅលើទឹកដីភូមិក្រាំងនេះជាដាច់ខាត"។

បណ្តាំទាំងប៉ុន្មានខ្ញុំបានរ៉ាយរ៉ាប់អស់ហើយ ពួកយើងទាំងអស់គ្នាមើលមុខគ្នានូវភាពសោកសៅនៃបណ្តាំចុកឈាមនេះ។ បន្ទាប់មកយាយបាននិយាយថា "ត្រូវហើយចៅៗ តាពិតជាមានការឈឺចាប់ណាស់។ មួយរយៈមុនយប់ណាក៏ដូចយប់ណាដែរ គាត់សម្រាន្តមិនលក់ទេ។ យាយឃើញគាត់រសាប់រសល់ប្រែចុះប្រែឡើងជូនកាលដេកទាំងយកដៃគងថ្ងាស ដូចជាគិតរឿងអ្វីមិនឈប់សោះ ហើយតាតែងតែនិយាយប្រាប់យាយថា "យាយអើយ ខ្ញុំមិនអាចរស់នៅភូមិនេះបានទេ ព្រោះដេកទៅមិនដែលបិទភ្នែកជិតឡើយ ឃើញតែមុខកូនស្រីកូនប្រុស និងចៅៗ នៅមុខស្រស់ៗ" ខ្ញុំតបទៅយាយ "ហើយតាបានផ្តាំទៀតថា ឲ្យចៅ ខស្សាហ៍ទៅលេងគាត់ផង"។

ពិតជាគ្រួសារប្រេះស្រាំរបួសដួងចិត្តដែលបានផ្តិតជាប់អារម្មណ៍សំងំបៀមទុក្ខ គ្មានថ្ងៃរលត់ឲ្យផុតវេរានូវកាលៈទេសៈកន្លងមក។ ទោះជាយើងខំជ្រកម្លប់ថ្មីវានៅតែមានរន្ធធ្លុះធ្លាយនៃវិបត្តិផ្លូវចិត្តដែលមានកម្រិតធ្ងន់ធ្ងរបំផុតគ្រប់ៗគ្នា។

ម្នាក់ៗសញ្ជប់សញ្ជឹងដូចស្ទិងស្មាធិ៍រៀងៗខ្លួន។ យាយក៏ពោលមកកាន់ចៅៗថា "ម៉ោះចៅ មកញ៉ាំនំដែលអ៊ុំឯងផ្ញើមកឲ្យសិនទៅ"។ ម្នាក់ៗនឹកមិនអស់ចិត្តនឹងបណ្តាំតា នៅពេលគាត់ផុតរលត់សង្ខារឲ្យប្រាសចាកពីភូមិនេះចុះ!។

ទោះជាយ៉ាងណា គ្រួសារខ្ញុំលំបាកវេទនាណាស់ ទ្រូងស្ទើររលេះរលួយ។ ហ៊ឺ! រឿងដូនៗកើតមានមិនឈប់សោះ ទោះជាយើងខំលោតផ្លោះរំលងយ៉ាងណា។

ខ្ញុំនៅតែស្រណោះតាវាចាពោលពាក្យបណ្តាំចុកឈាមជាមួយកំហឹងកក្រើកញ័រខ្លួន និងសម្រែកទឹកភ្នែកហូរដោកជាំដួងចិត្តស្ទើរស្លាប់ស្ទើររស់ ប៉ុន្តែយើងនៅតែពុះពារតស៊ូយកជ័យជម្នះឲ្យបានលើផ្លូវជីវិត ទាំងកាយទាំងចិត្ត ដែលយើងសង្ឃឹមថ្ងៃមួយជីវិតនឹងស្រស់បំព្រងជាមិនខាន។

# ១៣. ឆាកជីវិតក្រោយព្យុះសង្គ្រាមជិចត្តន៍

## ផ្លែបាំងមែក

ទំនប់ព្រែកដំបង

បន្ទាប់ពីរួចផុតពីការតាមប្រមាញ់សម្លាប់ឲ្យផុតពូជ និងរបបខ្មែរក្រហមត្រូវបានបញ្ចប់ផង ខ្ញុំ បងប្រុស បងស្រី ប្អូន និងតាយាយបានមករស់នៅផ្ទះកំណើតក្នុងភូមិក្រាំងវិញ។

គ្រួសារយើងដើររើសកួរស្រូវជាប់នឹងដី និងប្រមូលគ្រាប់ស្រូវដែលជ្រុះក្នុងស្រែមកលាងទឹកដើម្បីបុកយកអង្ករដាំបាយហូប ធ្វើស្រែដើម្បីចិញ្ចឹមជីវិត និងឡើងត្នោតយកទឹកមករំងាស់ជាស្ករ។

ប្រជាជនមូលដ្ឋានគេដើរប្រមូលកេរដំណែលដូចជាស្រែចម្ការគោក្របីរបស់គេ។ ពេលនេះ ជារដូវច្រូតកាត់មានទម្ងួរស្រូវទុំក្នុងស្រែ និងស្រូវដែលពួកខ្មែរក្រហមប្រមូលផលមិនទាន់អស់ដោយកងទ័ពវៀតណាមចូលមករំដោះ។ ប្រជាជនទាំងនោះបានទៅច្រូតស្រូវតាមស្រែរបស់គេរៀងៗខ្លួន។

ថ្ងៃមួយធំបេះ (ប្ដីរបស់ធំតែម) ធំតែម បងស្រី និងខ្ញុំចេញទៅច្រូតស្រូវដែលជាកេររបស់ធំតែមនៅវាលពោធិ៍ចង្ក្រានខាងជើងភូមិព្រៃស្រឡិតខាងកើតភូមិគកកើត។

ព្រលឹមស្រាងៗខ្ញុំបររទេះចេញទៅដោយធំតែមឌឹករទេះនឹងគោពីពូអិ។ នៅលើវាលស្រែធំល្វឹងល្វើយ យើងឱនងើបៗដើម្បីត្រកងស្រូវកាត់នឹងកណ្ដៀវចំពាស់ជាមួយសេចក្ដីសប្បាយរីករាយនឹងស្រូវដាក់គ្រាប់ពេញៗកួរយ៉ាងត្រលុកត្រលន់ក្រហមប្រាលដូចកម្រាលព្រំ។

ច្រូតកាត់រួចយើងទាំងអស់គ្នាដើរប្រមូលស្រូវចងជាកណ្ដាប់ ចំណែកបងស្រី ធំតែម និងអ្នកដទៃទៀតធ្វើដំណើរមកផ្ទះមុននៅសល់ខ្ញុំនិងធំបេះប្រមូលកណ្ដាប់ដាក់ក្នុងរទេះ។ កណ្ដាប់ស្រូវច្រើនពេកខ្ញុំរៀបរហូតដល់ប្រាំសាខ្ពស់ជាងរទេះលិចក្បាលហើយបររទេះសំដៅមកភូមិវិញ។ ធំបេះដើរពីក្រោយដោយគ្មានកន្លែងជិះ ខ្ញុំឈរលើទូករទេះកាន់ខ្សែញាក់គោ។

ថ្ងៃបាក់រសៀលគោដើរផងបោលផងសំដៅចូលភូមិ ដីហុយទ្រលោម ធំបេះស្រែកពីក្រោយថា "ក្មួយកុំបរលឿនពេកៗ"។ តើឲ្យខ្ញុំធ្វើដូចម្ដេច? ទោះជាខ្ញុំទាញខ្សែញាក់ថា "ហបៗ" ឲ្យឈប់យ៉ាងណាក៏ដោយ។ ខ្ញុំទាញខ្សែឲ្យវាឈប់តែទាញមិនឈ្នះគោ។ វាបោលរត់តាមផ្លូវរទេះ មកដល់ខាងលិចព្រៃដំបង វាបានបោះពួយយ៉ាងលឿនចូលទៅក្នុងប្រឡាយដែលមានផ្លូវចុះរាងចំណិតត្រសក់។ ពេលនោះធំបេះនៅតែស្រែកប្រយ័ត្នៗក្មួយកុំលឿនពេកៗ។ ខ្ញុំតូចកម្លាំងខ្សោយមិនអាចបញ្ឈប់វាបានក្នុងការបោះពួយអូសរទេះឆ្លងកាត់ប្រឡាយទេ។

ឮសំឡេងដាំង! អ៊ីៗត្រូវបាក់ឈើងទាំងអស់។ បន្ទាប់មកខ្ញុំឮសំឡេងស្រែកលើយៗ "ក្មួយនៅឯណា?ៗ"។ ខ្ញុំខំប្រឹងងើបឡើងលើមានកណ្ដាប់ស្រូវកប់ជាប់នៅក្នុងរណ្ដៅថ្លុកក្របី។ ពេលនោះខ្ញុំលូនចេញមកក្រៅ ខ្លួនប្រឡាក់សុទ្ធតែភក់ល្បាប់ ឃើញគោទាំងពីរជាប់នឹងនឹមនៅក្បែរដំបូកមួយ ចំណែកទូករទេះដាច់ជាពីរ រទេះក្រឡាប់ផ្ងារកង់ឡើងលើ។ ធំបេះស្ទុះមកអង្អែលខ្ញុំពោលក្នុងទឹកមុខអាណិត "ក្មួយមានត្រូវត្រង់ណាទេ?" ខ្ញុំឆ្លើយថា "មិនអីទេ"។

អ្នកភូមិដែលបានឃើញហេតុការណ៍នោះ បានប្រាប់ដល់បងស្រីនិងធំតែមថា អាវង្សត្រូវរទេះក្រឡាប់លើមិនដឹងយ៉ាងម៉េចទេជួយទៅមើលផង ព្រោះខ្ញុំឃើញគោបោលយ៉ាងលឿនបោះពួយចូលប្រឡាយ។ បន្ទាប់មកទូករទេះដាច់ជាពីរក្រឡាប់ពីរបីត្រឡប់កិនលើអាវង្ស។

ឮដូច្នោះ បងស្រីខ្ញុំ ធំតែម និងពូអិ ស្ទន់ស្ទោររត់ប្រញាប់មកប្រឡាយព្រៃដំបងយ៉ាងលឿនមកដល់ឃើញខ្ញុំ

**ឡុង ខត្យសមិទ្ធ**

*(តនៅលេខក្រោយ)*

រូបក្របមុខ៖
កងទ័ពបដិវត្តន៍ខ្មែរក្រហមធ្វើដំណើរតាមបណ្តោយមហាវិថីព្រះមុន្នីវង្សដោយមានទទួលស្វាគមន៍និងអបអរសាទរពីប្រជាជន។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រូបក្របក្រោយ៖
កងបដិវត្តន៍ខ្មែរក្រហមបណ្តេញប្រជាជនចេញពីផ្ទះសម្បែង បន្ទាប់ពីឡើងគ្រប់គ្រងអំណាច នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)




**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**

ផ្ទះលេខ១១ ផ្លូវ២៥៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ៖ (៨៥៥) ២៣ ២១១ ៨៧៥

DC-Cam/PIR: #11 ◆ Street 256 ◆ Sangkat Chatomuk ◆ Khan Daun Penh ◆ Phnom Penh ◆ Cambodia 12200

Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org

A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 280, April 2023 ◆ Funded by USAID

Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M. PRA. KA, 30 October 2018.